# ព្រឹត្តិបត្រ ការងារ

Labour Bulletin

ឆ្នាំទី១ លេខ០០១

ចេញផ្សាយប្រចាំខែសីហា ឆ្នាំ២០១១

*Vol. 1 Issue 001 August 2011*






## មគ្គុទេសក៍អាជីព
## Career GUIDANCE

## ព័ត៌មានទីផ្សារការងារនៅកម្ពុជា
## Labor Market Information in Cambodia

## ព័ត៌មានទីផ្សារការងារ
## Labor Market Information

## ស្ថានភាពទីផ្សារការងារនៅកម្ពុជា
## Labor Market in Cambodia

## ព័ត៌មានជ្រើសរើសបុគ្គលិក
## Job Vacancies

រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

# មាតិកា


ទំព័រ

- បុព្វកថា ១
- អារម្ភកថា ៣
- គណៈកម្មាធិការជាតិបណ្តុះបណ្តាល (គ. ជ. ប. ប) ៤
- អំពីទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) ៩
  - សេវារបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ១១
  - មជ្ឈមណ្ឌលការងារ (ម. ក) ១២
- មគ្គុទេសក៍អាជីព ១៥
- ព័ត៌មានទីផ្សារការងារ ១៩
  - ព័ត៌មានទីផ្សារការងារនៅកម្ពុជា ២២
- ស្ថានភាពទីផ្សារការងារនៅកម្ពុជា ២៨
  - អ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក និងវគ្គអប់រំបណ្តុះបណ្តាលដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ៣៩
- បច្ចុប្បន្នភាពនៃវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៤៤
- ព័ត៌មានជ្រើសរើសបុគ្គលិក ៥៦
- ដៃគូសហការសំខាន់ៗ ៧១
- ទម្រង់ចុះឈ្មោះអ្នកស្វែងរកការងារធ្វើ និយោជក និង អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ៧៣


















# បុព្វកថា



ទីផ្សារការងារនៃព្រះរាជាណាចក្រកម្ពុជាបានឈានចូលរបត់ថ្មីមួយ ក្នុងពេលដែលសេដ្ឋកិច្ចជាតិកំពុងងើបឡើងវិញពីឥទ្ធិពលអវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងមានការប្រែប្រួលក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ដោយសារកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងអត្រាជាមធ្យមជិតពីរខ្ទង់ក្នុងមួយឆ្នាំ បន្ទាប់ពីកម្ពុជាទទួលបាននូវសន្តិភាព ស្ថិរភាព និងឯកភាពជាតិពេញលេញនៅក្នុងឆ្នាំ១៩៩៨ ក្រោមនយោបាយ "**ឈ្នះ-ឈ្នះ**" របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះ ទីផ្សារការងារនៅកម្ពុជា នាពេលបច្ចុប្បន្នកំពុងទទួលរងនូវឥទ្ធិពលកាន់តែខ្លាំងឡើងពីការប្រកួតប្រជែងកាន់តែតឹងតែងដោយសារចរន្តដ៏លឿន នៃតំបន់នីយកម្ម និងសកលូបនីយកម្ម ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ការទាមទារនូវជំនាញកាន់តែខ្ពស់ឡើងនៅក្នុងសេដ្ឋកិច្ចជាតិ ព្រមជាមួយនឹងការកើនឡើងនូវកម្លាំងពលកម្មក្នុងស្រុកដែលមានវ័យក្មេង និងការហូរចេញកម្លាំងពលកម្មពីតំបន់ជនបទទៅកាន់ទីក្រុង។ ស្ថានភាពនេះ ទាមទារឱ្យទីផ្សារការងារមានលក្ខណៈងាយបត់បែននិងដំណើរការល្អប្រសើរ ព្រមជាមួយនឹងការផ្តល់ការគាំទ្រដល់ការបង្កើតការងារ ការអភិវឌ្ឍជំនាញរបស់កម្លាំងពលកម្ម ការបង្កើនគុណភាពនិងកែលម្អលក្ខខណ្ឌការងារ។

ស្ថាប័នផ្តល់សេវាការងារនិងព័ត៌មានទីផ្សារការងារសាធារណៈ គឺជាអន្តរការីយ៉ាងសំខាន់ដែលដើរតួនាទីក្នុងការសម្របសម្រួលដំណើរការទីផ្សារការងារនៅក្នុងភាពជាដៃគូជាមួយអ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងភាគីពាក់ព័ន្ធនានាក្នុងទីផ្សារការងារ។ បន្ថែមលើនេះ ស្ថាប័ននេះមានតួនាទីក្នុងការប៉ាន់ស្មាន និងព្យាករណ៍អំពីតម្រូវការនិងការផ្គត់ផ្គង់ជំនាញ ដើម្បីធ្វើអត្តសញ្ញាណកម្មនូវជំនាញនិងសមត្ថភាពដែលត្រូវការក្នុងពេលអនាគត។ ព័ត៌មានទីផ្សារការងារទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ភាគីទាំងអស់នៅក្នុងទីផ្សារការងារ ព្រមទាំងអ្នកផ្តល់ការបណ្តុះបណ្តាលជំនាញនិងសមត្ថភាព និងអ្នករៀបចំគោលនយោបាយ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំគោលនយោបាយប្រកបដោយភាពត្រឹមត្រូវដែលនឹងជួយធានាឱ្យទីផ្សារការងារមានដំណើរការល្អប្រសើរ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននិងកំពុងផ្តោតការយកចិត្តទុកដាក់ជាខ្លាំងក្នុងការអភិវឌ្ឍវិស័យការងារ ដូចដែលបានលើកឡើងក្នុង "**យុទ្ធសាស្ត្រចតុកោណ**" ដើម្បី***កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*** នៅកម្ពុជា **ដំណាក់កាលទី២** ព្រមទាំង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣**។ ក្នុងគោលនយោបាយទាំងនេះ រាជរដ្ឋាភិបាលចាត់ទុកការកែលម្អឱ្យប្រសើរឡើងនូវដំណើរការនិងប្រសិទ្ធភាពទីផ្សារការងារ និងការផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍជំនាញរបស់កម្លាំងពលកម្ម ជាកត្តាចាំបាច់ក្នុងការទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស ការស្រូបយកបច្ចេកវិទ្យា ការបង្កើតការច្នៃប្រឌិតថ្មី និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ដែលនាំឱ្យមានការបង្កើនផលិតភាពនិងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចជាតិ ការបង្កើតនិងផ្តល់ឱកាសការងារ ការលើកកម្ពស់កម្រិតជីវភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចព្រមទាំងការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព។ ស្របតាមស្មារតីនេះ ***គណៈកម្មាធិការជាតិបណ្តុះបណ្តាល*** ដែលជាស្ថាប័នត្រីភាគីថ្នាក់ជាតិក្រោមការដឹកនាំរបស់ខ្ញុំ ដោយមានតំណាងមកពីគ្រប់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និយោជក សហជីព និងអង្គការមិនមែនរដ្ឋាភិបាលបាននិងកំពុងដើរតួនាទីដ៏សំខាន់ក្នុងការសម្របសម្រួល រៀបចំនិងត្រួតពិនិត្យការអនុវត្តផែនការនិងគោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យបានឆ្លើយតបតាមតម្រូវការទីផ្សារការងារ ដើម្បីធានាឱ្យមានការបន្សុីគ្នាកាន់តែប្រសើរឡើងរវាងការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម។ ដើម្បីជាយន្តការចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅនេះ គណៈកម្មាធិការជាតិបណ្តុះបណ្តាលបានបង្កើត***ទីភ្នាក់ងារជាតិមុខរបរ និងការងារ*** នៅក្នុងឆ្នាំ២០០៩ ដែលមានតួនាទីក្នុងការផ្តល់សេវាការងារជាសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្នុងគោលបំណងផ្តល់ការគាំទ្រ និងសម្របសម្រួលដល់អ្នកស្វែងរកការងារធ្វើ និងនិយោជក ព្រមទាំងផ្តល់ភាពងាយស្រួល កាត់បន្ថយចំណាយ និងពេលវេលាក្នុងទីផ្សារការងារ។ បន្ថែមលើនេះ នៅក្នុងឆ្នាំ២០១០ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវបានរាជរដ្ឋាភិបាលផ្តល់តួនាទីបន្ថែមជា –

*"អង្គភាពស្ថិតិដែលបានចាត់តាំង"* ដែលទទួលបន្ទុកក្នុងការប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយនូវព័ត៌មានទីផ្សារការងារជាសាធារណៈ នៅមួយកន្លែងងាយស្រួលតាមប្រព័ន្ធអេឡិចត្រូនិច ឬក្នុងទម្រង់ក្រដាស សម្រាប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់ជាមុខចូលក្នុងការសម្រេចចិត្ត ព្រមទាំងរៀបចំផែនការនិងគោលនយោបាយសមស្រប សំដៅធ្វើឱ្យប្រសើរឡើងនូវដំណើរការនិងប្រសិទ្ធភាពទីផ្សារការងារ។

*«ព្រឹត្តិបត្រការងារ»* នេះគឺជាសមិទ្ធផលមួយនៃកិច្ចខិតខំប្រឹងប្រែងខាងលើ ដែលត្រូវបានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយប្រចាំខែ ដោយទីភ្នាក់ងារជាតិមុខរបរនិងការងារ ដើម្បីផ្តល់ជូនភាគីពាក់ព័ន្ធក្នុងទីផ្សារការងារនូវព័ត៌មានទីផ្សារការងារនៅកម្ពុជា ជាពិសេសព័ត៌មានស្តីពីការផ្គត់ផ្គង់និងតម្រូវការកម្លាំងពលកម្មក្នុងពេលបច្ចុប្បន្ន និងការប៉ាន់ស្មានក្នុងពេលអនាគត ព្រមជាមួយនឹងព័ត៌មានគោលនយោបាយ កម្មវិធីនិងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ និងការងារ។ ដើម្បីផ្តល់ជាជំនួយគាំទ្រដល់សិស្ស និស្សិត និងយុវជនក្នុងការរៀបចំផែនការអាជីព និងការធ្វើអន្តរកម្មដោយរលូនពីគ្រឹះស្ថានសិក្សាចូលទៅក្នុងទីផ្សារការងារ ព្រឹត្តិបត្រការងារនេះ នឹងផ្តល់ជូនផងដែរនូវចំណេះដឹងនិងបទពិសោធន៍ល្អៗស្តីពីមគ្គទេសក៍និងការណែនាំផ្នែកអាជីព ការបណ្តុះបណ្តាល វិជ្ជាជីវៈ និងការងារ ។ ព្រឹត្តិបត្រនេះ នឹងក្លាយជាវេទិកាដ៏ងាយស្រួល និងប្រកបដោយប្រសិទ្ធភាពមួយផងដែរសម្រាប់និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះ–បណ្តាលធ្វើការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធសំខាន់ៗនៅមួយកន្លែងងាយស្រួល។ លើសពីនេះ ខ្ញុំសង្ឃឹមថាក្នុងពេលអនាគត ព្រឹត្តិបត្រនេះនឹងបន្ថែមនូវការផ្សព្វផ្សាយអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងទីផ្សារ និងគោលនយោបាយការងារ ដើម្បីឱ្យក្លាយជាប្រភពព័ត៌មានទីផ្សារការងារដ៏សំខាន់មួយនៅកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃទីភ្នាក់ងារជាតិមុខរបរ និងការងារក្នុងការផ្តួចផ្តើមរៀបចំចងក្រង និងបោះពុម្ពផ្សាយនូវព្រឹត្តិបត្រការងារដ៏មានសារៈប្រយោជន៍នេះឡើង ព្រមទាំងថ្លែងអំណរគុណដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមចំណែក និងផ្តល់ការគាំទ្រក្នុងការរៀបចំព្រឹត្តិបត្រនេះ។ ខ្ញុំសង្ឃឹមជឿជាក់ថាព្រឹត្តិបត្រនេះនឹងទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីភាគីពាក់ព័ន្ធនានានៅក្នុងទីផ្សារការងារ និងសាធារណៈជនទូទៅ ព្រមទាំងចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវដំណើរការនិងប្រសិទ្ធភាព និងការអភិវឌ្ឍទីផ្សារការងារនៅព្រះរាជាណាចក្រកម្ពុជា។ ៚

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និង ជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

**បណ្ឌិតសភាចារ្យ សុខ អាន**

គណៈកម្មាធិការជាតិបណ្តុះបណ្តាល

រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០១១

# អារម្ភកថា



ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវ ***«ព្រឹត្តិបត្រការងារ»*** លេខទី១ នៃឆ្នាំទី១ ឆ្នាំ២០១១ ដែលត្រូវបានរៀបចំ និងបោះពុម្ពផ្សាយជាសាធារណៈលើកដំបូងដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីផ្តល់នូវព័ត៌មានទីផ្សារការងារទាំងកម្រិតម៉ាក្រូ និងកម្រិតមីក្រូ ដល់អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នករៀបចំផែនការនិងគោលនយោបាយ ព្រមទាំងសាធារណជនទូទៅ។ ព្រឹត្តិបត្រនេះ មានរួមបញ្ចូលផងដែរនូវមគ្គុទេសក៍ និងការណែនាំស្តីពីអាជីព ការបណ្តុះបណ្តាល និងការងារ ដើម្បីជាជំនួយដល់សិស្ស និស្សិត និងយុវជនក្នុងការរៀបចំផែនការអាជីព និងការធ្វើអន្តរកម្មដោយរលូនពីគ្រឹះស្ថានសិក្សាចូលទៅក្នុងទីផ្សារការងារ។ លើសពីនេះ ព្រឹត្តិបត្រការងារនេះផ្តល់ជូនផងដែរនូវព័ត៌មានស្តីពីកម្មវិធី វគ្គនិងការឧបត្ថម្ភនានា ព្រមទាំងស្ថានភាពទូទៅ វិវឌ្ឍនាការថ្មីៗ គោលនយោបាយ ផែនការ នីតិវិធី និងក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនឹងវិស័យអប់រំ-បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការងារ។ តាមរយៈព្រឹត្តិបត្រនេះ អ្នកស្វែងរកការងារធ្វើ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះ- បណ្តាលក៏ត្រូវបានផ្តល់ឱកាសផងដែរក្នុងការធ្វើការចុះឈ្មោះស្វែងរកការងារធ្វើ និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិក និងវគ្គអប់រំបណ្តុះបណ្តាលដោយឥតគិតថ្លៃនៅមួយកន្លែងដោយងាយស្រួល និងគ្របដណ្តប់លើវិសាលភាពទូលំទូលាយ។

ក្នុងបរិការណ៍នៃសកលូបនីយកម្មនិងការរីកចម្រើនផ្នែកបច្ចេកវិទ្យាយ៉ាងលឿន ការផ្តល់ព័ត៌មានទីផ្សារការងារបានគ្រប់គ្រាន់ និងទាន់ពេលវេលា ជាការចាំបាច់សម្រាប់ភាគីពាក់ព័ន្ធនៅក្នុងទីផ្សារការងារក្នុងការឆ្លើយតបបានឆាប់រហ័សនិងដោយចំណាយទាបដែលជួយកាត់បន្ថយនូវហានិភ័យនៃការកើតឡើងនូវគម្លាតក្នុងការផ្គត់ផ្គង់និងតម្រូវការជំនាញ និងភាពគ្មានការងារធ្វើក្នុងរយៈពេលយូរ។

ខ្ញុំមានការសង្ឃឹមជឿជាក់ថា ព្រឹត្តិបត្រការងារនេះនឹងក្លាយជាប្រភពព័ត៌មានទីផ្សារការងារដ៏សំខាន់មួយ ឆ្លើយតបទៅនឹងតម្រូវ-ការក្នុងពេលបច្ចុប្បន្នរបស់អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នករៀបចំផែនការ និងគោលនយោបាយ សិស្ស និស្សិត មាតាបិតា និងសាធារណជនទូទៅ ក្នុងការស្វែងរកការងារធ្វើ ការជ្រើសរើសបុគ្គលិក ការរៀបចំផែនការអាជីព ការអភិវឌ្ឍ-ជំនាញ និងការអប់រំបណ្តុះបណ្តាល ព្រមជាមួយនឹងការរៀបចំគោលនយោបាយទីផ្សារការងារ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះក្រុមការងារនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ ក្នុងការ-ផ្តួចផ្តើមរៀបចំចងក្រង និងបោះពុម្ពផ្សាយនូវព្រឹត្តិបត្រការងារដ៏មានសារៈប្រយោជន៍នេះឡើង ហើយខ្ញុំមានជំនឿយ៉ាងមុតមាំថាក្រុមការងារនេះនឹងបន្តខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវ ប្រមូលចងក្រងនូវព័ត៌មានពាក់ព័ន្ធនឹងទីផ្សារការងារឱ្យកាន់តែទូលំទូលាយ និងស៊ីជម្រៅ ព្រមទាំងចំណេះដឹងនិងបទពិសោធន៍អន្តរជាតិល្អៗសម្រាប់ធ្វើការផ្សព្វផ្សាយក្នុងលេខបន្តបន្ទាប់នៃព្រឹត្តិបត្រការងារនេះ ដើម្បីឱ្យព្រឹត្តិបត្រនេះ ចូលរួមចំណែកកាន់តែប្រសើរឡើងក្នុងការអភិវឌ្ឍទីផ្សារការងារនៅព្រះរាជាណាចក្រកម្ពុជា។៚

**រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**និង ជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល**

**ពេជ សោភ័ន**

គណៈកម្មាធិការជាតិបណ្តុះបណ្តាល

រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០១១

# គណៈកម្មាធិការជាតិបណ្តុះបណ្តាល ( គ.ជ.ប.ប )

# National Training Board

វិស័យអប់រំត្រូវបានចាត់ទុកជាយន្តការគន្លឹះដ៏សំខាន់មួយក្នុងការអភិវឌ្ឍធនធានមនុស្ស។ ម្យ៉ាងវិញទៀត ការទទួលបានការអប់រំដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាពក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការអភិវឌ្ឍវិស័យការងារ ព្រមទាំងវិស័យដ៏ទៃទៀតផងដែរ។ **«ការទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា»** ដូចដែលមានកំណត់នៅក្នុង គោលដៅអភិវឌ្ឍសហស្សវត្សរបស់អង្គការសហប្រជាជាតិ និងគោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា គឺពិតជាបានចែងយ៉ាងច្បាស់អំពីតួនាទី និងសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលទៅដល់មនុស្សគ្រប់ៗរូប។ យ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ បានផ្តោតការយកចិត្តទុកដាក់ យ៉ាងខ្លាំងចំពោះការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងជាពិសេសវិស័យអប់រំនៅកម្ពុជា។ ជាក់ស្តែងនៅក្នុង **«យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី២»** ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** ដែលជារបៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅត្រង់ចតុកោណយុទ្ធសាស្រ្តទីបួន បានចែងពីការកសាងសមត្ថភាព និងការអភិវឌ្ឍ ធនធានមនុស្ស ហើយដែលជាពិសេសនៅត្រង់មុំយុទ្ធសាស្រ្តទី១ បានចែងពីការពង្រឹងគុណភាពវិស័យអប់រំ។ ម្យ៉ាងវិញទៀត **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ** ២០០៩-២០១៣ ក៏ជាយុទ្ធសាស្រ្តគោល និងជាត្រីវិស័យដែលបម្រើឱ្យគោលនយោបាយអភិវឌ្ឍន៍ប្រទេសដើម្បីឈានឆ្ពោះទៅកាន់ភាពរីកចំរើនជឿនលឿន និងដើម្បីប្រជារាស្រ្តទទួលបានជីវភាពសម្បូរធូរធារ។

## ក. ការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងសម្រេចឱ្យបានជោគជ័យនូវគោលនយោបាយខាងលើនេះរាជរដ្ឋាភិបាលបានបង្កើត **គណៈកម្មាធិការជាតិបណ្តុះបណ្តាល** (គ. ជ. ប. ប) តាមរយៈអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដែលមានតួនាទី និងភារកិច្ចធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន និងទៅអនាគតនៅកម្ពុជា។ យោងតាមអនុក្រឹត្យនេះ គ. ជ. ប. ប មានភារកិច្ចអនុវត្តឱ្យសម្រេចនូវកិច្ចការ និងគោលដៅសំខាន់ៗរួមមាន៖

- រៀបចំគោលនយោបាយ និងគម្រោងផែនការជាតិសម្រាប់អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- សម្របសម្រួល និងតម្រង់ទិសការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។
- លើកគម្រោងកែទំរង់ និងអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យក្លាយជាប្រព័ន្ធមួយដែល៖
    - មានគុណភាព និងប្រសិទ្ធភាពខ្ពស់
    - ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍជាតិ
    - ឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ។ល។
    - មានទំនាក់ទំនងរវាងកន្លែងធ្វើការងារ និងគ្រឹះស្ថានបណ្តុះបណ្តាល

## ខ. រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល

គ. ជ. ប. ប បំពេញភារកិច្ចក្នុងទំរង់ជាគណៈកម្មាធិការគ្រប់គ្រងដែលរចនាសម្ព័ន្ធរបស់ស្ថាប័ននេះត្រូវបានបែងចែកជា គណៈកម្មាធិការប្រតិបត្តិដែលគ្រប់គ្រងទៅលើ អនុគណៈកម្មាធិការចំនួនបី រួមមាន អនុគណៈកម្មាធិការស្តង់ដារជាតិសមត្ថភាព និងធ្វើតេស្ត អនុគណៈកម្មាធិការទទួលស្គាល់វគ្គកម្មវិធីនិងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងអនុគណៈកម្មាធិការព័ត៌មានទីផ្សារការងារ។ គ. ជ. ប. ប ក៏មានសេនាធិការពីរផងដែរគឺទីភ្នាក់ងារជាតិមុខរបរ និងការងារ និងលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រៅពីនេះ នៅមានក្រុមការងារជំនាញមួយចំនួនទៀតគឺ៖ ក្រុមវាយតម្លៃសមត្ថភាពឯករាជ្យតាមជំនាញ ក្រុមការងារធានាគុណភាព/អធិការកិច្ចគុណភាពអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាឧស្សាហកម្មតាមផ្នែក/ជំនាញផ្សេងៗ (រូបទី១)។


តទៅទំព័របន្ទាប់

រូបទី១: រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល




**គ. សមាសភាពគណៈដឹកនាំរបស់ គ. ជ. ប. ប**

គ. ជ. ប. ប ត្រូវបានបង្កើតឡើងដោយមានរួមបញ្ចូលនូវសមាសភាពគណៈដឹកនាំចំរុះដែលមានតំណាងមកពីបណ្តាក្រសួង ស្ថាប័ន អង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាល និយោជក និយោជិត អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដែលស្ថិតនៅក្រោមការដឹកនាំដោយផ្ទាល់របស់ ឯក**ឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី។ សមាសភាពទាំងអស់នៃ គ. ជ. ប. ប មានដូចខាងក្រោម៖

តារាងទី១: សមាសភាពរបស់ គណៈកម្មាធិការជាតិបណ្តុះបណ្តាល

| *ល.រ* | *តំណាងរបស់ក្រសួង ស្ថាប័ន និងអង្គភាព* | *តួនាទី* |
|---|---|---|
| ១ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២ | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣ | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | អនុប្រធាន |
| ៤ | តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥ | តំណាងនិយោជក | អនុប្រធាន |
| ៦ | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

តនៅទំព័របន្ទាប់

| | | |
|---|---|---|
| ៧ | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨ | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៩ | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០ | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១ | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១២ | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១៣ | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១៤ | តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១៥ | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦ | តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៧ | តំណាងក្រសួងផែនការ | សមាជិក |
| ១៨ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩ | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ២០ | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១ | តំណាង ៤រូប របស់និយោជក | សមាជិក |
| ២២ | តំណាង ១រូប របស់សភាពាណិជ្ជកម្ម | សមាជិក |
| ២៣ | តំណាង ២រូប របស់និយោជិត | សមាជិក |
| ២៤ | តំណាង ៣រូប របស់អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល | សមាជិក |
| ២៥ | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ |
| ២៦ | តំណាងទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ២៧ | តំណាង ២រូបរបស់អង្គការអន្តរជាតិ | សមាជិក |

ការតែងតាំងសមាសភាពនៃគណៈកម្មធិការជាតិបណ្តុះបបណ្តាលត្រូវបានធ្វើឡើងដោយអនុក្រឹត្យលេខ ១០៦៦ អនក្រ. តត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពនៃ គ. ជ. ប. ប និងអនុក្រឹត្យដែលត្រូវបានចេញបន្តបន្ទាប់ដោយរាជរដ្ឋាភិបាលដែលមានរាយនាម ព្រមទាំងមុខងារ និងឈ្មោះក្រសួង ស្ថាប័ន អង្គភាព ដូចខាងក្រោម៖

**តារាងទី២: សមាសភាពគណៈដឹកនាំនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល**

| | | | | |
|---|---|---|---|---|
| ១ | ឯ.ឧ | **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២ | ឯ.ឧ | **ពេជ សោភ័ន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣ | ឯ.ឧ | **ហាវ ប៊ុនសៃ** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | អនុប្រធាន |
| ៤ | ឯ.ឧ | **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥ | ឯ.ឧ | **សុន សុគន្ធ** | ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា | អនុប្រធាន |
| ៦ | លោក | **វ៉ាន់ ស៊ូអៀង** | ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា តំណាងនិយោជក | អនុប្រធាន |
| ៧ | ឯ.ឧ | **ឌិក ប៊ុង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨ | ឯ.ឧ | **ឡា ណារ៉ាត** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៩ | ឯ.ឧ | **សំ ព្រហ្មនា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០ | ឯ.ឧ | **ងី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១ | ឯ.ឧ | **អ៊ឹង កុសល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |


តទៅទំព័របន្ទាប់

| | | | | |
|---|---|---|---|---|
| ១២ | ឯ.ឧ | គឹម ទូច | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៣ | ឯ.ឧ | មាស ម៉ូនីកា | អនុរដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១៤ | ឯ.ឧ | ហាក់ សុខមករា | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៥ | ឯ.ឧ | វង្ស សាម៉ុន | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៦ | ឯ.ឧ | លាភ វណ្ណដេន | អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៧ | ឯ.ឧ | អ៊ុំ សុផល | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រសួងសុខាភិបាល | សមាជិក |
| ១៨ | ឯ.ឧ | ស៊ូ សុវុធ | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានអប់រំព័ត៌មាន និងផ្សព្វផ្សាយ ក្រសួងបរិស្ថាន | សមាជិក |
| ១៩ | លោក | ឡាយ សំអូន | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២០ | ល.ស្រី | ឡុង និមល | អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គមក្រសួងកិច្ចការនារី | សមាជិក |
| ២១ | លោក | លាភ សំណាង | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២២ | លោក | ហង្ស បូ | ប្រធានគណនេយ្យ និងហិរញ្ញវត្ថុ ក្រុមហ៊ុនម៉ុងឫទ្ធីគ្រុប តំណាងនិយោជក | សមាជិក |
| ២៣ | លោក | គង់ សាង | អនុប្រធានទី១ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា តំណាងនិយោជក | សមាជិក |
| ២៤ | លោក | លូ ម៉េង | ប្រធានសមាគមសណ្ឋាគារកម្ពុជា តំណាងនិយោជក | សមាជិក |
| ២៥ | លោក | ហេង ហ៊ាង | អនុប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ប្រធានសមាគមឧស្សាហកម្មខ្នាតតូច និងមធ្យម តំណាងនិយោជក | សមាជិក |
| ២៦ | ឯ.ឧ | ងួន ម៉េងតិច | អគ្គនាយកសភាពាណិជ្ជកម្ម | សមាជិក |
| ២៧ | លោក | ជួន មុំថុល | ប្រធានសហព័ន្ធសហជីពខ្មែរ និងជាអនុប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា តំណាងនិយោជិត | សមាជិក |
| ២៨ | លោក | សោម អូន | ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា តំណាងនិយោជិត | សមាជិក |
| ២៩ | ឯ.ឧ | ប៊ុន ភារិន | នាយកវិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា តំណាងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល | សមាជិក |
| ៣០ | ល.ស្រី | ដួង វ៉ាន់ដេត | នាយិកាវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង តំណាងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល | សមាជិក |
| ៣១ | លោក | ស៊ុយ ផេង | នាយកសាលាបច្ចេកទេសដុនបូស្កូភ្នំពេញថ្មី តំណាងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល | សមាជិក |
| ៣២ | ឯ.ឧ | ឡៅ ហ៊ីម | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ |
| ៣៣ | លោក | ឌី សមស៊ីដេត | អ្នកឯកទេសអប់រំ និវាសដ្ឋាន បេសកកម្មប្រចាំកម្ពុជានៃធនាគារអភិវឌ្ឍន៍អាស៊ី តំណាងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល | សមាជិក |
| ៣៤ | លោក | ទុន សោភ័ណ | មន្ត្រីសម្របសម្រួលថ្នាក់ជាតិប្រចាំប្រទេសកម្ពុជា នៃអង្គការពលកម្មអន្តរជាតិ តំណាងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល | សមាជិក |
| ៣៥ | លោក | ពិន សារពេជ្ជ | នាយកកម្មវិធីអង្គការដើម្បីភាពញញឹមនៃកុមារ តំណាងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល | សមាជិក |
| ៣៦ | ឯ.ឧ | ហុង ជឿន | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |

តទៅទំព័របន្ទាប់

## ឃ. សកម្មភាពសំខាន់ៗដែលស្ថិតក្រោមការអនុវត្តរបស់ គ. ជ. ប. ប

ចាប់តាំងពីត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៥ គ. ជ. ប. ប បានបំពេញភារកិច្ច និងសម្រេចបាននូវស្នាដៃជាច្រើនដោយគិតចាប់ពីការយកចិត្តទុកដាក់ក្នុងការរក្សាបាននូវកិច្ចប្រតិបត្តិការដោយរលូននៅក្នុងស្ថាប័ន និងរចនាសម្ព័ន្ធការងារ រហូតដល់ការអនុវត្តបានដ៏មានប្រសិទ្ធភាពទៅតាមទិសដៅការងារសំខាន់ៗដូចមានកំណត់នៅក្នុងតួនាទី និងភារកិច្ចដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលតាមរយៈអនុក្រឹត្យ ជាពិសេស ពាក់ព័ន្ធទៅនឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាក់ស្តែង បន្ទាប់ពីការចូលជាធរមាននៃការប្រគល់តួនាទី និងភារកិច្ចរបស់ខ្លួន គ. ជ. ប. ប បានរៀបចំអនុវត្តនូវគម្រោងអភិវឌ្ឍន៍ជាច្រើនតាមរយៈអនុគណៈកម្មាធិការ និងសេនាធិការ និងក្រុមការងាររបស់ខ្លួនមានដូចជា៖ គម្រោងអភិវឌ្ឍវិស័យអប់រំទី ១ និងទី២ (ESDP I & II) ផែនការជាតិអភិវឌ្ឍន៍ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផែនការអភិវឌ្ឍន៍ធនធានមនុស្សដើម្បីអភិវឌ្ឍន៍ការងារ និងមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ (VSTP) ដែលបានអនុវត្តនៅតាមបណ្តាខេត្ត-ក្រុងនានា មូលនិធិជាតិបណ្តុះបណ្តាល (NTF) និងមូលនិធិបង្កើតមុខរបរដោយខ្លួនឯង (SEGF) ជាដើម។ បន្ថែមពីលើនេះ គ. ជ. ប. ប ថែមទាំងបានបង្កើត **ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ. ជ. ម. ក)** ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកព័ត៌មានទីផ្សារការងារ និងការជួយស្វែងរកការងារធ្វើដល់ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្មដែលរួមមានសិស្ស-និស្សិតទើបបញ្ចប់ការសិក្សា ព្រមទាំងអ្នកស្វែងរកការងារធ្វើ និងសាធារណជនទូទៅ។ នេះគឺជាការរួមចំណែកដោយផ្ទាល់ និងដោយប្រយោលចំពោះការអភិវឌ្ឍវិស័យអប់រំ–បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានន័យថាជាការធានានូវគុណភាព ប្រសិទ្ធិភាព និងនិរន្តរភាពនៃការអភិវឌ្ឍវិស័យអប់រំ អាស្រ័យដោយមានការតម្រង់ទិស និងផ្តល់ឱកាសដោយត្រង់ទៅដល់ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្មដែលត្រូវបានផលិតនៅក្នុងបរិបទនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងជាពិសេសដែលស្ថិតនៅក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងអភិវឌ្ឍវិស័យអប់រំស្របតាមគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងដែលស្ថិតក្រោមប្រតិបត្តិការដោយផ្ទាល់ពីសំណាក់ គ. ជ. ប. ប៕



*កិច្ចប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាលលើកទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល។ (រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១)*

**អាសយដ្ឋានរបស់ គណៈកម្មាធិការជាតិបណ្តុះបណ្តាល**

ស្ថិតនៅក្នុង ទីស្តីការគណៈរដ្ឋមន្ត្រី វិមានសន្តិភាព អគារលេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី

ទូរស័ព្ទ ០២៣ ៨៨២ ៤៣០ ទូរសារ ០២៣ ៨៨២ ៩០១

គេហទំព័រ http://www.ntb.gov.kh/

*អត្ថបទដោយ ទ.ជ.ម.ក (ដកស្រង់ និងយោងពីខ្លឹមសារនៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើត គ. ជ. ប. ប និងអនុក្រឹត្យលេខ ១០៦៦ អនក្រ. តត ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពនៃ គ. ជ. ប. ប ព្រមទាំងព័ត៌មាន និងឯកសារផ្សេងៗដែល មាននៅលើគេហទំព័ររបស់ គ. ជ. ប. ប)។*

# អំពីទីភ្នាក់ងារជាតិមុខរបរ និងការងារ ABOUT National Employment Agency

ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) (National Employment Agency–NEA) ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ក្រោមទម្រង់ជាទីភ្នាក់ងារប្រតិបត្តិការពិសេស (Special Operating Agency-SOA) គឺជាទីភ្នាក់ងារជាតិ ដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិបណ្តុះបណ្តាលដែលមានឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជាប្រធាន និងដែលមានតួនាទី និងភារកិច្ចក្នុងការផ្តល់សេវាការងារ (Employment Services) និងព័ត៌មានទីផ្សារការងារ (Labour Market Information) ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ និងដោយឥតគិតថ្លៃជូនដល់អ្នកស្វែងរកការងារធ្វើ និយោជិត និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នករៀបចំគោលនយោបាយ និងផែនការ និងសាធារណជនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទ.ជ.ម.ក ផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារតាមរយៈជម្រើសដោយងាយស្រួលចំនួន២ គឺ៖ តាមរយៈមជ្ឈមណ្ឌលការងារ និងនៅលើប្រព័ន្ធអ៊ីនធើណិតតាមរយៈគេហទំព័រ www.nea.gov.kh។

បន្ថែមទៅលើតួនាទី និងភារកិច្ចខាងលើនេះ ទ.ជ.ម.ក ក៏ត្រូវបានរាជរដ្ឋាភិបាលកំណត់ផងដែរជាអង្គភាពស្ថិតិដែលបានចាត់តាំងរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល តាមរយៈអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារ ដែលជាផ្នែកមួយរបស់ប្រព័ន្ធស្ថិតិជាតិ និងមានតួនាទី និងភារកិច្ចក្នុងការប្រមូល វិភាគ ចងក្រង និងផ្សព្វផ្សាយនូវព័ត៌មានទីផ្សារការងារជាសាធារណៈនៅមួយកន្លែងងាយស្រួលតាមប្រព័ន្ធអេឡិចត្រូនិច និងក្នុងទម្រង់ក្រដាសសម្រាប់បម្រើដល់តម្រូវការព័ត៌មានពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងទីផ្សារការងារ និងសាធារណជនទូទៅ។

ដើម្បីសម្រេចបានដោយជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់នូវតួនាទីភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនខាងលើនេះ ចំពោះការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ ទ.ជ.ម.ក បានរៀបចំផែនការ ការងាររយៈពេល៣ឆ្នាំរបស់ខ្លួន(ឆ្នាំ២០១១-២០១៣) ដែលកំណត់យ៉ាងច្បាស់លាស់អំពីចក្ខុវិស័យរួមមួយ ព្រមទាំងបេសកកម្មធំៗចំនួនពីរ និងទិសដៅអនុវត្តជាអាទិភាពចំនួនបី ដូចខាងក្រោម៖

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ ទ.ជ.ម.ក ក្នុងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារគឺ៖

*"រួមចំណែកក្នុងការសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារការងារ បង្កើនការចូលរួមក្នុងទីផ្សារការងារ កាត់បន្ថយនិកម្មភាព ជំរុញកំណើននិងភាពនុវត្តភាព និងជាយថាហេតុជួយកាត់បន្ថយភាពក្រីក្រ"* ។

## បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ទ.ជ.ម.ក មានបេសកកម្មដូចខាងក្រោម៖

- ផ្តល់សេវាការងារជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាពដូចជា ការផ្គូផ្គងគ្នារវាងអ្នកស្វែងរកការងារធ្វើ និងកន្លែងការងារទំនេរ ដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារការងារ
- ប្រមូលព័ត៌មាន វិភាគ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារដើម្បីជាមូលដ្ឋានគ្រឹះក្នុងការផ្តល់សេវាការងារប្រកបដោយប្រសិទ្ធភាព និងផ្តល់ព័ត៌មាន ទៅដល់អ្នករៀបចំគោលនយោបាយក្នុងការផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញ និងការអភិវឌ្ឍកម្មវិធីសិក្សា។

## ទិសដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មខាងលើ ទ.ជ.ម.ក មានទិសដៅសម្រាប់រយៈពេលបីឆ្នាំ ទៅមុខ (២០១១-២០១៣)ដូចខាងក្រោម៖

- អភិវឌ្ឍ និងផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ ដោយឈរលើមូលដ្ឋានតម្រូវការរបស់អ្នកប្រើប្រាស់សេវា
- ការបង្កើនការយល់ដឹងជាសាធារណៈ និងការអភិវឌ្ឍព័ត៌មានទីផ្សារការងារ
- ការអភិវឌ្ឍធនធានមនុស្ស ៕

តទៅទំព័របន្ទាប់

# រចនាសម្ព័ន្ធរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ

រចនាសម្ព័ន្ធរបស់ទ.ជ.ម.ក ចែកចេញជាពីរផ្នែកសំខាន់ៗគឺៈ ផ្នែកគ្រប់គ្រង និងទ្រទ្រង់ការផ្ដល់សេវា (Back Office) និងផ្នែកផ្ដល់សេវាជួរមុខ (Front Office)។ ផ្នែកគ្រប់គ្រង និងគាំទ្រការផ្ដល់សេវា គឺសំដៅទៅលើផ្នែកស្នូលទាំងបួនរបស់ ទ.ជ.ម.ក ដែលរួមមានៈ ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ផ្នែកផែនការ និងសហប្រតិបត្តិការ ផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន និងផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន។

ចំពោះផ្នែកផ្ដល់សេវាជួរមុខ (Front Office) គឺជាមជ្ឈមណ្ឌលការងារដែលធ្វើការផ្ដល់សេវាដោយផ្ទាល់ដល់អ្នកប្រើប្រាស់សេវា ហើយដែលនឹងត្រូវបានបង្កើតនៅគ្រប់រាជធានី ខេត្ត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីនាំយកសេវាឱ្យកាន់តែខិតទៅជិតអ្នកប្រើប្រាស់សេវានៅមូលដ្ឋាន និងគ្របដណ្ដប់បានទូលំទូលាយ ។ ទ.ជ.ម.ក ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ដូចមានបង្ហាញក្នុងរូបខាងក្រោមៈ



*កិច្ចប្រជុំបូកសរុបការងារ និងរបាយការណ៍ប្រចាំឆ្នាំ និងទិសដៅអនុវត្តផែនការការងារឆ្នាំបន្ទាប់ ក្រោមអធិបតីភាព **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ (រូបទី៤ ពីខាងឆ្វេង) ដែលបានប្រារព្ធឡើងនៅទីស្នាក់ការកណ្ដាលរបស់ ទ.ជ.ម.ក ដោយមានការចូលរួមពីមន្ត្រី និងបុគ្គលិកគ្រប់ផ្នែកដែលស្ថិតនៅក្រោមឱវាទ។ (ខែមីនា ឆ្នាំ២០១១)*

រូបទី២: អង្គការលេខរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ






តទៅទំព័របន្ទាប់

# ការផ្ដល់សេវា Services provided by NEA
## របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ទ.ជ.ម.ក ផ្ដល់សេវាការងារ និងព័ត៌មានទីផ្សារការងារដល់អ្នកប្រើប្រាស់សេវាទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដោយឥតគិតថ្លៃ និងនៅមួយកន្លែងងាយស្រួលតាមរយៈជម្រើសពីរគឺ៖

- សេវាលើប្រព័ន្ធអ៊ីនធើរណិត តាមរយៈគេហទំព័រ ដែលមានឈ្មោះ www.nea.gov.kh ។
- សេវាតាមរយៈមជ្ឈមណ្ឌលការងារ ដែលនឹងត្រូវបង្កើតនៅទូទាំង ២៤ រាជធានី ខេត្ត។

សេវាដែលមានផ្ដល់ជូនរួមមានដូចតទៅនេះ

### សេវាសម្រាប់អ្នកស្វែងរកការងារធ្វើ

- ការចុះឈ្មោះស្វែងរកការងារធ្វើ និងផ្សព្វផ្សាយប្រវត្តិរូបសង្ខេប (CV) នៅលើគេហទំព័រ ឬនៅមជ្ឈមណ្ឌលការងាររបស់ ទ.ជ.ម.ក
- ការទទួលបានព័ត៌មានអំពីតម្រូវការជ្រើសរើសបុគ្គលិក និងការបណ្ដុះបណ្ដាលអភិវឌ្ឍន៍ជំនាញ
- ការជួយស្វែងរកការងារធ្វើ និងផ្គូផ្គងជាមួយតម្រូវការជ្រើសរើសបុគ្គលិក
- ការជួយបញ្ជូនប្រវត្តិរូបសង្ខេបទៅនិយោជក
- ការទទួលបានការណែនាំអំពីអាជីព ការរៀបចំខ្លួនសម្រាប់ឈានចូលទីផ្សារការងារ ឱកាសការងារ និងការវាយតម្លៃអំពីលទ្ធភាពទទួលបានការងារ
- ការទទួលបាននូវព័ត៌មានទីផ្សារការងារទូទៅ។




### សេវាសម្រាប់និយោជក

- ការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិកនៅលើគេហទំព័រ ឬព្រឹត្តិបត្រការងារ ឬនៅតាមមជ្ឈមណ្ឌលការងារ
- ការផ្ដល់មូលដ្ឋានទិន្នន័យរបស់អ្នកស្វែងរកការងារធ្វើ
- ការបញ្ជូនបេក្ខជនដែលបានជ្រើសសម្រាំង
- ការផ្ដល់ទីតាំងការិយាល័យសម្រាប់ជ្រើសរើសបុគ្គលិក
- ការចុះជួបនិយោជកផ្ទាល់ដើម្បីប្រមូលព័ត៌មានជ្រើសរើសបុគ្គលិក
- ការទទួលបានការណែនាំអំពីការជ្រើសរើសបុគ្គលិក
- ការទទួលបានព័ត៌មានបណ្ដុះបណ្ដាលសម្រាប់បង្កើនជំនាញសមស្របដល់បុគ្គលិក
- ការទទួលបាននូវព័ត៌មានទីផ្សារការងារទូទៅ។



### សេវាសម្រាប់អ្នកផ្ដល់ការអប់រំបណ្ដុះបណ្ដាល

- ផ្សព្វផ្សាយនូវកម្មវិធី និងវគ្គអប់រំបណ្ដុះបណ្ដាល នៅលើគេហទំព័រ ឬព្រឹត្តិបត្រការងារ ឬនៅតាមមជ្ឈមណ្ឌល ការងារ
- ការផ្ដល់ការណែនាំពីការស្វែងរកការងារធ្វើ និងកន្លែងចុះកម្មសិក្សា
- ការផ្ដល់ព័ត៌មានទីផ្សារការងារ ដើម្បីអភិវឌ្ឍ និងរៀបចំកម្មវិធីអប់រំបណ្ដុះបណ្ដាលសមស្របតាមតម្រូវការ
- ការទទួលបាននូវព័ត៌មានទីផ្សារការងារទូទៅ។






*មន្ត្រីមជ្ឈមណ្ឌលការងារ (ម.ក) របស់ ទ.ជ.ម.ក កំពុងពន្យល់អំពីការប្រើប្រាស់សេវា និងការបញ្ចូលព័ត៌មាន (ប្រវត្តិរូបសង្ខេប) របស់អ្នកស្វែងរកការងារធ្វើទៅក្នុងប្រព័ន្ធកុំព្យូទ័រ និងបង្ហោះតាមប្រព័ន្ធអ៊ិនធើរណិត។ (ម.ក ខែកុម្ភៈ ឆ្នាំ ២០១១)*



*និយោជកនៃក្រុមហ៊ុន Panasonic កំពុងធ្វើការសម្ភាសន៍ដល់អ្នកស្វែងរកការងារធ្វើនៅក្នុង ម.ក ជាទីកន្លែងដែលផ្ដល់ដោយ ទ.ជ.ម.ក សម្រាប់និយោជក ឬក្រុមហ៊ុនណាមួយដែលមិនមានទីកន្លែងដើម្បីសម្ភាសន៍។ (ម.ក ភ្នំពេញ ខែតុលា ឆ្នាំ ២០១០)*

តទៅទំព័របន្ទាប់

# មជ្ឈមណ្ឌលការងារ (ម.ក)

ទ.ជ.ម.ក មានមជ្ឈមណ្ឌលការងារ (ម.ក) ដែលជាការិយាល័យផ្តល់សេវាជួរមុខ (Front Office) សម្រាប់ផ្តល់សេវាដោយផ្ទាល់ដល់អ្នកប្រើប្រាស់សេវា ហើយនឹងត្រូវបានបង្កើតជាជំហានៗតាមរាជធានីខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើនេះទៀត ទ.ជ.ម.ក នឹងបង្កើត ម.ក មួយដែលមានទីតាំងនៅក្នុងអគារទីស្នាក់ការកណ្តាលរបស់ខ្លួន និងស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ប្រធាន ទ.ជ.ម.ក ជាគំរូសម្រាប់ផ្តល់សេវាដល់អ្នកប្រើប្រាស់សេវា ជាពិសេសសម្រាប់ការផ្តល់សេវាជ្រើសរើសបុគ្គលិកដែលមានជំនាញខ្ពស់ និងសម្រាប់ជាគំរូក្នុងការអភិវឌ្ឍ ម.ក ដទៃទៀត។ ជាទូទៅ ម.ក នីមួយៗមានក្រុមការងារផ្តល់នូវបណ្តុំសេវាជាមូលដ្ឋានចំនួនបី និងក្រុមការងារគាំទ្រការផ្តល់សេវា ចំនួនមួយរួមមាន៖ ក្រុមការងារសេវាអ៊ីនធើណេត ក្រុមការងារសេវាបណ្ណាល័យ ក្រុមការងារសេវាណែនាំ ក្រុមការងាររដ្ឋបាល និងហិរញ្ញវត្ថុ។

ប៉ុន្តែ ម.ក នីមួយៗអាចកែប្រែ និងរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនបន្ថែម ដើម្បីផ្តល់សេវាសមស្របទៅតាមតម្រូវការ អ្នកប្រើប្រាស់សេវា និងចរិតលក្ខណៈទីផ្សារការងារ និងសង្គមសេដ្ឋកិច្ចនៅក្នុងមូលដ្ឋានរបស់ខ្លួន។

រូបទី៣: លំហូរនៃការផ្តល់សេវានៅមជ្ឈមណ្ឌលការងាររបស់ ទ.ជ.ម.ក



លំហូរនៃការផ្តល់សេវានៅតាម ម.ក នីមួយៗមានបង្ហាញជូននៅក្នុងរូបទី៣ ខាងដើម។ ជារួមក្នុងការប្រើប្រាស់សេវារបស់ម.ក អ្នកប្រើប្រាស់សេវា (អ្នកស្វែងរកការងារធ្វើ និយោជក និងភាគីពាក់ព័ន្ធផ្សេងៗទៀត) អាចជ្រើសរើសការប្រើប្រាស់សេវាតាមប្រព័ន្ធអ៊ីនធើរណិត ដោយមិនចាំបាច់ធ្វើដំណើរមកកាន់ ម.ក ឬជ្រើសរើស ការប្រើប្រាស់សេវាដោយធ្វើដំណើរមកកាន់ ម.ក ណាមួយដោយផ្ទាល់អាស្រ័យទៅតាមកម្រិតយល់ដឹង និងតម្រូវការរបស់អ្នកប្រើប្រាស់សេវា។

ចំពោះអ្នកប្រើប្រាស់សេវាដែលធ្វើដំណើរមកកាន់ ម.ក ដោយផ្ទាល់ ពេលចូលមកដល់កន្លែងផ្តល់ព័ត៌មាននឹងត្រូវបានកំណត់អំពីជម្រើសសេវាដែលអាចប្រើ។ អ្នកប្រើប្រាស់សេវាដែលមានចំណេះដឹងក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធើរណិត និងមានការអប់រំមធ្យមឡើងទៅអាចត្រូវបានណែនាំទៅកាន់ផ្នែកសេវាបម្រើដោយខ្លួនឯង។ រីឯអ្នកប្រើប្រាស់សេវាដែលមិនចេះប្រើប្រាស់ប្រព័ន្ធអ៊ីនធើរណិត និងមានការអប់រំទាប អាចត្រូវបានណែនាំទៅ កាន់ផ្នែកសេវាមានជំនួយពីមន្ត្រីរបស់ ម.ក ។

បច្ចុប្បន្ននេះ មជ្ឈមណ្ឌលការងាររបស់ ទ.ជ.ម.ក មានស្ថិតនៅក្នុងបួនទីតាំងផ្សេងគ្នាគឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងកំពត។ ម.ក នីមួយៗ មានមន្ត្រីរង់ចាំទទួលបម្រើសេវាកម្មដល់អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងមហាជនទូទៅដែលមានកំណត់នៅក្នុងកម្មវិធីនៃម៉ោងធ្វើការដូចខាងក្រោម៖

| ម៉ោងធ្វើការរបស់មជ្ឈមណ្ឌលការងារ៖ | | | |
|---|---|---|---|
| ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ | | ថ្ងៃសៅរ៍ | |
| ពេលព្រឹកម៉ោង | ៧:៣០ ដល់ ១១:៣០ | ពេលព្រឹកម៉ោង | ៩:០០ ដល់ ១១:៣០ |
| ពេលល្ងាចម៉ោង | ១៣:៣០ ដល់ ១៧:៣០ | ពេលល្ងាចម៉ោង | ១៥:៣០ ដល់ ១៥:០០ |



*អគារទីស្នាក់ការកណ្តាលរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលបច្ចុប្បន្នគឺជាទីស្នាក់ការកណ្តាលផង និងជាមជ្ឈមណ្ឌលការងារផង។ (ខែមិថុនា ឆ្នាំ ២០១១)*



***សេវាបណ្ណាល័យ៖*** *នៅគ្រប់មជ្ឈមណ្ឌលការងារ មានបំពាក់ទៅដោយ* ***បណ្ណាល័យការងារ*** *ដែលមានផ្ទុកនូវឯកសារ និងសៀវភៅសំខាន់ៗពាក់ព័ន្ធនឹងវិស័យការងារ មុខរបរ អាជីព និងស្ថិតិ ។ល។ អ្នកស្វែងរកការងារធ្វើ និយោជក និងសាធារណជនអាចប្រើប្រាស់បណ្ណាល័យទាំងនេះដោយឥតគិតថ្លៃ និងនៅគ្រប់ពេលម៉ោងធ្វើការ។*



*មជ្ឈមណ្ឌលការងារ ក៏មានមន្ត្រីបម្រើសេវាផ្នែកណែនាំផ្តល់យោបល់ទៅដល់អ្នកស្វែងរកការងារធ្វើស្តីពីចំណុចសំខាន់ៗដូចជា វិធីសរសេរនិងរៀបចំ CV ការត្រៀមខ្លួនទៅចូលសម្ភាសន៍ ឥរិយាបថនៅពេលសម្ភាសន៍ វិធីនៃការឆ្លើយសំនួរ ជាដើម។ ក្នុងរូបនេះមន្ត្រី ម.ក ភ្នំពេញកំពុងពន្យល់ក្រុមអ្នកស្វែងរកការងារធ្វើ។*

តទៅទំព័របន្ទាប់

# អាសយដ្ឋានរបស់មជ្ឈមណ្ឌលការងារ

អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងមហាជនទូទៅដែលមានបំណងប្រើប្រាស់ ឬទទួលបានសេវាពីមជ្ឈមណ្ឌលការងាររបស់ ទ.ជ.ម.ក សូមទំនាក់ទំនង ឬអញ្ជើញមកកាន់មជ្ឈមណ្ឌលការងារណាមួយដែលស្ថិតនៅជិតលោកអ្នកបំផុតដែលមានអាសយដ្ឋានដូចខាងក្រោម៖

## មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ

វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទ: ០២៣ ៦៣៣ ៦០០២
០៧៧ ២៣២ ៣៧៨
០១៦ ៦៦៧ ៨១២
អ៊ីម៉ែល: jc_pp@nea.gov.kh

## មជ្ឈមណ្ឌលការងារខេត្តសៀមរាប

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប
សង្កាត់ស្លក្រាម ក្រុងសៀមរាប
ទូរសព្ទ: ០៦៣ ៩៦៩ ៣៩៦
អ៊ីម៉ែល: jc_siemreap@nea.gov.kh







## មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង

វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង ផ្លូវលេខ០១
ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ទូរសព្ទ: ០៥៣ ៩៥៣ ៥៨០
អ៊ីម៉ែល: jc_battambang@nea.gov.kh

## មជ្ឈមណ្ឌលការងារខេត្តកំពត

វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត
ភូមិ០១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត
ទូរសព្ទ: ០៣៣ ៩៣២ ១២២
អ៊ីម៉ែល: jc_kampot@nea.gov.kh






# អំពីប្រភេទនៃបុគ្គលិកលក្ខណៈ*

## ១. សេចក្តីផ្តើម

ជាធម្មតាមនុស្សគ្រប់រូបតែងត្រូវការចំណាយពេលវេលា កម្លាំងកាយ កម្លាំងចិត្ត យ៉ាងច្រើនសម្រាប់បំពេញការងាររបស់ខ្លួន។ ប្រការសំខាន់ជាងនេះទៅទៀតគឺត្រូវស្វែងយល់ឱ្យបានជិតដល់បន្ថែមថា តើការងារដែលខ្លួនកំពុងតែបំពេញបានផ្តល់លទ្ធផល និងការចាប់អារម្មណ៍កម្រិតណាដល់ខ្លួនឯង។ ពោលដោយខ្លី តើអ្នកពេញចិត្តនឹងការងារនោះដែរឬទេ? ឆ្លងតាមបទពិសោធន៍នៃការស្រាវជ្រាវ និងបទពិសោធន៍របស់អ្នកធ្វើការបានបង្ហាញឱ្យដឹងថា ″មនុស្សម្នាក់អាចនឹងពេញចិត្តជាមួយការងារមួយ ឬផ្ទុយមកវិញការងារមួយអាចបំពេញចិត្តមនុស្សម្នាក់ គឺអាស្រ័យទៅលើភាពជក់ចិត្តចាប់អារម្មណ៍ក្នុងការទទួលបំពេញកិច្ចការនោះ ហើយក៏ត្រូវពិនិត្យមើលផងដែរទៅលើលទ្ធភាពនានាដែលការងារនោះអាចផ្តល់ឱកាស ឬក៏ជម្រើសជាក់លាក់អ្វីមួយដែលបង្កភាពសប្បាយរីករាយដល់អ្នកបំពេញការងារ″។ ពោលដោយខ្លីម្យ៉ាងទៀត គឺគ្មានការងារណាដែលអាចទទួលបានជោគជ័យទេ ប្រសិនបើគ្មានការជក់ចិត្ត។ ម្យ៉ាងវិញទៀតគេត្រូវកំណត់ក្នុងចិត្តថាការចូលចិត្តចាប់អារម្មណ៍ ឬសេចក្តីរីករាយរបស់បុគ្គលម្នាក់ចំពោះការងារណាមួយនោះ គឺមិនមែនមានន័យថាការងារនោះនឹងបំពេញចិត្ត ផ្តល់ការចាប់អារម្មណ៍ ឬបង្កភាពសប្បាយរីករាយដល់មនុស្សគ្រប់ៗគ្នានោះទេ។

អាស្រ័យហេតុនេះពាក្យថា *″ការងារ″ ″បុគ្គល″ ″ចំណូលចិត្ត″ ″ចំណាប់អារម្មណ៍″ ″ភាពសប្បាយរីករាយ″ ″ភាពជោគជ័យ″* ជាដើម គឺជាកត្តាដែលកំណត់ដោយបុគ្គលិកលក្ខណៈរបស់បុគ្គលរៀងៗខ្លួន ព្រមទាំងរួមបញ្ចូលនូវលទ្ធភាពអាចបំពេញការងារ សមត្ថភាព ការអប់រំបណ្តុះបណ្តាល សារជាតិរបស់ការងារដែលតម្រូវឱ្យមានជម្រើសខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ផ្សេងទៀត ពីប្រភេទការងារមួយទៅប្រភេទការងារមួយទៀត។ ដូចបានលើកឡើងមកនេះ តើត្រូវធ្វើដូចម្តេចទើបអាចបញ្ជាក់បានពីភាពសមស្របរវាងបុគ្គលណាម្នាក់ទៅនឹងការងារណាមួយ?

ចម្លើយទៅនឹងសំនួរខាងលើនេះហាក់មិនមានអ្វីស្មុគស្មាញទេ គឺថាបុគ្គលឯកជនម្នាក់ត្រូវតែស្វែងយល់ អំពីបុគ្គលិកលក្ខណៈ ចំណូលចិត្ត ជំនាញ និងចំណាប់អារម្មណ៍របស់ខ្លួនឱ្យបានច្បាស់លាស់ជាមុនសិន មុននឹងចាប់ផ្តើម សម្រេចចិត្តជ្រើសរើសការងារជាអាជីពណាមួយ។ តើត្រូវធ្វើយ៉ាងដូចម្តេចទើបអាចវាស់ស្ទង់ ឬស្វែងយល់អំពីចំណុចទាំងឡាយ ដូចបានរៀបរាប់ខាងលើ? ចម្លើយចំពោះសំនួរនេះ និងដើម្បីស្វែងយល់អំពីជម្រើសដ៏ត្រឹមត្រូវសម្រាប់អាជីពក្នុងពេលអនាគតណាមួយ នឹងមានបរិយាយជូនទៅតាមហេតុ និងសេចក្តីដែលមានជាលំដាប់លំដោយដូចខាងក្រោម៖

## ២. ប្រភេទនៃបុគ្គលិកលក្ខណៈ

ភាពខុសប្លែកគ្នានៃបុគ្គលិកលក្ខណៈ គឺជាអ្វីដែលធម្មជាតិបានបែងចែក និងកំណត់ភាពផ្សេងគ្នារបស់មនុស្សម្នាក់ៗ ឬមនុស្សមួយក្រុម។ ឧទាហរណ៍ អ្នកខ្លះចូលចិត្តជួបនិយាយជាមួយមនុស្សប្លែកៗ អ្នកខ្លះពូកែគិតបានលម្អិតអំពីរឿងផ្សេងៗ អ្នកខ្លះមានភាពវាងវៃក្នុងការរៀបចំគម្រោងនិងផែនការនានា អ្នកខ្លះទៀតអាចសម្របខ្លួនទៅនឹងគ្រប់ស្ថានភាពបានយ៉ាងប្រសើរ -ល- ប្រភេទនៃបុគ្គលិកលក្ខណៈក៏ជាមធ្យោបាយសម្រាប់បង្ហាញថាតើបុគ្គលម្នាក់ៗចូលចិត្តអ្វី? មានទំនោរបែបណា និងតម្រង់ទិសខ្លួនឯងទៅខាងណា? ហើយដោះស្រាយបញ្ហាជុំវិញខ្លួនយ៉ាងដូចម្តេច?

មានការសិក្សាជាច្រើនបានបង្ហាញព័ត៌មានអំពីប្រភេទនៃបុគ្គលិកលក្ខណៈនីមួយៗដែលមានឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការជ្រើសរើសមុខរបរ និងការងារដែលមនុស្សម្នាក់ៗចូលចិត្ត។ ដូច្នេះការស្វែងយល់អំពីប្រភេទនៃបុគ្គលិកលក្ខណៈរបស់យើងម្នាក់ៗគឺជាកត្តាសំខាន់ ដើម្បីជាប្រយោជន៍ឱ្យយើងអាចជ្រើសរើសការងារដែលខ្លួនពេញចិត្ត និងសមស្របទៅតាមបរិយាកាសសង្គម។ ការស្គាល់ពីប្រភេទនៃបុគ្គលិកលក្ខណៈរបស់អ្នក អាចជួយឱ្យអ្នកតម្រង់ទិសចំណង់ចំណូលចិត្តផ្ទាល់ខ្លួនក្នុងទិសដៅត្រឹមត្រូវ។ ដូច្នេះជាដំបូង អ្នកត្រូវកំណត់ពីផ្លូវ ឬអត្តចរិតដែលអ្នកចង់ប្រកាន់យក និងចង់តម្រង់ទិសខ្លួនឯងទៅកាន់ពិភពខាងក្រៅ ឬ «ពិភពការងារ»។ យោងតាមបទពិសោធន៍ និងការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញផ្នែកអាជីព ឬអ្នកផ្តល់ប្រឹក្សាផ្នែកអាជីព ដែលបានត្រួសត្រាយនិងបកស្រាយពន្យល់ដោយចងក្រងជាឯកសារ បញ្ជាក់ថាមធ្យោបាយសម្រាប់ការអង្កេតអំពីប្រភេទនៃបុគ្គលិក លក្ខណៈរបស់មនុស្សទាំងពួង ដើម្បីតម្រង់ផ្លូវតម្រូវសេចក្តីទៅនឹងបរិបទការងារនានាត្រូវបានគេបែងចែកជាបួនក្រុមដោយផ្តុំសេចក្តីទៅតាមគោលសំខាន់ៗនៃប្រ--ភេទរបស់បុគ្គល ឬមនុស្សទាំងឡាយដែលនឹងបង្ហាញជូនតាមរបៀបរៀបជាសេចក្តីដូចមានពណ៌នានៅផ្នែកខាងក្រោម។

## ៣. ការពន្យល់អំពីរបៀបជ្រើសរើសប្រភេទនៃបុគ្គលិកលក្ខណៈទាំងបួនក្រុម

សេចក្តីពន្យល់បកស្រាយអំពីប្រភេទនៃបុគ្គលិកលក្ខណៈទាំងបួនក្រុមមានគោលបំណងបង្ហាញដល់អ្នកអានទូទៅ ក៏ដូចជាលោកអ្នកដែលកំពុងស្ថិតក្នុងដំណាក់កាលនៃការស្វែងរកការងារធ្វើ ហើយមានបំណងចង់ស្វែងយល់អំពីបុគ្គលិកលក្ខណៈរបស់ខ្លួន ថាតើបុគ្គលិកលក្ខណៈផ្ទាល់របស់លោកអ្នកមានភាពសមស្រប ឬត្រូវគ្នាទៅនឹងចំណុចណាមួយ ដើម្បីតម្រូវខ្លួនទៅនឹងបរិយាកាសការងារ ឬប្រភេទការងារដែលលោកអ្នកចង់បំពេញ ឬកំពុងស្វះស្វែងរក។ ការពន្យល់នេះគឺជាមូលដ្ឋានគ្រឹះដំបូងបំផុតសម្រាប់ជួយលោកអ្នកឱ្យស្វែងយល់ពីខ្លួនឯង មុននឹងឈានទៅដល់ការកំណត់យកការងារដែលខ្លួនចូលចិត្ត ស្វែងរកការងារដែលមានភាពស៊ីសង្វាក់ជាមួយខ្លួនឯង ឬក៏សម្របខ្លួនទៅនឹងការងារដែលកំពុងតែបំពេញ។ ម្យ៉ាងទៀត ការពន្យល់អំពីប្រភេទនៃបុគ្គលិកលក្ខណៈនេះ គឺមិនមែនបញ្ចប់ដោយឡែកតែត្រឹមបួនក្រុមនោះទេ ប៉ុន្តែនឹងមានយោង ឬភ្ជាប់សេចក្តីទៅដល់ខ្លឹមសារផ្សេងៗទៀតដែលណែនាំ–

តទៅទំព័របន្ទាប់

ទាក់ទងទៅនឹងអាជីព ឬការស្វែងរកការងារធ្វើ នាពេលក្រោយៗទៀត។

ប្រភេទនៃបុគ្គលិកលក្ខណៈទាំងបួនក្រុមត្រូវបានរៀបចំបែងចែកដាក់ក្នុងតារាង ឬប្រអប់បួនដោយឡែកៗពីគ្នា។ យ៉ាងណាមិញ នៅក្នុងក្រុមនីមួយៗមានរួមបញ្ចូលនូវប្រភេទនៃបុគ្គលិកលក្ខណៈតូចៗពីរដែលមានទម្រង់ជាការប្រៀបធៀបគ្នា ឧទាហរណ៍ ក្នុងបុគ្គលិកលក្ខណៈក្រុមទី១ មានបុគ្គលិកលក្ខណៈឈ្មោះ EXTRAVERSION តាងដោយអក្សរឡាតាំង (E) និងមួយទៀតឈ្មោះ INTROVERSION តាងដោយអក្សរឡាតាំង (I)។ ហេតុដែលមិនប្រែអត្ថន័យនៃឈ្មោះ ឬពាក្យទាំងនេះជាភាសាខ្មែរ គឺអ្នករៀបចំអត្ថបទមានបំណងរក្សាទុកឈ្មោះដើមនៃភាសាបរទេស ដើម្បីងាយធ្វើការផ្ទៀងផ្ទាត់ឈ្មោះនៃបុគ្គលិកលក្ខណៈនីមួយៗនាជំណាក់កាលក្រោយៗទៀតដោយប្រើត្រឹមតែអក្សរបំពេញ (ឧទាហរណ៍ EXTRAVERSION = E)។ ជាជំនួស ពាក្យបរទេសទាំងនេះនឹងមានពន្យល់ខ្លឹមសារបន្ថែមដោយឡែកដើម្បីឱ្យអ្នកអានងាយយល់សេចក្តី។

ដូច្នេះ បន្ទាប់ពីលោកអ្នកបានអានសេចក្តីសង្ខេតពីប្រភេទនៃបុគ្គលិកលក្ខណៈនីមួយៗរួចរាល់ហើយ នៅក្នុងក្រុមនីមួយៗសូមជ្រើសរើសយកតែបុគ្គលិកលក្ខណៈណាមួយក្នុងចំណោមបុគ្គលិកលក្ខណៈតូចពីរ ដែលលោកអ្នកយល់ថាវាមានភាពសមស្របភាគច្រើនទៅនឹងចរិតលក្ខណៈផ្ទាល់ខ្លួនរបស់លោកអ្នក។ ឧទាហរណ៍ ក្នុងបុគ្គលិកលក្ខណៈក្រុមទីមួយ ចរិតលក្ខណៈរបស់លោកអ្នកត្រូវគ្នាខ្លាំងនឹងប្រភេទ EXTRAVERSION ដូច្នេះសូមជ្រើសយកប្រភេទនេះដោយគូសសម្គាល់នៅត្រង់ប្រអប់ដែលមាននៅភាគខាងក្រោមនៃតារាងនីមួយៗ(ឧទាហរណ៍: ☑ E : E X T R A V E R S I O N ក្រុមទីពីរ ☑ I:INTUITION ជាដើម)។ បន្ទាប់មក សូមបន្តអាន និងអនុវត្តរបៀបដូចគ្នានេះចំពោះប្រភេទនៃបុគ្គលិកលក្ខណៈទាំងបួនក្រុម។ តាមរយៈវិធីយ៉ាងដូច្នេះលោកអ្នកនឹងអាចស្វែងរកឃើញពីបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនដោយខ្លួនឯង។ បន្ទាប់ពីគូសកំណត់ប្រភេទនៃបុគ្គលិកលក្ខណៈបានទាំងបួនក្រុមរួចហើយសូមរក្សាទុក ឬកត់ចំណាំអក្សរឡាតាំងទាំងបួនដែលលោកអ្នកបានជ្រើសយកថាមានសភាពត្រឹមត្រូវគ្នាខ្លាំងជាមួយចរិតលក្ខណៈរបស់លោកអ្នក ដើម្បីទុកប្រើប្រាស់ក្នុងការវាស់ស្ទង់នាពេលក្រោយ (ឧទាហរណ៍ បុគ្គល «ក» បានអានប្រភេទនៃបុគ្គលិកលក្ខណៈទាំងបួនក្រុមរួចរាល់ហើយបានជ្រើសរើសពីក្រុមនីមួយៗនូវអក្សរតំណាង «ESFP» ដូច្នេះអក្សរឡាតាំងទាំងបួនគឺបញ្ជាក់ពីបុគ្គលិកលក្ខណៈរបស់បុគ្គល «ក») ដូចមានសេចក្តីបកស្រាយនៅក្នុងក្រុមនីមួយៗ។

## ៤. បុគ្គលិកលក្ខណៈទាំង ៤ក្រុម

### បុគ្គលិកលក្ខណៈក្រុមទី១

| ***E: EXTRAVERSION***<br>*ជាបុគ្គលសកម្ម មានទំនុកចិត្ត ចូលរួមរីករាយជាមួយអ្នកដទៃ។ បុគ្គលប្រភេទនេះមានទំនោរទៅរកៈ* | ***I: INTROVERSION***<br>*ជាបុគ្គលស្ងៀមស្ងាត់ អៀនប្រៀន មិនចូលចិត្ត ឬមិនសូវចូលរួមរីករាយជាមួយអ្នកដទៃ។ បុគ្គលប្រភេទនេះមានទំនោរទៅរកៈ* |
|---|---|
| • ផ្តោតលើការប្រើប្រាស់ថាមពល និងព័ត៌មានដែលទទួលបានពីខាងក្រៅដោយសម្តែងចេញជាមតិយោបល់ និងធ្វើសកម្មភាព។<br>• មិនចូលចិត្តភាពសាំញ៉ាំ អាចពុះពារធ្វើកិច្ចការអ្វីមួយបានយូរអង្វែងជាពិសេស ប្រសិនបើជាការងារដែលគេត្រូវតែបំពេញដោយខកខានមិនបាន។<br>• រៀនសូត្រ និងបំពេញកិច្ចការបានល្អល្អះនៅពេលដែលអាចចែករំលែកយោបល់ ពិភាក្សា និងផ្តល់ព័ត៌មានទៅវិញទៅមកជាមួយមនុស្សដទៃ។<br>• មានសំណួរ និងរិះគិតដោយចំហរបែបភ្លៀវភ្លានៅក្នុង សកម្មភាពផ្សេងៗ ឬខណៈពេលមានការសម្រេចចិត្តលើកិច្ចការអ្វីមួយ។<br>• យល់ច្បាស់អំពីស្ថានភាពផ្ទាល់ខ្លួនដែលកំពុងតែប្រព្រឹត្តដោយសម្តែងចេញជាសកម្មភាព ឬនិយាយចេញមកក្រៅ។ | • ផ្តោតលើការប្រើប្រាស់ថាមពល និងព័ត៌មានដែលទទួលបានពីខាងក្រៅដោយការពិចារណាយ៉ាងហ្មត់ចត់និងជ្រៅជ្រះ មុននឹងសម្រេចចិត្តបំពេញកិច្ចការអ្វីមួយ។<br>• ចូលចិត្តធ្វើការនៅទីកន្លែងស្ងប់ស្ងាត់ ហើយពុះពារធ្វើកិច្ចការអ្វីមួយបានយូរអង្វែង។<br>• រៀនសូត្រ និងបំពេញកិច្ចការល្អល្អះដោយត្រូវការពេលវេលាកំណត់ណាមួយដើម្បីស្វែងយល់ និងទទួលបានព័ត៌មានជាក់លាក់ដោយខ្លួនឯង។<br>• ជាប្រភេទមនុស្សគិតមុននិយាយ ឬគិតមុនធ្វើសកម្មភាព។ គេអាចមិនសូវមានទំនុកចិត្តចំពោះខ្លួនឯង នៅពេលដែលតម្រូវឱ្យបង្ហាញពីសមត្ថភាព ឬឆ្លើយតបទៅតាមសេចក្តីត្រូវការអ្វីមួយ។<br>• ទម្លាក់តម្លៃចំពោះចំណុចខ្លាំងរបស់ខ្លួនក្នុងមជ្ឈដ្ឋានជុំវិញ ដោយទាញហេតុផលថាសមត្ថភាពរបស់ខ្លួនអាចត្រូវបានគេវាយតម្លៃទាប។ |

មនុស្សគ្រប់រូបប្រើប្រាស់វិធី ឬមធ្យោបាយបែប EXTRAVERSION និង INTROVERSION ក្នុងសកម្មភាពប្រចាំថ្ងៃ។ យ៉ាងណាមិញមនុស្សម្នាក់ៗតែងមានជម្រើសបែបធម្មជាតិ និងមានភាពសមស្របបំផុតសម្រាប់ខ្លួនទៅនឹងចំណុចណាមួយក្នុងចំណោមចំណុចទាំងពីរខាងលើ។ ហេតុនេះ សូមជ្រើសយកចំណុចណាមួយដែលអ្នកគិតថាសមស្របខ្លាំងទៅនឹងបុគ្គលិកលក្ខណៈផ្ទាល់របស់អ្នកៈ

☐ ***E: EXTRAVERSION*** ☐ ***I: INTROVERSION***


តទៅទំព័របន្ទាប់

## បុគ្គលិកលក្ខណៈក្រុមទី២

| ***S: SENSING***<br>*ជាជំពូកបុគ្គលដែលផ្តោតការយកចិត្តទុកដាក់ចំពោះតែកិច្ចការអនុវត្តជាក់ស្តែង និងទៅលើភាពល្អិតល្អន់នៃកិច្ចការនោះ។ បុគ្គលប្រភេទនេះមានទំនោរទៅរកៈ* | ***N: INTUITION***<br>*ផ្តោតការយកចិត្តទុកដាក់ដល់ភាពអរូបីយ៍ចំពោះការគិតគូរបង្ហាញគំនិត និងលទ្ធភាពដែលអាចធ្វើបាន។ បុគ្គលប្រភេទនេះមានទំនោរទៅរកៈ* |
|---|---|
| • ផ្តោតចំពោះការពិតដោយឡែកៗពីគ្នា និងភាពល្អិតល្អន់របស់វា មុនពេលមើលទៅដល់រូបភាពសំខាន់ទាំងមូល និងគំនិតរួមរបស់ហេតុផលនោះ។<br>• មានចំណាប់អារម្មណ៍ខ្លាំងទៅនឹងហេតុការណ៍ពិត នៅពេលដែលបានដឹងអំពីហេតុអ្វីមួយជាក់ច្បាស់។<br>• ចូលចិត្តព័ត៌មាន និងកិច្ចការណាដែលមានការរៀបចំបានល្អប្រសើរ ហើយបានរៀបបង្ហាញទៅតាមលំដាប់លំដោយនៃទម្រង់អ្វីមួយ។<br>• ធ្វើការងារដោយមានស្ថិរភាពនៅក្នុងកម្រិតកំណត់មួយ។<br>• អាចអស់ភាពអត់ធ្មត់ ឬបារម្ភជាមួយកិច្ចការស្មុគស្មាញ និងការងារដែលតម្រង់ទិសទៅអនាគតដែលត្រូវបំពេញក្នុងរយៈពេលយូរអង្វែង។<br>• ចូលចិត្តប្រើប្រាស់អារម្មណ៍លាយឡំជាមួយកិច្ចការងារ។ | • ផ្តោតចំពោះការចង់ដឹងលើចំណុចថាតើការពិតទាំងឡាយមានន័យយ៉ាងដូចម្តេច ហើយវាត្រូវរួមបញ្ចូលគ្នាបែបណា។ ច្រើនគិតអំពី ន័យធៀបនៃវត្ថុ ឬហេតុអ្វីមួយ ភាពដែលអាចធ្វើបាន ព្រមទាំងទំនាក់ទំនងរវាងគំនិតនានាជាជាងគិតអំពីការពិត និងភាពល្អិតល្អន់ផ្សេងៗតែមួយមុខ។<br>• ក្លាយជាធុញថប់ និងគ្មានការអត់ធ្មត់ចំពោះការស្វែងយល់ពីភាពល្អិតល្អន់នានា ជក់ចិត្តខ្លាំងតែជាមួយរឿងធំទាំងមូល។<br>• ចូលចិត្តដោះស្រាយបញ្ហា និងអភិវឌ្ឍជំនាញថ្មីៗ ប៉ុន្តែងាយ នឹងធុញទ្រាន់ជាមួយការងារបែបដដែលៗជាប្រចាំថ្ងៃ។<br>• ធ្វើការ និងរៀនសូត្រតែក្នុងរវាងក្របខណ្ឌដែលត្រូវគិត និងការងារដែលត្រូវបំពេញ ទំនងជាមានសន្ទុះថាមពលតែមួយពេលខ្លីជាជាងភាពរឹងប៉ឹងយូរអង្វែងក្នុងការបំពេញការងារ។ |

មនុស្សគ្រប់រូបប្រើប្រាស់វិធី ឬមធ្យោបាយបែប SENSING និង INTUITION ក្នុងសកម្មភាពប្រចាំថ្ងៃ។ យ៉ាងណាមិញមនុស្សម្នាក់ៗ តែងមានជម្រើសបែបធម្មជាតិ និងមានភាពសមស្របបំផុតសម្រាប់ខ្លួនទៅនឹងចំណុចណាមួយក្នុងចំណោមចំណុចទាំងពីរខាងលើ។ ហេតុនេះសូមជ្រើសយកចំណុចណាមួយដែលអ្នកគិតថាសមស្របខ្លាំងទៅនឹងបុគ្គលិកលក្ខណៈផ្ទាល់របស់អ្នកៈ

☐ ***S: SENSING*** ☐ ***S: INTUITION***

## បុគ្គលិកលក្ខណៈក្រុមទី៣

| ***T: THINKING***<br>*ផ្តោតខ្លាំងតែចំពោះហេតុផលសមរម្យពិតប្រាកដ និងការវិភាគ។ បុគ្គលប្រភេទនេះមានទំនោរទៅរកៈ* | ***F: FEELING***<br>*ផ្តោតចំពោះគុណតម្លៃផ្ទាល់របស់ខ្លួន និងភាពប្រែប្រួលទាំងឡាយ។ បុគ្គលប្រភេទនេះមានទំនោរទៅរកៈ* |
|---|---|
| • ផ្តោតចំពោះហេតុផលសមរម្យពិតប្រាកដ និងការវិភាគអំពីមូលហេតុ<br>• អាចដោះស្រាយបញ្ហាបានល្អប្រសិនមានទិន្នន័យជាគោល និង ទំនាក់ទំនងនានារបស់ហេតុផល។<br>• ពិចារណាពីផលល្អ និងផលអាក្រក់របស់គំនិត ព័ត៌មាននិងការយល់ឃើញអំពីអ្វីមួយ។<br>• យល់បានអំពីអារម្មណ៍ និងការទទួលដឹងបានដោយល្អនៅពេលពន្យល់ពីការពិត និងរឿងលំអិតនានាដើម្បីពិចារណាឈានដល់ការសម្រេចចិត្ត និងការដោះស្រាយបញ្ហា។<br>• ចូលចិត្តភាពស្ងៀមស្ងាត់ និងធ្វើការទំនាក់ទំនងតែក្នុងគោលបំណងច្បាស់-លាស់អ្វីមួយ។ | • ច្រើនតែចាប់អារម្មណ៍ជាមួយភាពប្រែប្រួលនៃព័ត៌មានអំពីបុគ្គលឬមនុស្សជាជាងគិតពីភាពប្រែប្រួលរបស់វត្ថុ និងគំនិត។<br>• ច្រើនមានការជំរុញទឹកចិត្តពីអ្នកដទៃ ហើយធ្វើការបានល្អនៅក្នុងស្ថានភាពដែលមានការលើកទឹកចិត្ត និងការជួយជ្រោមជ្រែងពីសំណាក់ក្រុមមិត្ត ឬអ្នកស្ថិតនៅជុំវិញខ្លួន។<br>• យល់ដឹងអំពីសារសំខាន់នៃបរិយាកាសក្នុងកន្លែងការងារ ថាជាប្រការសំខាន់ដូចគ្នាទៅនឹងការងារផ្ទាល់ដែរ។<br>• ធ្វើការសម្រេចចិត្តអ្វីៗដោយផ្អែកលើគោលគំនិតផ្ទាល់ខ្លួនជាចំបង។ ប៉ុន្តែជារឿយៗគេអាចស្វែងយល់ និងទទួលស្គាល់អំពីគុណតម្លៃរបស់អ្នកដទៃបានដោយងាយផងដែរ។<br>• ស្វែងរកគោលដៅ ភាពហ្មត់ចត់នៃហេតុផលពិត។ គេប្រហែលអាចដឹងបានថាមានការរិះគន់ដោយអ្នកដទៃដែលធ្វើការក្នុងបរិបទ ឬវិធីបែបវិភាគ និងពិចារណារកការពិត។ |

មនុស្សគ្រប់រូបប្រើប្រាស់វិធី ឬមធ្យោបាយបែប THINKING និង FEELING ក្នុងសកម្មភាពប្រចាំថ្ងៃ។ យ៉ាងណាមិញមនុស្សម្នាក់ៗតែងមានជម្រើសបែបធម្មជាតិ និងមានភាពសមស្របបំផុតសម្រាប់ខ្លួនទៅនឹងចំណុចមួយក្នុងចំណោមចំណុចទាំងពីរខាងលើ។ ហេតុនេះសូមជ្រើសយកចំណុចណាមួយដែលអ្នកគិតថាសមស្របខ្លាំងទៅនឹងបុគ្គលិកលក្ខណៈផ្ទាល់របស់អ្នកៈ

☐ ***T: THINKING*** ☐ ***F: FEELING***

តទៅទំព័របន្ទាប់

## បុគ្គលិកលក្ខណៈក្រុមទី៤

| ***J: JUDGING***<br>*ជាបុគ្គលមានទំនោរបែបធ្វើការសម្រេចចិត្តអ្វីដោយមុតមាំ ចូលចិត្តអ្វីៗដែលមានលក្ខណៈជារចនាសម្ព័ន្ធ និងបែបការគ្រប់គ្រង* | ***P: PERCEIVING***<br>*ជាបុគ្គលមានទំនោរបែបបើកចំហរចំពោះគោលគំនិតរបស់ខ្លួន ហើយចូលចិត្តអ្វីៗដែលកើតឡើងភ្លាមៗ និងភាពងាយបត់បែន* |
|---|---|
| • ធ្វើការសម្រេចចិត្តយ៉ាងលឿនរហ័សដើម្បីបញ្ចប់សេចក្តី។<br>• រៀបចំគម្រោង និងគ្រប់គ្រងកិច្ចការរបស់ខ្លួន។<br>• មានការអនុគ្រោះចំពោះភាពច្រំដែលរាល់ថ្ងៃ និងកិច្ចការបែបជារចនាសម្ព័ន្ធ។<br>• ចូលចិត្តមានការកំណត់ឱ្យបានច្បាស់លាស់ចំពោះតួនាទី និងការរំពឹងទុក។<br>• មិនចូលចិត្តការផ្លាស់ប្តូរ ឬភាពមិនមានន័យច្បាស់លាស់។<br>• ខំប្រឹងសម្រេចកិច្ចការឱ្យបានរួចរាល់ និងបន្តទៅមុខទៀត។<br>• មានការរៀបចំ និងមានគម្រោងជាក់ប្រាកដ។ | • កាត់សេចក្តីតាមវិធីផ្សេងៗដោយខិតខំប្រមូលព័ត៌មានឱ្យបានច្រើន។<br>• ធ្វើអ្វីៗដោយមិនបានព្រៀងទុក ហើយពន្យារកិច្ចការរហូតដល់នាទីចុងក្រោយ។ ប្រហែលគេជ្រើសរើសយកការមិនរៀបចំគម្រោង មិនគ្រប់គ្រងភារកិច្ច ឬមិនរៀបចំពេលវេលា។<br>• ចូលចិត្តការចាប់ផ្តើមគម្រោងថ្មីហើយធ្វើការជាមួយគម្រោងនោះរហូតតទៅ។<br>• មានភាពងាយបត់បែន និងភាពងាយសម្របខ្លួន។<br>• មានការបារម្ភចំពោះអ្វីដែលជាច្បាប់ទម្លាប់ ភាពច្រំដែលរាល់ថ្ងៃ និងការបញ្ចប់អ្វីមួយ។<br>• ផ្តោតចំពោះការរុករក និងស្វះស្វែងព័ត៌មានថ្មីៗហើយប្រមូល និងទទួលយកការផ្លាស់ប្តូរ។ |

មនុស្សគ្រប់រូបប្រើប្រាស់វិធី ឬមធ្យោបាយបែប JUDGING និង PERCEIVING ក្នុងសកម្មភាពប្រចាំថ្ងៃ។ យ៉ាងណាមិញមនុស្សម្នាក់ៗតែងមានជម្រើសបែបធម្មជាតិ និងមានភាពសមស្របបំផុតសម្រាប់ខ្លួនទៅនឹងចំណុចមួយក្នុងចំណោមចំណុចទាំងពីរខាងលើ។ ហេតុនេះសូមជ្រើសយកចំណុចណាមួយដែលអ្នកគិតថាសមស្របខ្លាំងទៅនឹងបុគ្គលិកលក្ខណៈផ្ទាល់របស់អ្នក៖

☐ ***J: JUDGING*** ☐ ***P: PERCEIVING***

សព្វថ្ងៃនេះ គេឃើញមានក្រុមហ៊ុន ឬភ្នាក់ងារជ្រើសរើសបុគ្គលិកខ្លះៗដែលកំពុងធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក្តី ការណែនាំអំពីអាជីព និងការងារហាក់មិនទាន់មានភាពពេញនិយម ឬក៏មិនទាន់មានក្រុមហ៊ុន ឬភ្នាក់ងារខាងអាជីពណាមួយទទួលបម្រើសេវាបែបនេះឲ្យបានជាក់លាក់នៅឡើយទេ។ ប៉ុន្តែ នៅក្នុងពេលដ៏ខ្លីខាងមុខ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) នឹងមានអនុវត្តនូវកម្មវិធីធ្វើតេស្តវាស់សមត្ថភាពផ្សេងៗដើម្បីស្វែងយល់អំពីសមាសធាតុសំខាន់ៗក្នុងការវាយតម្លៃពីបុគ្គលិកលក្ខណៈ ជំនាញ ចំណូលចិត្ត ជាដើម របស់បុគ្គលម្នាក់ៗ មុននឹងសម្រេចចិត្តចាប់យកអាជីពអ្វីមួយ ឬមុននឹងសម្រេចចិត្តសិក្សាមុខវិជ្ជាអ្វីមួយសម្រាប់អនាគតរបស់ខ្លួន។ យោងទៅដល់ចំណុចដូចបានជម្រាបមកនេះ ទ.ជ.ម.ក បានកំពុងរៀបចំចងក្រងឯកសារ និងព័ត៌មាននានាដែលពាក់ព័ន្ធដើម្បីឲ្យអ្នកស្វែងរកការងារធ្វើ និងសាធារណជនទូទៅអាចធ្វើតេស្តវាស់ស្ទង់ពីបុគ្គលិកលក្ខណៈ ជំនាញ ចំណូលចិត្ត ជាដើមសម្រាប់តម្រូវដល់ការជ្រើសរើសការងារជាអាជីព ដែលតេស្តបែបនេះអាចនឹងមានរៀបចំធ្វើតាមទម្រង់ជាក្រដាស និងតាមប្រព័ន្ធកុំព្យូទ័រ ឬតាមប្រព័ន្ធអ៊ិនធើរណិតផងដែរ។ សម្រាប់ជាព័ត៌មានដល់លោកអ្នកដែលមានចំណាប់អារម្មណ៍ចង់ស្វែងយល់បន្ថែមអំពីព័ត៌មានទាក់ទងនឹងក្រុមហ៊ុនអាជីព ឬក៏ការណែនាំអាជីពនៅតាមបណ្តាប្រទេសជឿនលឿនមួយចំនួនសូមអញ្ជើញចូលទស្សនាគេហទំព័ររបស់ភ្នាក់ងារ ឬក្រុមហ៊ុន នៃប្រទេសទាំងនោះដូចមានបង្ហាញជូនខាងក្រោម៖

| *ល.រ* | *ឈ្មោះស្ថាប័ន/ក្រុមហ៊ុន/ភ្នាក់ងារ អាជីព ឬការងារ* | *គេហទំព័រ* |
|---|---|---|
| ១ | America's Career InfoNet | http://www.careerinfonet.org/ |
| ២ | Career Information (Bureau of Labor and Statistics, U.S.A) | http://www.bls.gov/k12/index.htm |
| ៣ | Career Onestop (Pathway to Career Success) | http://careeronestop.org/ResumesInterviews/ResumesInterviews.aspx |
| ៤ | Job Guide 2011 (Australian Government) | http://www.jobguide.deewr.gov.au/ |
| ៥ | My Future (Australia) | http://www.myfuture.edu.au/ |
| ៦ | O*NET Academy (U.S.A) | http://www.onetacademy.org/ |
| ៧ | SkillsInfo (Australian Government) | http://www.skillsinfo.gov.au/ |
| ៨ | United States Department of Labor | http://www.bls.gov/oco/ |
| ៩ | Year 12: What's Next? (Department of Education, Employment, and Workplace Relations, Australian Government) | http://www.year12whatnext.gov.au/ |

ម្យ៉ាងវិញទៀត លោកអ្នកក៏អាចស្វែងរកព័ត៌មានអំពីគេហទំព័រដូចគ្នានឹងអ្វីដែលមានបង្ហាញជូនខាងលើនេះដោយគ្រាន់តែចូលទៅកាន់ «**ទំព័រមគ្គុទេសក៍អាជីព និងការងារ**» នៃគេហទំព័ររបស់ ទ.ជ.ម.ក http://www.nea.gov.kh/ ក៏បាន៕

** ដកស្រង់ និងប្រែសម្រួលដោយលោក **ហៃ ហ៊ុនឡេង** ចេញពីសៀវភៅ៖ Donna Dunning, 2001. What's Your Type of Career?: Unlock the Secrets of Your Personality to Find Your Perfect Career Path. Davies-Black Publishing. ទំព័រ (៩-១៣) ព្រមទាំងឯកសារពាក់ព័ន្ធមួយចំនួនទៀត។*



សូមរង់ចាំអានបន្តនៅការចេញផ្សាយលេខបន្ទាប់

# តើអ្វីជាព័ត៌មានទីផ្សារការងារ?

What is Labour Market Information?

## ១. និយមន័យ*

ជាទូទៅហាក់ពុំមាននិយមន័យដាច់ដោយឡែកណាមួយសម្រាប់កំណត់អត្ថន័យស្តីពី «ព័ត៌មានទីផ្សារការងារ» ទេ។ និយាយម្យ៉ាងទៀត គឺមាននិយមន័យផ្សេងៗគ្នាដែលបានផ្តល់ឱ្យដោយអ្នកស្រាវជ្រាវ ឬស្ថាប័នជំនាញផ្នែកទីផ្សារការងារ អ្នកជំនាញផ្នែកអាជីព ឬអ្នកប្រឹក្សាផ្នែកអាជីព។ ប្រសិនបើពិនិត្យទៅលើនិយមន័យដែលផ្តល់ដោយអង្គការពលកម្មអន្តរជាតិ (International Labour Organization) «ព័ត៌មានទីផ្សារការងារ» *គឺសំដៅដល់ "ព័ត៌មានទាំងឡាយណាដែលទាក់ទងទៅនឹងទំហំ និងសមាសភាពរបស់ទីផ្សារការងារ ឬផ្នែកណាមួយរបស់ទីផ្សារការងារ បែបផែន ឬមុខងារនៃផ្នែកណាមួយរបស់ទីផ្សារការងារ បញ្ហាពាក់ព័ន្ធ ឱកាសដែលនឹងអាចកើតមានឡើង ព្រមជាមួយនឹងបំណងប្រាថ្នាចំពោះការងារដែលចង់បាន ឬសេចក្តីរំពឹងទុករបស់ជនទាំងឡាយដែលពាក់ព័ន្ធទៅនឹងទីផ្សារការងារ"*។

ក្រៅពីនិយមន័យរបស់អង្គការពលកម្មអន្តរជាតិ នៅមានប្រភពផ្សេងទៀតដែលបានសិក្សាស្រាវជ្រាវ និងឱ្យនិយមន័យប្រហាក់ប្រហែលគ្នាអំពីព័ត៌មានទីផ្សារការងារគឺជា "ព័ត៌មានទាំងឡាយណាដែលបង្ហាញអំពី រចនាសម្ព័ន្ធ ឬការងារនៅក្នុងទីផ្សារការងារ ដោយរួមបញ្ចូលនូវរាល់កត្តាទាំងឡាយដែលជះឥទ្ធិពលទៅដល់រចនាសម្ព័ន្ធ និងការងារនៅក្នុងទីផ្សារការងាររួមមាន៖ ឱកាសការងារ ឬតម្រូវការកម្លាំងពលកម្ម (Labour demand) ការផ្គត់ផ្គង់កម្លាំងពលកម្ម ឬធនធានមនុស្សដែលមានសម្រាប់បំពេញការងារ ( Labour supply) យន្តការនានាដែលផ្គូផ្គងចំណុចទាំងពីរខាងលើ ការប្រែប្រួលទាំងផ្នែកខាងក្នុង និងខាងក្រៅនៃបរិស្ថានការងារ"។ ជាមួយគ្នានោះដែរ ព័ត៌មានទីផ្សារការងារក៏បានរួមបញ្ចូលនូវរាល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការងារ ប្រាក់បៀវត្ស កម្រិតគុណវុឌ្ឍិសម្រាប់ការងារនីមួយៗ លក្ខខណ្ឌការងារ សូចនាករសេដ្ឋកិច្ច លក្ខខណ្ឌទីផ្សារការងារ និងតម្រូវការនៅក្នុងការសិក្សាអប់រំ និងបណ្តុះបណ្តាល។

យ៉ាងណាមិញ និយមន័យខាងលើនេះនៅមានលក្ខណៈទូលំទូលាយនៅឡើយ ដោយមិនទាន់អាចកំណត់បាននូវចំណុចគោលសំខាន់ៗឱ្យបានច្បាស់លាស់នៅឡើយទេ។ ដោយហេតុថាអ្នកសិក្សាស្រាវជ្រាវ ឬអ្នកអនុវត្តកិច្ចការពាក់ព័ន្ធទៅនឹងផ្នែកនេះច្រើនមានទំនោរ និងទស្សនវិស័យផ្តោតទៅលើចំណុចដែលថាក្រុមជននានារួមមាន៖ អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នករៀបចំគោលនយោបាយ និងផែនការ និងសាធារណជនទូទៅ មានតម្រូវការ និងការស្វែងយល់អំពីព័ត៌មានទីផ្សារការងារផ្សេងៗពីគ្នា ហើយក៏ឈានទៅកំណត់ផែនការសម្រាប់ធ្វើជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្តជ្រើសរើសអាជីពរបស់ខ្លួននាពេលអនាគត។ ព័ត៌មានទីផ្សារការងារ គឺជាប្រភពព័ត៌មានដ៏មានសារៈសំខាន់សម្រាប់បុគ្គលគ្រប់រូបដែលមានបំណងស្វែងយល់អំពីអាជីព ការងារ និងឱកាសនៅក្នុងការសិក្សាអប់រំ ក៏ដូចជាតម្រូវការព័ត៌មានស្តីអំពីទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។ ចំពោះអ្នកដែលមានបំណងចង់ស្វែងរកការងារធ្វើ ឬកំពុងបំពេញការងារនោះ អាចប្រើប្រាស់ព័ត៌មានទីផ្សារការងារដើម្បីកំណត់អំពីមុខរបរដែលខ្លួនចង់ធ្វើ ក៏ដូចជាការងារដែលកំពុងពេញនិយមនៅក្នុងទីផ្សារការងារ និងទីកន្លែងរបស់ការងារទាំងនោះ។ ក្រៅពីនេះព័ត៌មានទីផ្សារការងារ ក៏ជាប្រភពព័ត៌មានសិក្សាអប់រំ និងបណ្តុះបណ្តាលសម្រាប់បុគ្គលទាំងឡាយដែលមានបំណងចាប់យកអាជីពណាមួយ។ រីឯនិយោជកក៏អាចប្រើប្រាស់ព័ត៌មានទីផ្សារការងារ ដូចជាទិន្នន័យប្រជាសាស្ត្រ ការព្យាករណ៍អំពីការងារនាពេលអនាគត និងស្ថិតិពាក់ព័ន្ធដទៃទៀតដែលជាអត្ថប្រយោជន៍ក្នុងការរៀបចំផែនការអាជីវកម្មរបស់ខ្លួន និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍធនធានមនុស្ស ។

ប្រសិនបើយើងធ្វើការសង្ខេបអំពីភាពចាំបាច់របស់ព័ត៌មានទីផ្សារការងារនោះ យើងសង្កេតឃើញមានចំណុចសំខាន់ៗដូចជា៖

- **វិស័យការងារ:** ជាកិច្ចការដែលមនុស្សទូទៅ (កម្លាំងពលកម្ម) បំពេញ ហើយដែលនិយោជកចង់ឱ្យអ្នកទាំងនោះបំពេញ (ប្រភេទការងារ) ចំនួនការងារ ឬឱកាសការងារដែលមានក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត។
- **សក្តានុពលនៃកម្លាំងពលកម្មដែលមាន:** សំដៅទៅលើក្រុមជនដែលកំពុងបំពេញការងារ ក្រុមជនដែលមិនមានការងារធ្វើ ក៏ប៉ុន្តែចង់បានការងារ (សំដៅទៅដល់អ្នកអត់ការងារធ្វើ) ឬចំពោះក្រុមជនដែលនឹងស្វែងរកការងារធ្វើនៅក្នុងពេលអនាគត។
- **និយោជក:** សំដៅទៅដល់ក្រុមហ៊ុន ស្ថាប័ន និងរោងចក្រសហគ្រាសនានាដោយរួមបញ្ចូលនូវរាល់ចំណុចពាក់ព័ន្ធមួយចំនួនដូចជា៖ ស្ថានភាពការងារ ប្រាក់ឈ្នួល ឬប្រាក់កម្រៃ ព្រមទាំងតម្រូវការផ្នែកសមត្ថភាព និងជំនាញជាដើម។

**ដកស្រង់ និងប្រែសម្រួលដោយលោក សាម៉េន សុខា លោក ហៃ ហ៊ុនឡេង និងលោក ទូច សុផាត ចេញពីសៀវភៅ៖ Gothard Bill, et al., (2001). Career Guidance in Context. Sage Publication. Page 78 – 79. ព្រមទាំង ឯកសារពាក់ព័ន្ធដ៏ទៃទៀត។*

តទៅទំព័របន្ទាប់

តាមការរៀបរាប់ខាងលើនេះ រាល់ព័ត៌មានសំខាន់ៗសម្រាប់ធ្វើការពិចារណាស្វែងយល់អំពីទំនាក់ទំនងនៅក្នុងព័ត៌មានទីផ្សារការងារ រួមមាន៖ អាយុ ដំណាក់កាលផ្សេងៗនៃស្ថានភាពរស់នៅ កម្រិតវប្បធម៌ បែបផែននៃការសម្រេចចិត្ត ឬដំណាក់កាលអន្តរកាល គោលបំណងនៃការណែនាំអំពីការងារដែលនឹងត្រូវលើកយកមកប្រើប្រាស់។

## ២. សមាសធាតុនៃព័ត៌មានទីផ្សារការងារ

ដូចដែលបានបកស្រាយនៅក្នុងនិយមន័យខាងលើ ព័ត៌មានទីផ្សារការងារគឺជាបណ្តុំព័ត៌មានដែលរួមបញ្ចូលទៅដោយសមាសធាតុផ្សេងៗពាក់ព័ន្ធនឹងតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ឱកាសការងារ ជាដើម។ ក្នុងផ្នែកបន្ទាប់យើងនឹងពិនិត្យមើលទៅលើសមាសធាតុនីមួយៗ ថាតើចំណុចទាំងអស់នោះមានទំនាក់ទំនងជាមួយព័ត៌មានទីផ្សារការងារយ៉ាងដូចម្តេចខ្លះ។ ខាងក្រោមនេះគឺជាចំណុចសំខាន់ៗចំនួន ៦ ដែលលើកឡើងដោយអ្នកផ្តល់ការណែនាំផ្នែកអាជីព (Career Advisor) អំពីបទ ពិសោធន៍ទូទៅដែលឆ្លើយតបទៅនឹងអ្នកស្វែងរកការងារធ្វើ ស្ថាប័ន ឬក្រុមហ៊ុនអាជីពផ្សេងៗ (Careers Companies) ស្តីអំពីព័ត៌មានទីផ្សារការងាររួមមាន៖

### *២.១. តម្រូវការកម្លាំងពលកម្ម*

នៅក្នុងចំណុចនេះតែងមានការចោទសួរជាច្រើនដូចជា៖ តើអ្វីទៅជាចំណុចងាយស្រួលដើម្បីទទួលបានការងារធ្វើនៅក្នុងស្ថាប័ន ឬក្រុមហ៊ុនណាមួយ? តើការងារប្រភេទនេះមានការប្រកួតប្រជែងបែបណាខ្លះ?

ជាទូទៅ ចម្លើយសម្រាប់សំនួរបែបនេះត្រូវបានបកស្រាយដោយពិនិត្យទៅលើការខ្វះខាតជំនាញផ្នែកណាមួយ (Skill Shortage) តម្រូវការសម្រាប់ការជំនួសតួនាទី ឬតំណែងក្នុងការងារ (Replacement Demand) ការបង្កើនតម្រូវការ ឬបង្កើនការផ្តល់កម្លាំងពលកម្ម (Expansive demand and the supply of labour)។ល។ ទន្ទឹមនឹងនេះ ចម្លើយក៏អាចបានមកពីការយល់ដឹងអំពីចំនួននៃឱកាសការងារដោយធ្វើការប្រៀបធៀបទៅនឹងចំនួនបេក្ខជននាពេលមុន និងក្រោយការអប់រំបណ្តុះបណ្តាល។ តើវាជាប្រភេទការងារកំពុងពេញនិយម ឬក៏មិនសូវពេញនិយម? តើការងាររបស់ស្ថាប័ន ឬសហគ្រាសនោះមានការពង្រីកបរិមាណ ឬមានគម្រោងបង្កើតថ្មីដែរឬទេ? តើទំនោរនៃការបំពេញការងាររបស់កម្មករ បុគ្គលិកនៅក្នុងស្ថាប័ន ឬសហគ្រាសនោះមានរយៈពេលយូរ ឬឆាប់?

### *២.២. វិធីសាស្ត្រនៃការអភិវឌ្ឍ (សមត្ថភាព) រចនាសម្ព័ន្ធការងារ ឬប្រាក់ចំណូល*

តើមានការរំពឹងទុកបែបណាខ្លះអំពីការងាររបស់ខ្លួន? តាមរយៈការងារនេះ តើខ្ញុំអាចអភិវឌ្ឍសមត្ថភាពបានកម្រិតណា?

សម្រាប់សំណួរបែបនេះ យើងត្រូវធ្វើការស្វែងយល់អំពីប្រាក់បៀវត្សនាពេលចាប់ផ្តើមការងារ និងក្រោយពេលបំពេញការងារបានមួយរយៈពេលកន្លងមក ភាពប្រាកដប្រជានៅក្នុងក្របខណ្ឌការងារ ឬតួនាទី រួមទាំងបែបបទក្នុងការការងារ ឬរចនាសម្ព័ន្ធនៃអាជីពដូចជា ឱកាសក្នុងការឡើងឋានៈ មធ្យោបាយក្នុងការអភិវឌ្ឍសមត្ថភាពដែលពាក់ព័ន្ធទៅនឹងឱកាសទាំងនោះជាដើម។

ពាក់ព័ន្ធទៅនឹងចំណុចទាំងនេះ ការយល់ដឹងអំពីលទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាព ឬការបណ្តុះបណ្តាលជំនាញឱ្យកាន់តែល្អ ប្រសើរ គឺជាប្រការសំខាន់ណាស់សម្រាប់ការសម្រេចចិត្តទទួលយកការងារណាមួយ។

### *២.៣. លទ្ធភាពទទួលបានការងារធ្វើនៅក្នុងទីកន្លែង ឬតំបន់ណាមួយ*

តើមានការងារដែលស្ថិតនៅក្បែរ ឬជិតតំបន់ដែលខ្ញុំកំពុងរស់នៅដែរឬទេ?

សំណួរបែបនេះតែងត្រូវបានចោទសួរដោយយោងទៅលើហេតុផលចាំបាច់មួយចំនួន ដូចជាប្រភេទការងារខ្លះតម្រូវឱ្យអ្នកបំពេញការងារ រស់នៅ ឬមានលំនៅឋានស្ថិតនៅជិតទីកន្លែងបំពេញការងារដើម្បីមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅវិញទៅមក។ ឧទាហរណ៍៖ កម្មកររោងចក្រ អ្នកបម្រើការងារនៅកន្លែងត្រួតពិនិត្យចរាចរតាមផ្លូវអាកាសជាដើម។

មានសំនួរខ្លះទៀតដែលអ្នកស្វែងរកការងារធ្វើបានចោទសួរតាមបែបប្រយោល ឬមិនចំពោះទៅលើប្រធានបទណាមួយ ក៏ប៉ុន្តែចង់ស្វែងយល់អំពីព័ត៌មានដែលពាក់ព័ន្ធទៅនឹងចំណុចដែលបានគូសបញ្ជាក់ខាងលើដូចជា៖

- តើមានវគ្គអប់រំបណ្តុះបណ្តាលដែរឬទេ?
- តើការបណ្តុះបណ្តាលនោះរៀបចំនៅកន្លែងណា?

ចំពោះចម្លើយសម្រាប់សំណួរទាំងនេះ គឺត្រូវមានការយល់ដឹងអំពីទីតាំងនៅក្នុងតំបន់ ផ្លូវធ្វើដំណើរ និងមធ្យោបាយក្នុងការធ្វើដំណើរ (ជាពិសេសចំពោះទីតាំងដែលនៅស្ថិតនៅឆ្ងាយ ឬដាច់ស្រយ៉ាល មធ្យោបាយធ្វើដំណើរតែងជួបការលំបាក)។ ម្យ៉ាងវិញទៀត ការយល់ដឹងអំពីប្រាក់បៀវត្សដែលនឹងផ្ដល់ជូន (ឧទាហរណ៍ ប្រាក់ខែតិចពេក) ក៏អាចជាប្រធានបទក្នុងការពិចារណាអំពីការចំណាយសម្រាប់មធ្យោបាយធ្វើដំណើរផងដែរ។ ការយល់ដឹងអំពីទីកន្លែងស្នាក់នៅដែលនឹងផ្ដល់ជូនក៏ជាប្រការសំខាន់ប្រសិនបើកន្លែងការងារស្ថិតនៅឆ្ងាយពេកមិនអាចធ្វើដំណើរទៅវិញទៅមកបានជាប្រចាំថ្ងៃនោះ។

### ២.៤. និន្នាការការងារ

តើចំនួនការងារនៅក្នុងវិស័យនេះមានការកើនឡើង និងមានស្ថិរភាពដែរឬទេ? ឬ តើឱកាសការងារមានការធ្លាក់ចុះនាថ្ងៃអនាគត ដែរឬទេ?

ជាធម្មតា ចំណុចទាំងនេះគឺជាសេចក្ដីបារម្ភរបស់អ្នកដែលបានចំណាយពេលវេលាយូរក្នុងការសិក្សា ការរៀបចំខ្លួនសម្រាប់អាជីពថ្មី ឬក៏ការលះបង់តំណែងការងារណាមួយទៅចាប់យកឱកាសការងារថ្មីមួយនៅកន្លែងដទៃទៀតជាដើម។ ទន្ទឹមនឹងនេះ ក៏ស្ថិតនៅត្រង់ចំណុចដែលថា ប្រសិនបើអ្នកទាំងនោះបានចំណាយពេលវេលា និងប្រាក់កាសដ៏ច្រើនដើម្បីទទួលបានការអប់រំបណ្ដុះបណ្ដាលនោះ តើអ្វីទៅដែលជាឱកាសសម្រាប់ទទួលបានការងារត្រលប់មកវិញ? តើនៅពេលបញ្ចប់ការសិក្សា លទ្ធភាពនៃការត្រូវបានជួលឱ្យទៅបំរើការងារមានសភាពយ៉ាងដូចម្ដេចដែរ?

ជាការពិតណាស់ អ្នកប្រឹក្សាផ្នែកអាជីពនឹងធ្វើការពិនិត្យទៅលើបញ្ហាទាំងនេះដោយរំពឹងទៅលើទិសដៅ ឬទិន្នន័យដែលបានមកពីការស្រាវជ្រាវនាពេលកន្លងមក ដោយអាចចោទជាសំណួរដូចខាងក្រោម៖

- តើអ្នកដែលធ្លាប់បានឆ្លងកាត់ការសិក្សាបែបនេះ ច្រើនតែបំពេញការងារបែបណាដែរនាពេលកន្លងមក?
- តើការងារ ឬស្ថាប័នបែបនេះអាចទទួលរងផលប៉ះពាល់ដែលបណ្ដាលមកពីការវិវត្តន៍នៃស្ថានភាពសេដ្ឋកិច្ចដែរឬទេ?
- តើឱកាសការងារបែបនេះត្រូវបានជូនដំណឹងមកយើង/អ្នកដោយមានបង្ហាញអំពីចំនួនកើនឡើង ឬក៏មានការផ្សព្វផ្សាយយ៉ាងទៀងទាត់នៅកន្លែងដទៃទៀតដែរឬទេ?
- តើមានសញ្ញាណស្ដីពីការកើនឡើង ឬការរីកចម្រើនក្នុងវិស័យការងារបែបនេះដែរឬទេ?
- តើយើងអាចដឹងអ្វីខ្លះពីទស្សនវិស័យការងារប្រភេទនេះនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង?

### ២.៥.លទ្ធភាពនៃការផ្លាស់ប្ដូរ ឬការផ្ទេរការងារ

ក្នុងករណីការងារ ឬមុខរបរនៅក្នុងវិស័យដែលកំពុងបំពេញមានការធ្លាក់ចុះ ឬមានឱនភាព ឬត្រូវបញ្ឈប់ជាស្ថាពរ តើមានវិធីសាស្ត្រអ្វីខ្លះដែលខ្ញុំអាចបំពេញកិច្ចការដោយប្រើចំណេះដឹងដែលទទួលបានពីការបណ្ដុះបណ្ដាលសមត្ថភាព ការប្រកួតប្រជែង ឬជំនាញដែរ ឬទេ?

ដើម្បីអាចឆ្លើយសំនួរនេះបាន អ្នកប្រឹក្សាផ្នែកអាជីពត្រូវការយល់ដឹងអំពីវិធីសាស្ត្រនៃការទទួលព័ត៌មានដែលបានមកពីការប្រកួតប្រជែង គម្លាតនៃតម្រូវការជាមូលដ្ឋានរបស់ជំនាញក្នុងស្ថានភាពការងារបច្ចុប្បន្ន ព្រមទាំងត្រូវយល់ដឹងអំពីកន្លែងដែលអាចទទួលបាននូវព័ត៌មានខាងលើ ឬចំណុចដែលនឹងត្រូវលើកយកមកពិចារណា។

### ២.៦. ការជួលឱ្យបំពេញការងារ និងវិធីសាស្ត្រនៃការជ្រើសរើសបុគ្គលិក

ក្នុងការស្វែងរកការងារធ្វើ តើត្រូវប្រើវិធីសាស្ត្របែបណាខ្លះ? តើត្រូវរកការងារដែលខ្លួនចង់បាននៅកន្លែងណា?

ចម្លើយសម្រាប់សំណួរនេះ គឺត្រូវមានការយល់ដឹងអំពីវិធីសាស្ត្រជាមូលដ្ឋានដែលពាក់ពន្ធ័ទៅនឹងមុខតំណែង ឬស្ថាប័នណាមួយ និងអំពីដំណើរការដែលនិយោជកកំណត់យកវិធីជាក់លាក់ណាមួយសម្រាប់ការជួល ឬជ្រើសរើសបុគ្គលិក ឧទាហរណ៍៖ តើព័ត៌មានស្ដីពីឱកាសការងារត្រូវបានផ្សព្វផ្សាយនៅកន្លែងណា? តើមានការប្រលងជ្រើសរើស (តេស្ត) សម្រាប់ការងារនេះដែរឬទេ?

សម្រាប់ព័ត៌មានដទៃទៀត ក៏អាចធ្វើការពិនិត្យអំពីទស្សនៈរបស់បេក្ខជនដែលធ្លាប់បានដាក់ពាក្យសម្រាប់មុខតំណែងនោះពីមុន ថាតើនិយោជកមានទំនោរបែបណាខ្លះក្នុងការជ្រើសរើសបុគ្គលិក? ម្យ៉ាងវិញទៀត តើអ្នកស្វែងរកការងារធ្វើនាពេលកន្លងមកបានរៀបចំការដាក់ពាក្យសុំការងារធ្វើយ៉ាងដូចម្ដេចខ្លះ?

យោងទៅដល់ សំណួរ-ចម្លើយដែលមានបង្ហាញជូនក្នុងចំណុចគោលទាំង៦ខាងលើ គឺជាការស្វែងយល់ និងការផ្ដល់ព័ត៌មានទូទៅអំពីការងារ ឬអាជីព លទ្ធភាពក្នុងការបំពេញការងារ តម្រូវការរបស់និយោជក និងដំណើរការពង្រឹងសមត្ថភាពក្នុងក្របខណ្ឌការងារជាដើម។ សមាសធាតុទាំងនេះក៏បានឆ្លើយតបទៅ

តទៅទំព័របន្ទាប់

នឹងសំណួរដែលបានចោទសួរថា "**តើអ្វីជាព័ត៌មានទីផ្សារការងារ?**"។ មានន័យថា ការសន្ទនាគ្នារវាងភាគីពាក់ព័ន្ធនានាដែលមានសកម្មភាពក្នុងទីផ្សារការងារដូចជា និយោជក អ្នកស្វែងរកការងារធ្វើ អ្នកណែនាំផ្នែកអាជីព គឺសុទ្ធសឹងបានប្រាស្រ័យទាក់ទង ព្រមទាំងផ្សាភ្ជាប់ព័ត៌មានរវាងគ្នា និងគ្នាស្ថិតក្នុងបរិបទនៃការចង់ស្វែងយល់អំពីចំណុចគន្លឹះមួយចំនួនមានជាអាទិ៍ តម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម និន្នាការការងារ និងដំណើរវិវឌ្ឍនៃចរន្តទីផ្សារការងារនាពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។ អាស្រ័យហេតុនេះ ប្រសិនបើពិនិត្យ ទៅលើខ្លឹមសារនៃ សំណួរ-ចម្លើយក្នុងចំណុចទាំង ៦ខាងលើ គេពិតជាអាចស្វែងយល់អំពីសារៈសំខាន់ និងតួនាទីរបស់ព័ត៌មានទីផ្សារការងារសម្រាប់ក្រុមមនុស្ស ដែលមានបំណងស្វែងយល់ឱ្យកាន់តែទូលំទូលាយ និងសម្រាប់ជាមូលដ្ឋានគ្រឹះ នៃការសម្រេចចិត្តក្នុងក្របខណ្ឌការងាររបស់ខ្លួន។

ភ្ជាប់ទៅនឹងសេចក្តីអធិប្បាយខាងលើ សម្រាប់បរិបទទីផ្សារការងារនៅប្រទេសកម្ពុជាលោកអ្នកអាចទទួលបាននូវសេវាបែបនេះជាពិសេសតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) ដែលមានផ្តល់ជូននូវព័ត៌មានទីផ្សារការងារដោយគ្របដណ្តប់ទៅលើព័ត៌មានស្តីពីការចុះឈ្មោះស្វែងរកការងារធ្វើ ព័ត៌មានជ្រើសរើសបុគ្គលិក ព័ត៌មានអប់រំបណ្តុះបណ្តាល -ល- ព័ត៌មានទាំងនេះមានផ្តល់ជូននៅមួយកន្លែងងាយស្រួលដោយការប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលការងារ ឬតាមរយៈគេហទំព័ររបស់ ទ.ជ.ម.ក (www.nea.gov.kh)។ សូមជម្រាបថា សម្រាប់សេវាណែនាំអាជីព ក៏ដូចជាជំបូន្មានសំខាន់ៗស្តីពីទីផ្សារការងារនៅកម្ពុជាសម្រាប់អ្នកស្វែងរកការងារធ្វើ និងសាធារណជនទូទៅក៏នឹងមានផ្តល់ជូនផងដែរនាពេលខាងមុខ ដោយបច្ចុប្បន្ននេះ ទ.ជ.ម.ក កំពុងតែរៀបចំចងក្រងនូវឯកសារពាក់ព័ន្ធនានាសម្រាប់បម្រើឱ្យផ្នែកនេះ។ ហេតុនេះ ក្នុងពេលបច្ចុប្បន្ន លោកអ្នកអាចទទួលបានសេវាដែលមានបម្រើស្រាប់ដោយឥតគិតថ្លៃនៅនឹងកន្លែងមានដូចជា ព័ត៌មានស្តីពីតម្រូវការកម្លាំងពលកម្ម (ឱកាសការងារ ឬព័ត៌មានជ្រើសរើសបុគ្គលិក) ដែលមានផ្សព្វផ្សាយជាប្រចាំថ្ងៃនៅតាមមជ្ឈមណ្ឌលការងារ ឬនៅលើគេហទំព័រការងាររបស់ ទ.ជ.ម.ក។ ចំណែកឯ ព័ត៌មានពាក់ព័ន្ធនឹងនិន្នាការការងារនាពេលបច្ចុប្បន្ន និងពេលអនាគតលោកអ្នកក៏អាចទទួលបានព័ត៌មានប្រភេទនេះតាមរយៈព័ត៌មានទីផ្សារការងាររបស់ ទ.ជ.ម.ក ដែលមានផ្សព្វផ្សាយជាសាធារណៈតាមមធ្យោបាយបម្រើសេវាផ្សេងៗរបស់ខ្លួនដូចជា គេហទំព័រ និងព្រឹត្តិបត្រ ជាដើម។

សរុបសេចក្តីមក សារៈសំខាន់នៃតម្រូវការ និងការផ្តល់ព័ត៌មានទីផ្សារការងារនៅក្នុងវិស័យការងារគឺមានអត្ថប្រយោជន៍ និងមានភាពចាំបាច់ដូចៗគ្នា។ បានន័យថាការអាចទទួលបានការងារសមតាមចំណូលចិត្ត និងជំនាញរបស់បុគ្គលគ្រប់ៗរូប គឺអាស្រ័យដោយការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីស្ថាប័ន ឬភ្នាក់ងារជំនាញផ្នែកទីផ្សារការងារ។ ហេតុនេះការផ្តួចផ្តើមបង្កើតឱ្យមាន ទីភ្នាក់ងារជាតិមុខរបរ និងការងារនៅកម្ពុជា គឺជាហេតុផលចម្បងដែលមានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងខ្លឹមសារដែលបានពណ៌នាខាងលើ ហើយដែលនេះគឺជាគោលគំនិត និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំប្រកបដោយភាពឈ្លាសវៃ។

## ៣. ព័ត៌មានទីផ្សារការងារនៅកម្ពុជា

ស្ថានភាពព័ត៌មានទីផ្សារការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលកន្លងមក នៅពុំទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការរបស់ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងវិស័យការងារនៅឡើយទេ។ រាល់ព័ត៌មានដែលទាក់ទងទៅនឹងឱកាសការងារ កម្លាំងពលកម្ម និងទិន្នន័យអំពីមុខរបរនៅតាមបណ្តារោងចក្រ សហគ្រាស ឬក្រុមហ៊ុននានានៅមានសភាពដាច់ដោយដុំៗ អាស្រ័យដោយយន្តការនៃការប្រមូល ចងក្រង និងវិភាគអំពីព័ត៌មានប្រភេទនេះនៅមានកម្រិតនៅឡើយ។ កង្វះខាតនៃព័ត៌មានទីផ្សារការងារបានក្លាយជាឧបសគ្គនៅក្នុងដំណើរការនៃការរៀបចំតម្រង់ទិសនៅក្នុងទីផ្សារការងារឱ្យបានល្អប្រសើរ និងការរៀបចំផែនការអភិវឌ្ឍវិស័យការងារទាំង សម្រាប់ផ្នែកសាធារណៈ និងផ្នែកឯកជននៅកម្ពុជា។

អាស្រ័យដោយវិសាលភាពនៃបណ្តុំព័ត៌មានទីផ្សារការងារមានលក្ខណៈទូលំទូលាយទាំងនៅក្នុងផ្នែកសាធារណៈ និងផ្នែកឯកជន ដូច្នេះយន្តការនៃការប្រមូលក៏ត្រូវគ្របដណ្តប់ទៅលើទំហំការងារទាំងអស់នោះដោយយោងទៅតាមផ្នែក វិស័យ ប្រភេទគំមាន និងស្ថាប័ន ជាដើម។ ដោយផ្តោតទៅលើភាពចាំបាច់ និងប្រសិទ្ធភាពនៃការប្រមូលព័ត៌មានទីផ្សារការងារ ជាពិសេសព័ត៌មានដែលនឹងត្រូវធ្វើការប្រមូលពីតាមបណ្តាក្រសួង ស្ថាប័ន អង្គភាពដែលពាក់ព័ន្ធនានា ក្នុងគោលបំណងអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន និងទៅអនាគតនៅកម្ពុជា គណៈកម្មាធិការជាតិបណ្តុះបណ្តាលបានចេញប្រកាសលេខ ១៣៤ ប្រក ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៨ ស្តីពី ***ការបង្កើតអនុគណៈកម្មការព័ត៌មានទីផ្សារការងារ*** ដែលមានរួមបញ្ចូលទៅដោយសមាសភាពចំរុះនៃតំណាងមកពី ក្រសួង ស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ព្រមទាំងតំណាងនានាដែលមកពីផ្នែកឯកជនរួមមាន តំណាងសភាមុខរបរនិងមីក្រូសហគ្រាស សភាពាណិជ្ជកម្ម សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា និយោជក និងនិយោជិត។

យោងទៅលើប្រកាសលេខ ១០៩ ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ ស្តីពី ការកែសម្រួលប្រការ២ នៃប្រកាសលេខ ១៣៤ ប្រក ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៨ ដូចបានពោលពីខាងដើម សមាសភាពនៃអនុគណៈកម្មការព័ត៌មានទីផ្សារការងារ មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១ | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | ប្រធាន |
| ២ | តំណាងសភាមុខរបរ និងមីក្រូសហគ្រាស | អនុប្រធាន |
| ៣ | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤ | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៥ | មន្ត្រីជំនាញ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៦ | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧ | តំណាងសភាពាណិជ្ជកម្ម | សមាជិក |
| ៨ | តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ៩ | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១០ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១ | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២ | តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣ | តំណាងនិយោជក ៥រូប | សមាជិក |
| ១៤ | តំណាងនិយោជិត ១រូប | សមាជិក |
| ១៥ | តំណាងនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦ | តំណាងនាយកដ្ឋានស្តង់ដារជាតិសមត្ថភាព នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧ | នាយកដ្ឋានព័ត៌មានទីផ្សារការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | លេខាធិការដ្ឋាន |

ដោយអនុលោមទៅលើមូលដ្ឋាននៃសេចក្តីប្រកាសនេះ អនុគណៈកម្មការព័ត៌មានទីផ្សារការងារមានភារកិច្ចៈ

- រៀបចំបង្កើតបណ្តាញព័ត៌មានទីផ្សារការងាររហូតដល់ថ្នាក់ខេត្ត ក្រុង
- សិក្សាស្រាវជ្រាវរកឱ្យឃើញនូវមុខរបរជាអាទិភាព និងមុខរបរថ្មីៗតាមតម្រូវការទីផ្សារការងារ
- កសាងគោលនយោបាយទីផ្សារការងារមួយឱ្យសមស្របតាមតម្រូវការ ពិសេសការគ្រប់គ្រងកម្លាំងពលកម្មគ្រប់ប្រភេទ និងធ្វើឱ្យ មានតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស។
- រៀបចំនីតិវិធីក្នុងការប្រមូលទិន្នន័យព័ត៌មានទីផ្សារការងារ វិភាគ និងកសាងទៅជាស្ថិតិការងារមួយសម្រាប់ជាជំនួយដល់ការកសាងផែនការ និងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ផ្នែកឧស្សាហកម្ម សេវាកម្ម កសិកម្ម ។ល។
- កំណត់តម្រូវការដាក់លាក់លើការអប់រំបណ្តុះបណ្តាលជំនាញតាមផ្នែកឧស្សាហកម្ម សេវាកម្ម កសិកម្ម ។ល។
- ផ្តល់យោបល់លើការចងក្រងមុខរបរផ្នែកឧស្សាហកម្ម សេវាកម្ម កសិកម្ម ។ល។
- រៀបចំលេខកូដមុខរបរ (ឈ្មោះមុខរបរ)
- ធ្វើការផ្សព្វផ្សាយ និងផ្តល់សេវាព័ត៌មានទីផ្សារការងារដល់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសិស្សនិស្សិត និងកម្មករនិយោជិត
- រៀបចំបង្កើតគេហទំព័រស្តីពីព័ត៌មានទីផ្សារការងារ
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារព័ត៌មានទីផ្សារការងារ
- រៀបចំរបាយការណ៍សកម្មភាពការងារ និងរាយការណ៍ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដើម្បីដោះស្រាយរាល់បញ្ហានានាដែលពាក់ព័ន្ធ
- រៀបចំផែនការការងារប្រចាំឆ្នាំ។

តទៅទំព័របន្ទាប់

ម្យ៉ាងវិញទៀត ដើម្បីជាឧបករណ៍ក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យការងារ និងលើកកម្ពស់ការផ្តល់ និងទទួលបានព័ត៌មានទីផ្សារការងារ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត ទ.ជ.ម.ក តាមរយៈអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៩ និងបានកំណត់ ទ.ជ.ម.ក ជាអង្គភាពស្ថិតិដែលបានចាត់តាំងរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល តាមរយៈអនុក្រឹត្យលេខ១១៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារដោយបន្ថែមទៅលើតួនាទី និងភារកិច្ចដែលមានស្រាប់ (រូបទី ៤)។ អនុលោមតាមអនុក្រឹត្យនេះ ទ.ជ.ម.ក មានតួនាទី និងភារកិច្ចក្នុងការសម្របសម្រួល ប្រមូល សំយោគ ផលិត ចងក្រង វិភាគ សិក្សាស្រាវជ្រាវ បង្កើត អភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារជាសាធារណៈនៅមួយកន្លែងងាយស្រួលតាមប្រព័ន្ធអេឡិចត្រូនិច ឬក្នុងទម្រង់ក្រដាសសម្រាប់ផ្តល់តម្រូវការព័ត៌មានរបស់ភាគីពាក់ ព័ន្ធសំខាន់ៗនៅក្នុងទីផ្សារការងារ។

ក្នុងដំណើរការការងាររបស់ខ្លួនក្នុងរយៈពេលជាង១ឆ្នាំមកនេះ ទ.ជ.ម.ក បានរៀបចំ ប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារពីប្រភពនានាជាប្រចាំថ្ងៃដើម្បីធ្វើការផ្សព្វផ្សាយនៅលើគេហទំព័រការងារនិងនៅតាមមជ្ឈមណ្ឌលការងាររបស់ខ្លួន និងបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ។ ទិន្នន័យទាំងនោះសុទ្ធសឹងតែឆ្លុះបញ្ចាំងអំពីស្ថានភាពទីផ្សារការងារ និងសារៈសំខាន់នៃមូលដ្ឋានគ្រឹះរបស់ព័ត៌មានទីផ្សារការងារដែលមានប្រយោជន៍សម្រាប់សាធារណជនទូទៅ។

រូបទី៤: ប្រព័ន្ធស្ថិតិជាតិកម្ពុជា




រូបទី៥: គំនូរបំព្រួញស្តីពីប្រព័ន្ធព័ត៌មានទីផ្សារការងារ




*ប្រភព: រូបនេះដកស្រង់ និងរចនាឡើងវិញចេញពី Sparreboom, T (1999: 3)*


តទៅទំព័របន្ទាប់

### ៣.១. យន្តការប្រមូលព័ត៌មានទីផ្សារការងារ

ដូចដែលបានកំណត់ដោយរាជរដ្ឋាភិបាលនៅក្នុងអនុក្រឹត្យលេខ ១១៧ ខាងដើម ទ.ជ.ម.ក ជាអង្គភាពស្ថិតិដែលបានចាត់តាំងដែលជាផ្នែកមួយនៃប្រព័ន្ធស្ថិតិជាតិទាំងមូលទទួលបន្ទុកក្នុងការប្រមូលចងក្រង និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារនៅកម្ពុជា ព្រមទាំងអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ (តារាងទី១ និងរូបទី៦)។ នៅក្រោមរចនាសម្ព័ន្ធរបស់ ទ.ជ.ម.ក មានផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មានដែលជាផ្នែកបច្ចេកទេសទទួលបន្ទុកក្នុងការធ្វើកិច្ចការដ៏សំខាន់នេះ។ ទិន្នន័យ និងព័ត៌មានពាក់ព័ន្ធត្រូវបានប្រមូលពីប្រភពចម្បងពីរគឺ៖

*ក) ទិន្នន័យដែលប្រមូលចងក្រង និងវិភាគមានប្រភពពីទ.ជ.ម.ក៖*

- ទិន្នន័យរដ្ឋបាលស្ដីពីការចុះឈ្មោះ អ្នកស្វែងរកការងារធ្វើ និយោជក និងអ្នកផ្ដល់ការអប់រំបណ្ដុះបណ្ដាល
- ទិន្នន័យរដ្ឋបាលស្ដីពីព័ត៌មានជ្រើសរើសបុគ្គលិក និងឱកាសការងារ
- ទិន្នន័យអង្កេតស្ដីពីតម្រូវការជ្រើសរើសបុគ្គលិកក្នុងពេលអនាគត តាមប្រភេទនៃអាជីព ជំនាញ ការអប់រំ វិស័យ និងតំបន់ភូមិសាស្ត្រ ដោយក្រសួង ស្ថាប័ន រាជរដ្ឋាភិបាល សមាគម អង្គការមិនមែនរដ្ឋាភិបាល
- ទិន្នន័យអង្កេតស្ដីពីការលើស និងកង្វះខាតជំនាញក្នុងពេលបច្ចុប្បន្ន និងពេលអនាគត
- លទ្ធផលការសិក្សាអំពីការងារ និង ព័ត៌មានទីផ្សារការងារសំខាន់ៗដទៃទៀត។



ការអនុវត្តកម្មវិធី *"ផែនការមេ"* (Pilot Project) តាមរយៈការបញ្ជូនមន្ត្រី ទ.ជ.ម.ក ឲ្យចុះទៅតាមមូលដ្ឋានដើម្បីផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំមូលដ្ឋានស្ដីពីយុទ្ធនាការចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ដោយចាប់ផ្ដើមពីខេត្តតាកែវ។ (រូបថត: ឃុំដូងខ្ពស់ ស្រុកបុរីជលសា ខេត្តតាកែវ ខែមិថុនា ឆ្នាំ២០១១)

*ខ) ទិន្នន័យដែលប្រមូល ចងក្រង និងវិភាគ មកពីប្រភពវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៃក្រសួងស្ថាប័នរាជរដ្ឋាភិបាល និងប្រភពផ្សេងៗទៀត៖*

- ទិន្នន័យស្ដីពីការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម និងការព្យាករណ៍ក្នុងពេលអនាគតតាមប្រភេទនៃមុខរបរ ជំនាញ និងវិស័យ
- ទិន្នន័យស្ដីពីប្រាក់ឈ្នួល និងអត្រាគ្មានការងារធ្វើ ក្នុងពេលបច្ចុប្បន្ន និងការព្យាករណ៍ក្នុងពេលអនាគត
- ព័ត៌មានស្ដីពីការអប់រំបណ្ដុះបណ្ដាល និងតម្រូវការការអប់រំ បណ្ដុះបណ្ដាលក្នុងពេលបច្ចុប្បន្ន និងការព្យាករណ៍ក្នុងពេលអនាគត
- ព័ត៌មានស្ដីពីការណែនាំអាជីព និងទស្សនវិស័យមុខរបរ ព័ត៌មានស្ដីពីផែនការ និងគម្រោងអភិវឌ្ឍន៍ និងវិនិយោគថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលនិងផ្នែកឯកជនដែលមានទំនាក់ទំនងទៅនឹងទីផ្សារការងារ ព័ត៌មានស្ដីពីគោលនយោបាយ ច្បាប់ កម្មវិធី និងវិធានការទីផ្សារការងារ និងព័ត៌មានទិន្នន័យ និងឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងព័ត៌មានទីផ្សារការងារ។

បន្ទាប់ពីបានប្រមូលបាន និងរៀបចំបញ្ចូលជាទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ ព័ត៌មានទាំងនោះនឹងត្រូវធ្វើការសិក្សា វិភាគដោយបែងចែកទៅតាមប្រភេទ និងក្រុមផ្សេងៗ ដើម្បីជាប្រយោជន៍ និងបង្កភាពងាយស្រួលដល់ការប្រើប្រាស់នៅពេលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។




*(រូបឆ្វេង)៖* ទ.ជ.ម.ក មានយុទ្ធនាការប្រមូលព័ត៌មានទីផ្សារការងារតាមរយៈការផ្សព្វផ្សាយ និងចុះឈ្មោះអ្នកស្វែងរកការងារធ្វើដល់ទីកន្លែង តាមរយៈការផ្សព្វផ្សាយនៅតាមសាកលវិទ្យាល័យនានា តាមពិព័រណ៍ចល័ត និងវេទិកាអាជីពជាដើម។ ឧទាហរណ៍ នៅក្នុងអំឡុងខែមិថុនា ឆ្នាំ២០១១ មានការប្រារព្ធពិធី *"វេទិកាអាជីព"* (Career Forum) នៅឯមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ ថ្ងៃទី២៥-២៦ ខែមិថុនា និងមួយទៀតគឺ *"ពិព័រណ៍ការងារ"* (Job Fair) នៅឯវិទ្យាស្ថានជាតិអប់រំ ថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០១១។ នាឱកាសនោះមានសិស្ស និស្សិត និងមហាជនច្រើនកុះករចាប់អារម្មណ៍ចោមរោមសាកសួរព័ត៌មានអំពីសេវាការងាររបស់ទ.ជ.ម.ក និងបានចុះឈ្មោះស្វែងរកការងារធ្វើយ៉ាងសន្ធឹកសន្ធាប់ផងដែរ។ (រូបថត: វេទិកាអាជីពនៅកោះពេជ្រ ខែមិថុនា ឆ្នាំ២០១១)

តទៅទំព័របន្ទាប់

តារាងទី១: ការសង្ខេបអំពីការប្រមូលព័ត៌មានទីផ្សារការងាររបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ

| ប្រភេទទិន្នន័យ | ជាតុផ្សំរបស់ទិន្នន័យ | ប្រភពនៃទិន្នន័យ |
|---|---|---|
| . ទិន្នន័យសេដ្ឋកិច្ច | . កំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ (GDP)<br>. អតិផរណា | គណនេយ្យជាតិ (វិទ្យាស្ថានជាតិស្ថិតិ) |
| . ប្រជាពលរដ្ឋ<br>. កម្លាំងពលកម្ម<br>. ភាពមានការងារធ្វើ និងនិកម្មភាព | . ប្រជាពលរដ្ឋ និងប្រជាសាស្ត្រ<br>. ការព្យាករណ៍កំណើនប្រជាសាស្ត្រ<br>. ការធ្វើចំណាកស្រុក<br>. ការចូលរួមក្នុងកម្លាំងពលកម្ម<br>. អត្រាប្រជាជនមានការងារធ្វើ<br>. អត្រាមានការងារធ្វើតាមតួនាទី<br>. មុខរបរ<br>. ផ្នែក ឬទីតាំងភូមិសាស្ត្រ<br>. អត្រាគ្មានការងារធ្វើ<br>. យុវជនមានការងារធ្វើ និងគ្មានការងារធ្វើ<br>. ការងារក្រៅប្រព័ន្ធ<br>. ពលកម្មកុមារ ។ល។ | . អង្កេតស្តីពីកម្លាំងពលកម្ម<br>. ជំរឿនទូទៅនូវប្រជាពលរដ្ឋឆ្នាំ១៩៩៨ និង២០០៨ (វិទ្យាស្ថានជាតិស្ថិតិ)<br>. អង្កេតស្តីពីសង្គមសេដ្ឋកិច្ច (វិទ្យាស្ថានជាតិស្ថិតិ)<br>. ជំរឿនសេដ្ឋកិច្ច (វិទ្យាស្ថានជាតិស្ថិតិ) |
| . ផ្នែកតម្រូវការ (កម្លាំងពលកម្ម) | . ឱកាសការងារ<br>. ការងារដែលនឹងមានក្នុងពេលខាងមុខ<br>. ការព្យាករណ៍អំពីមុខរបរ និងឧស្សាហកម្ម<br>. ភាពគ្មានការងារក្នុងរយៈពេលវែង<br>. ការកាត់បន្ថយបុគ្គលិក<br>. ចំនួនរោងចក្រ ឬសហគ្រាស<br>. អត្រាប្រាក់ឈ្នួល ឬប្រាក់ខែ<br>. គម្រោងវិនិយោគថ្មីៗ<br>. ការចាប់ផ្តើមបង្កើតមុខរបរថ្មីៗ ។ល។ | . ទ.ជ.ម.ក (ទិន្នន័យរដ្ឋបាល និងអង្កេត និយោជក)<br>. អង្កេតស្តីពីកម្លាំងពលកម្ម (វិទ្យាស្ថានជាតិស្ថិតិ)<br>. អង្កេតស្តីពីសង្គមសេដ្ឋកិច្ច (វិទ្យាស្ថានជាតិស្ថិតិ)<br>. ជំរឿនទូទៅនូវប្រជាពលរដ្ឋឆ្នាំ១៩៩៨ និង២០០៨ (វិទ្យាស្ថានជាតិស្ថិតិ)<br>. ជំរឿនសេដ្ឋកិច្ច (វិទ្យាស្ថានជាតិស្ថិតិ)<br>. ទិន្នន័យរដ្ឋបាលរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ក្រសួងពាណិជ្ជកម្ម |
| . ផ្នែកផ្គត់ផ្គង់ (កម្លាំងពលកម្ម) | . ចំនួនអ្នកស្វែងរកការងារធ្វើតាមកម្រិតអប់រំ និងតាម មុខរបរ<br>. ចំនួនអ្នកចុះឈ្មោះចូលរៀន និងអ្នកបានបញ្ចប់ការសិក្សា និង វគ្គបណ្តុះបណ្តាល<br>. អ្នកទើបចូលរួមក្នុងកម្លាំងពលកម្ម ។ល។<br>. ការទទួលបានការអប់រំ<br>. ការព្យាករណ៍សម្រាប់ផ្នែកផ្គត់ផ្គង់ (កម្លាំងពលកម្ម) | . ទ.ជ.ម.ក (ទិន្នន័យរដ្ឋបាល)<br>. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិង ក្រសួងអប់រំ យុវជន និងកីឡា (ទិន្នន័យរដ្ឋបាល)<br>. អង្កេតស្តីពីកម្លាំងពលកម្ម (វិទ្យាស្ថានជាតិស្ថិតិ)<br>. ជំរឿនទូទៅនូវប្រជាពលរដ្ឋឆ្នាំ១៩៩៨ និង២០០៨ (វិទ្យាស្ថានជាតិស្ថិតិ) |
| . ព័ត៌មានស្តីពីការអប់រំ និងការបណ្តុះបណ្តាល | . គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាល<br>. កម្មវិធីសិក្សា<br>. មុខវិជ្ជាសិក្សា<br>. ការជួយជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុ | . ទ.ជ.ម.ក (ទិន្នន័យរដ្ឋបាល) |
| . ទិន្នន័យស្ថិតក្នុងប្រភេទផ្សេងៗទៀតដែលនឹងត្រូវ កំណត់នាពេលក្រោយ | . សហជីព<br>. ការគាំពារសង្គម<br>. គ្រោះថ្នាក់ក្នុងការងារ<br>. គម្រោង ឬកម្មវិធីផ្នែកទីផ្សារការងារ<br>. ការងារដែលពាក់ព័ន្ធទៅនឹងក្របខណ្ឌនិតិវិធីនានា | . ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ទិន្នន័យរដ្ឋបាល) |

រូបទី៦: គំនូសសង្ខេបពីការប្រមូលព័ត៌មានទីផ្សារការងារ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ




### ៣.២. លទ្ធផល និងទិសដៅ

ជាទិដ្ឋភាពរួម ទ.ជ.ម.ក កំពុងរៀបចំកសាង និងអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ព្រមទាំងបានប្រមូលចងក្រង និងផ្សព្វផ្សាយនូវព័ត៌មានជាមូលដ្ឋានគឺ ព័ត៌មានស្តីអំពីអ្នកស្វែងរកការងារធ្វើ ការជ្រើសរើសបុគ្គលិក និងវគ្គអប់រំបណ្តុះបណ្តាល។ នៅក្នុងពេលអនាគត ទ.ជ.ម.ក នឹងខិតខំប្រមូលព័ត៌មាន និងទិន្នន័យសំខាន់ៗដទៃទៀត ដើម្បីធ្វើការវិភាគ សំយោគ និងផ្សព្វផ្សាយជាសាធារណៈ ទៅតាមមធ្យោបាយដែលអ្នកប្រើប្រាស់ងាយទទួលបាន។ ជាក់ស្តែង នៅក្នុងព្រឹត្តិបត្រនេះគ្រង់ជំពូកស្តីពី **"ស្ថានភាពទីផ្សារការងារនៅកម្ពុជា"** មានមួយផ្នែក ទ.ជ.ម.ក បានបង្ហាញទិន្នន័យសំខាន់ៗមួយចំនួនដែលស្ថាប័នខ្លួនបានផលិត។ ដើម្បីឱ្យការប្រមូលព័ត៌មានកាន់តែមានប្រសិទ្ធិភាព និងបម្រើតាមតម្រូវការអ្នកប្រើប្រាស់បានទាន់ពេលវេលា ទ.ជ.ម.ក និងខិតខំអភិវឌ្ឍន៍ និងបង្កើនសមត្ថភាពមន្ត្រីរបស់ខ្លួនក្នុងវិស័យនេះឱ្យកាន់តែស៊ីជម្រៅ។ នៅផ្នែកបន្ទាប់នៃអត្ថបទនេះ ទ.ជ.ម.ក បានភ្ជាប់មកជាមួយនូវព័ត៌មានជ្រើសរើសបុគ្គលិកដែលត្រូវបានប្រមូលពីនិយោជកផ្សេងៗ។ លើសពីនេះទៀត ដើម្បីឆ្លុះបញ្ចាំងពីឱកាសការងារ និងតម្រូវការកម្លាំងពលកម្មទៅតាមប្រភេទផ្សេងនៃមុខរបរ ឬការងារដែលមានសកម្មភាពនៅក្នុងទីផ្សារការងារនាពេលបច្ចុប្បន្ន ការបង្ហាញនេះក៏ជាការផ្តល់ឱកាសថ្មីមួយបន្ថែមទៀតសម្រាប់អ្នកស្វែងរកការងារធ្វើដែលមានបំណងបំពេញការងារណាមួយទៅតាមជំនាញ និងចំណូលចិត្តរបស់ខ្លួន គេអាចដាក់ពាក្យសុំការងារទាំងនោះដោយងាយស្រួលនៅតាមមជ្ឈមណ្ឌលការងារណាមួយ ឬនៅលើគេហទំព័ររបស់ ទ.ជ.ម.ក ដែលមានឈ្មោះ www.nea.gov.kh ។

និយោជកដែលកំពុងត្រូវការជ្រើសរើសបុគ្គលិក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាលក៏អាចប្រើប្រាស់ផ្នែកនេះដើម្បីធ្វើការផ្សព្វផ្សាយដោយឥតគិតថ្លៃ និងងាយស្រួល នូវព័ត៌មានជ្រើសរើសបុគ្គលិក ឬវគ្គអប់រំបណ្តុះបណ្តាលរបស់ខ្លួនបានយ៉ាងឆាប់រហ័ស និងគ្របដណ្តប់លើវិសាលភាពយ៉ាងទូលំទូលាយនៅព្រះរាជាណាចក្រកម្ពុជា៕

# ស្ថានភាព ទីផ្សារការងារ នៅកម្ពុជា
# Labor Market in Cambodia

## ១. ស្ថានភាពទីផ្សារការងារនៅប្រទេសកម្ពុជា

មុននឹងពិនិត្យមើលពីស្ថានភាពទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា គេគួរតែស្វែងយល់ និងពិនិត្យទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជា ដើម្បីអាចកំណត់បានពីនិន្នាការចាំបាច់មួយចំនួនដូចជា តម្រូវការកម្លាំងពលកម្ម និងការផ្គត់ផ្គង់កម្លាំងពលកម្ម ជាដើមដែលជានិច្ចកាលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងស្ថានភាពទូទៅនៃកំណើន ឬក៏ការធ្លាក់ចុះរបស់សេដ្ឋកិច្ច។ អត្ថបទនេះនឹងពិនិត្យមើលជាសង្ខេបទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលឋិតក្នុងចន្លោះឆ្នាំ ១៩៩៨ និងឆ្នាំ២០១០ ដើម្បីអាចយល់បានពីការប្រែប្រួលក្នុងដំណាក់កាលជាងមួយទស្សវត្សន៍កន្លងមកនេះ ក៏ដូចជាកត្តាចាំបាច់ដើម្បីឈានទៅតម្រង់ទិសស្ថានភាពទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា។

### ១.២. *ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា*

#### ១.២.១. *អត្រាកំណើនផលិតផលក្នុងស្រុកសរុប* (GDP)

ចាប់ពីឆ្នាំ១៩៩៥ បន្ទាប់ពីទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨មក សេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកសរុបរហូតដល់ពីរខ្ទង់។ អត្រាកំណើននេះបានបង្ហាញពីដំណើរការល្អនៃបរិស្ថានសេដ្ឋកិច្ច ទីផ្សារការងារ គោលនយោបាយអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា កំណើនវិនិយោគទុនបរទេស -ល- របស់ប្រទេសដែលទើបចេញពីសង្គ្រាម។ កត្តាដែលសំខាន់មួយទៀតនោះគឺការរក្សាបានស្ថិរភាពនយោបាយនៅក្នុងប្រទេស ដែលជាការអនុវត្តដ៏ជោគជ័យនូវគោលនយោបាយបង្រួបបង្រួមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ទាំងអស់នេះជាកត្តាចលករដ៏សំខាន់បំផុតដែលបានបង្កលទ្ធភាពងាយស្រួលដល់ការអភិវឌ្ឍប្រទេស និងជាពិសេសអភិវឌ្ឍវិស័យសេដ្ឋកិច្ចនៅកម្ពុជា។ ប្រសិនពិនិត្យមើលទៅលើតួលេខនៃអត្រាកំណើនក្នុងឆ្នាំទាំងនោះ នៅឆ្នាំ១៩៩៨ កម្ពុជាមានអត្រាកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំត្រឹមតែ ៥.០% ប៉ុណ្ណោះ យ៉ាងណាមិញ អត្រាកំណើនបានចាប់ផ្តើមមានសន្ទុះខ្លាំងក្លានាឆ្នាំបន្ទាប់ៗដូចជា ក្នុងឆ្នាំ១៩៩៩ (១១.៩%) ឆ្នាំ២០០៥ (១៣.៣%) ឆ្នាំ២០០៧ (១០.២%) ជាដើម។

ទោះបីជាកំឡុងពេលនៃវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសាកលលោកដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៧ ក៏កម្ពុជាអាចទទួលបាននូវអត្រាកំណើនវិជ្ជមាននៃផលិតផលក្នុងស្រុកសរុប០.១%នៅក្នុងឆ្នាំ២០០៩ វិស័យដែលទទួលរងនូវផលប៉ះពាល់គួរឱ្យកត់សម្គាល់គឺវិស័យកាត់ដេរ សំណង់ ទេសចរណ៍ និងអចលនទ្រព្យ។ ទោះជាយ៉ាងណាក្តី នៅក្នុងឆ្នាំ២០១០ សេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញក្នុងទម្រង់ជាអក្សរវី(V) គឺអាស្រ័យដោយសារការរីកចម្រើននៃវិស័យកសិកម្ម និងការងើបឡើងវិញនៃវិស័យសំខាន់ៗដែលទទួលរងផលប៉ះពាល់ខ្លាំងនាពេលមានវិបត្តិ។ ជាក់ស្តែង អត្រាកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ២០១០ បានកើនឡើងដល់ ៥.៩% (រូបទី៧ ) ហើយការព្យាករណ៍ក្នុងពេលអនាគតបង្ហាញឱ្យឃើញនូវទស្សនវិស័យល្អនៃអត្រាកំណើនក្នុងឆ្នាំបន្ទាប់ៗគឺក្នុងឆ្នាំ ២០១១ (៦%) ក្នុងឆ្នាំ២០១២(៦.៥%) និងក្នុងឆ្នាំ២០១៣ (៧%)។

រូបទី៧ : អត្រាកំណើនផលលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំរបស់កម្ពុជាពីឆ្នាំ១៩៩៨ ដល់២០១៣p (គិតតាមថ្លៃថេរ)




*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១១)*


តទៅទំព័របន្ទាប់

### ១.២.២. សេដ្ឋកិច្ចតាមវិស័យ

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ជារួមពឹងផ្អែកលើវិស័យសំខាន់ៗចំនួនបីរួមមាន៖ កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ក្នុងអំឡុងពេលជាងមួយទសវត្សន៍កន្លងមកនេះ បមាណភាគនៃការរួមចំណែករបស់វិស័យសំខាន់ៗទាំងបីនៅក្នុងផលិតផលក្នុងស្រុកសរុបមានការប្រែប្រួលទោះបីជាសេដ្ឋកិច្ចកម្ពុជានឹងពឹងផ្អែកជាសំខាន់ទៅលើវិស័យទាំងបីនេះក៏ដោយ។ រូបទី៨ ខាងក្រោមបង្ហាញឱ្យឃើញថានៅក្នុងឆ្នាំ១៩៩៨ បមាណភាគនៃវិស័យកសិកម្មមានអត្រាប្រមាណ ៤៤.៥% វិស័យឧស្សាហកម្ម ១៦.៧% និង វិស័យសេវាកម្ម ៣៤.៨%។ ដោយឡែកក្នុងឆ្នាំ២០១០ បមាណភាគនៃវិស័យកសិកម្មបានថយចុះមកនៅត្រឹមអត្រា ៣៣.៨% ខណៈពេលដែលវិស័យឧស្សាហកម្មបានកើនឡើងដល់ ២១.៦% និងវិស័យសេវាកម្មក៏បានកើនឡើងដល់៣៨.៥%។ ការប្រែប្រួលរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចជាតិនេះបង្ហាញឱ្យឃើញពីការផ្លាស់ប្តូរពីការពឹងផ្អែកខ្លាំងនៃខឿនសេដ្ឋកិច្ចជាតិលើវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម ឬដំណើរការឧស្សាហូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជាបានកើនឡើងដែលឆ្លុះបញ្ចាំងឱ្យឃើញនូវការផ្លាស់ប្តូរជាបណ្តើរៗពីប្រទេសកសិកម្ម ទៅប្រទេសឧស្សាហកម្មដូចប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនលើពិភពលោកបច្ចុប្បន្ន បានឆ្លងកាត់នៅក្នុងដំណើរការអភិវឌ្ឍន៍របស់គេ។

រូបទី៨: បមាណាទាគតាមវិស័យនៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា ឆ្នាំ១៩៩៨ ដល់ ២០១៣p




*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១១)*

បើពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅថែមទៀត គេសង្កេតឃើញថាអនុវិស័យសំខាន់ៗចំនួន ៩ បានរួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចកម្ពុជាដែលរួមមាន៖ ដំណាំ ជលផល ការចិញ្ចឹមសត្វ សំណង់ ដឹកជញ្ជូននិងទូរគមនាគមន៍ សណ្ឋាគារនិងភោជនីយដ្ឋាន កាត់ដេរ ពាណិជ្ជកម្ម និងអចលនទ្រព្យ (រូបទី៩)។ នេះបង្ហាញថាមូលដ្ឋានសេដ្ឋកិច្ចកម្ពុជានៅមានលក្ខណៈតូចចង្អៀត ហើយការធ្វើពិពិធកម្មសេដ្ឋកិច្ចទៅកាន់វិស័យផ្សេងៗទៀតគឺការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន។ ប្រការនេះបានឆ្លុះបញ្ចាំងឱ្យឃើញអំពីលទ្ធភាពនៃការចូលរួមរបស់កម្លាំងពលកម្ម និងតម្រូវការកម្លាំងពលកម្ម ក៏ដូចជាបានបង្ហាញពីរចនាសម្ព័ន្ធទូទៅនៃទីផ្សារការងាររបស់ប្រទេសកម្ពុជាផងដែរ។ រចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ និងការប្រែប្រួលកន្លងមកមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅលើរចនា-សម្ព័ន្ធនៃទីផ្សារការងាររបស់កម្ពុជា ជាពិសេសប្រភេទនៃមុខរបរ សកម្មភាពសេដ្ឋកិច្ច តម្រូវការជំនាញ និងលំហូរនៃកម្លាំងពលកម្មពីជនបទមកទីក្រុង ឬមកកាន់តំបន់ឧស្សាហកម្ម។ បើពិនិត្យមើលលើនិន្នាការបច្ចុប្បន្ននេះ គេអាចព្យាករណ៍បានថានៅថ្ងៃអនាគតការផ្ទេរចេញនូវកម្លាំងពលកម្មពីជនបទមកទីក្រុងនឹងមានល្បឿនកាន់តែលឿនឡើងដែលកត្តានេះមានបច្ច័យជាសំខាន់ដល់ទីផ្សារការងារ និងគោលនយោបាយពាក់ព័ន្ធ។

តទៅទំព័របន្ទាប់

រូបទី៩: បមាណភាគនៃវិស័យសំខាន់ចំនួន៩ ក្នុងផលិតផលក្នុងស្រុកសរុបពីឆ្នាំ១៩៩៨ ដល់ ២០១៣p




ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១១)

ដូច្នេះប្រសិនបើយោងទៅលើនិន្នាការសេដ្ឋកិច្ចដូចបានរៀបរាប់ពីខាងដើមឃើញថា ការងើបឡើងវិញជាបណ្តើរៗនៃសេដ្ឋកិច្ចពិភពលោកបន្ទាប់ពីមានការធ្លាក់ចុះ ក៏បានផ្តល់ឥទ្ធិពលវិជ្ជមានផងដែរសម្រាប់ការពង្រឹងឡើងវិញនូវសេដ្ឋកិច្ចកម្ពុជាលើគ្រប់វិស័យ។ ម្យ៉ាងទៀត ការចាប់ផ្តើមមានសន្ទុះខ្លាំងឡើងវិញនៃអត្រាកំណើននឹងបង្កើតឱកាសការងារ និងតម្រូវការនូវកម្លាំងពលកម្មបន្ថែមទៀតសម្រាប់ការចូលរួមចំណែកក្នុងការពង្រីកផលិតកម្មនៃផលិតផល និងសេវាកម្មក្នុងពេលបច្ចុប្បន្ន និងអនាគតដ៏ខ្លីខាងមុខ។ ដូច្នេះការពិនិត្យមើលអំពីសូចនាករកម្លាំងពលកម្ម អត្រានិកម្មភាព និងព័ត៌មានទីផ្សារការងារជារួមនឹងក្លាយជាទិន្នន័យគោលសម្រាប់ការស្វែងយល់ និងតម្រង់ទិសការអភិវឌ្ឍវិស័យការងារ និងទីផ្សារការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. ស្ថានភាពកម្លាំងពលកម្មនៅប្រទេសកម្ពុជា

### ២.១. *ប្រជាពលរដ្ឋសរុបក្នុងឆ្នាំ ១៩៩៨ និង២០០៨*

ប្រជាពលរដ្ឋកម្ពុជាសរុបបានកើនឡើងពីចំនួនប្រមាណ ១១.៤ លាននាក់ក្នុងឆ្នាំ១៩៩៨ ទៅ ១៣.៤ លាននាក់ក្នុងឆ្នាំ២០០៨ ក្នុងអត្រាកំណើនមធ្យម ១.៥% ក្នុងមួយឆ្នាំ។ កំណើនប្រជាពលរដ្ឋនៅទីក្រុង(២.២%) មានអត្រាខ្ពស់ជាងនៅតាមតំបន់ជនបទ (១.៤%)។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺបមាណភាគនៃប្រជាពលរដ្ឋអាយុពី ២៥-៥៤ឆ្នាំ បានកើនឡើង ពី៣១.៤% ទៅ ៣៤.៧% និងប្រជាពលរដ្ឋដែលជាយុវវ័យ (អាយុ ១៥-២៤ឆ្នាំ) បានកើនឡើងពី១៨.៣% ទៅ ២២.៣% ក្នុងចន្លោះពេលដូចគ្នានេះ (រូបទី១០)។

រូបទី១០: ការបែងចែកប្រជាពលរដ្ឋសរុប ក្នុងឆ្នាំ១៩៩៨ និង២០០៨ តាមក្រុមអាយុ (គិតជា%)




*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ២០០៨*

#### ២.១.១ *កម្លាំងពលកម្ម*

##### ២.១.១.១ *កម្លាំងពលកម្មសរុបក្នុងឆ្នាំ១៩៩៨ និង២០០៨*

ក្នុងចន្លោះឆ្នាំ១៩៩៨ ដល់ ២០០៨ កម្លាំងពលកម្មសរុបរបស់កម្ពុជា(អាយុចាប់ពី១៥ឆ្នាំឡើង)មានការកើនឡើងពីប្រមាណ៥លាននាក់ទៅជិត៧.០ លាននាក់ ក្នុងអត្រាកំណើនជាមធ្យម ៣.៣% ក្នុងមួយឆ្នាំ។ កម្លាំងពលកម្មយុវវ័យអាយុពី ១៥-២៤ ឆ្នាំមានការកើនឡើងពីចំនួនជិត ១.៣ លាននាក់ ទៅជិត ១.៨ លាននាក់ ហើយកម្លាំងពលកម្មអាយុចាប់ពី ២៥ ឆ្នាំឡើង បានកើនឡើងពីចំនួនជិត ៣.៨ លាននាក់ទៅជិត ៥.២ លាននាក់ (រូបទី១១ និងតារាងទី២)។


តទៅទំព័របន្ទាប់

រូបទី១១: កម្លាំងពលកម្មសរុប ក្នុងឆ្នាំ១៩៩៨ និង២០០៨




*ប្រភព: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨*

តារាងទី២: កម្លាំងពលកម្មសរុបរបស់កម្ពុជាអាយុពី១៥ឆ្នាំឡើង (ក្នុងឆ្នាំ១៩៩៨ និង២០០៨)

| | 1998 | 2008 |
|---|---|---|
| ***កម្លាំងពលកម្មសរុប*** | **5,038,382** | **6,955,640** |
| បុរស | 2,443,580 | 3,396,449 |
| នារី | 2,594,802 | 3,559,191 |
| ទីក្រុង ឬទីប្រជុំជន | 850,135 | 1,283,328 |
| ជនបទ | 4,188,247 | 5,672,312 |
| ***ចំនួនប្រជារាស្ត្រសរុបស្ថិតក្នុងវ័យធ្វើការ*** | **6,539,848** | **8,881,890** |
| បុរស | 3,009,001 | 4,201,248 |
| នារី | 3,530,847 | 4,680,642 |
| ទីក្រុង ឬទីប្រជុំជន | 1,325,949 | 1,949,676 |
| ជនបទ | 5,213,899 | 6,932,214 |

ប្រភព: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨

## *២.២ ការចូលរួមក្នុងកម្លាំងពលកម្ម*

យោងតាមទិន្នន័យក្នុងចន្លោះឆ្នាំ១៩៩៨-២០០៨ អត្រាចូលរួមនៃកម្លាំងពលកម្មសរុបអាយុចាប់ពី១៥ឆ្នាំឡើង បានកើនឡើងបន្តិចពី ៧៧% ទៅ ៧៨.៣% (រូបទី១២ និងតារាងទី៣) ដែលក្នុងនោះអត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រីមានការកើនឡើងពី ៧៣.៥% ទៅ ៧៦.០% ចំណែកឯអត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់បុរសមានការថយចុះបន្តិចពី ៨១.២% ទៅ ៨០.០%។ ការចូលរួមក្នុងកម្លាំងពលកម្មរបស់យុវវ័យអាយុពី ១៥-២៤ ឆ្នាំ មានអត្រាថយចុះបន្តិច ហើយការចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រជារាស្ត្រចាប់ពីអាយុ២៥ឆ្នាំឡើងបានកើនឡើងពី ៨៤.៧% ទៅ ៨៧.៥%។

រូបទី១២: អត្រាចូលរួមកម្លាំងពលកម្មក្នុងឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ តាមក្រុមនៃអាយុ




*ប្រភព: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ២០០៨*

តទៅទំព័របន្ទាប់

តារាងទី៣: អត្រាចូលរួមនៃកម្លាំងពលកម្មសរុប អាយុពី១៥ឆ្នាំ ឡើង (ឆ្នាំ១៩៩៨ និង ២០០៨)

| អត្រាចូលរួមនៃកម្លាំងពលកម្មសរុប (គិតជា %) | 1998 | 2008 |
|---|---|---|
| | 77.0 | 78.3 |
| បុរស | 81.2 | 80.8 |
| នារី | 73.5 | 76.0 |
| ទីក្រុង ឬទីប្រជុំជន | 64.1 | 65.8 |
| ជនបទ | 80.3 | 81.8 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨*

## ២.៣. ប្រជារាស្ត្រមានការងារធ្វើក្នុងឆ្នាំ ១៩៩៨ និង២០០៨

ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០៨ កម្លាំងពលកម្មអាយុ១៥ឆ្នាំ ឡើង ដែលមានការងារធ្វើបានកើនឡើងពីចំនួនជិត ៤.៨ លាននាក់ ទៅជាង ៦.៨ លាននាក់ ក្នុងអត្រាកំណើនជាមធ្យម ៣.៦%ក្នុងមួយឆ្នាំ (រូបទី១៣ និងតារាងទី៤)។ ព្រមជាមួយគ្នានេះចំនួនកម្លាំងពលកម្មយុវវ័យអាយុពី១៥-២៤ឆ្នាំ ដែលមានការងារធ្វើបានកើនពី ១.១ លាននាក់ទៅជាង ១.៧ លាននាក់ ក្នុងអត្រាកំណើនជាមធ្យម ៤.៤% ក្នុងមួយឆ្នាំ។ រីឯចំនួនកម្លាំងពលកម្ម អាយុចាប់ពី ២៥ឆ្នាំឡើង ដែលមានការងារធ្វើបានកើនឡើងពីចំនួនជិត ៣.៧ លាននាក់ ទៅ ៥.១ លាននាក់ ក្នុងអត្រាកំណើនជាមធ្យម ៣.៣% ។

រូបទី១៣: កំណើនចំនួនអ្នកមានការងារធ្វើជាមធ្យមប្រចាំឆ្នាំ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៨




*ប្រភព: ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ២០០៨*

តារាងទី៤: អត្រា និងចំនួនប្រជារាស្ត្រមានការងារធ្វើបែងចែកតាមភេទ និងទីក្រុង/ជនបទ ក្នុងឆ្នាំ១៩៩៨ និង២០០៨

| អត្រាអ្នកមានការងារធ្វើសរុប (%) | 1998 | 2008 |
|---|---|---|
| | 73.0 | 77.0 |
| បុរស | 77.4 | 79.6 |
| នារី | 69.2 | 74.7 |
| ទីក្រុង ឬទីប្រជុំជន | 57.0 | 62.9 |
| ជនបទ | 77.0 | 81.0 |
| **ចំនួនអ្នកមានការងារធ្វើសរុប** | 4,773,488 | 6,841,272 |
| បុរស | 2,330,301 | 3,345,926 |
| នារី | 2,443,187 | 3,495,346 |
| ទីក្រុង ឬទីប្រជុំជន | 756,420 | 1,225,965 |
| ជនបទ | 4,017,068 | 5,615,307 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨*

តទៅទំព័របន្ទាប់

## ២.៤. *ការបែងចែកប្រជាពលរដ្ឋមានការងារធ្វើតាមវិស័យ*

បើពិនិត្យមើលតាមវិស័យសំខាន់ទាំងបីដូចបង្ហាញជូននៅក្នុងរូបទី៨ និងតារាងទី៤ ខាងក្រោមនេះ នៅក្នុងឆ្នាំ២០០៨ ក្នុងចំណោមអ្នកមានការងារធ្វើសរុប (អាយុចាប់ពី ១៥ឆ្នាំឡើង) ក្នុងអត្រា ៧២.១% បានធ្វើការក្នុងវិស័យកសិកម្មដែលមានការថយចុះពីអត្រា ៧៥.៦% ក្នុងឆ្នាំ១៩៩៨។ ចំណែកឯអ្នកធ្វើការងារក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មវិញបានកើនឡើងពីអត្រា ៤.២% ទៅ ៨.៦% និងពី ១៨.៣% ទៅ ១៩.៣% ក្នុងចន្លោះឆ្នាំដូចគ្នា។ បើពិនិត្យមើលតាមឋានៈក្នុងការងារវិញមានភាគច្រើនលើសដល់ (៨៣.០%) នៃអ្នកមានការងារធ្វើក្នុងឆ្នាំ២០០៨ ជាអ្នកដែលធ្វើការក្នុងគ្រួសារ និងប្រើទុនផ្ទាល់ខ្លួនទោះបីជាអត្រានេះមានការថយចុះបើប្រៀបធៀបទៅនឹងឆ្នាំ១៩៩៨ ដែលមានកម្រិត(៨៦.០%) (រូបទី១៤ និងតារាងទី៥)។

**រូបទី១៤: ការបែងចែកប្រជាពលរដ្ឋមានការងារធ្វើតាមវិស័យក្នុងឆ្នាំ១៩៩៨ និងឆ្នាំ២០០៨**




*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ២០០៨*

**តារាងទី៥: ការបែងចែកប្រជាពលរដ្ឋមានការងារធ្វើតាមវិស័យក្នុងឆ្នាំ១៩៩៨ និង ២០០៨ (គិតជា %)**

| *វិស័យការងារ* | *១៩៩៨* | | | *២០០៨* | | |
|---|---|---|---|---|---|---|
| | *សរុប* | *ស្រី* | *ប្រុស* | *សរុប* | *ស្រី* | *ប្រុស* |
| វិស័យកសិកម្ម | 75.6 | 81.8 | 69 | 72.1 | 75 | 69.2 |
| វិស័យឧស្សាហកម្ម | 4.2 | 3.5 | 5.0 | 8.6 | 9.0 | 8.1 |
| វិស័យសេវាកម្ម | 18.3 | 13.5 | 23.4 | 19.3 | 16.0 | 22.7 |
| មិនមានបញ្ជាក់ | 1.9 | 1.3 | 2.5 | 0.0 | 0.0 | 0.0 |
| *សរុប* | 4,773,488 | 2,443,187 | 2,330,301 | 6,841,272 | 3,495,346 | 3,345,926 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨*

**រូបទី១៥: ភាគរយនៃអ្នកមានការងារធ្វើគិតតាមឋានៈការងារ**




*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ២០០៨*

តទៅទំព័របន្ទាប់

តារាងទី៦: អ្នកមានការងារធ្វើគិតតាមឋានៈក្នុងការងារ (%)

| អ្នកមានការងារធ្វើ (%) | 1998 | | | 2008 | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ប្រុស | សរុប | ស្ត្រី | ប្រុស |
| និយោជក | 0.2 | 0.1 | 0.2 | 0.1 | 0.1 | 0.2 |
| និយោជិត (ដែលទទួលប្រាក់ខែពីការងារ) | 12.3 | 6.3 | 18.6 | 17.3 | 14.0 | 20.7 |
| កម្មករនិយោជិតដែលមានមុខរបរផ្ទាល់ខ្លួន | 45.9 | 31.0 | 61.5 | 39.6 | 25.3 | 54.5 |
| កម្មករនិយោជិតដែលជួយបម្រើកិច្ចការក្នុងគ្រួសារ | 40.9 | 62.1 | 18.6 | 42.9 | 60.6 | 24.5 |
| ក្រុមផ្សេងៗ ឬមិនមានព័ត៌មាន | 0.8 | 0.5 | 1.1 | 0.1 | 0.0 | 0.1 |
| *សរុប* | 100 | 100 | 100 | 100 | 100 | 100 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨*

## *២.៥. ការបែងចែកប្រភេទមុខរបរគិតតាមកម្រិតអប់រំក្នុងចំណោមកម្លាំងពលកម្មចន្លោះពីអាយុ ២០ - ២៩ឆ្នាំ (ឆ្នាំ២០០៩)*

យោងតាមទិន្នន័យអង្កេតស្តីពីសង្គមសេដ្ឋកិច្ចនៅកម្ពុជានាឆ្នាំ២០០៩ បានបង្ហាញពីលទ្ធភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងចំណោមប្រភេទមុខរបរចំនួនដប់ដែលបែងចែកទៅតាមកម្រិតសិក្សា (រូបទី១៦)។ ក្នុងចំណោមប្រភេទមុខរបរទាំងដប់ ឃើញថាភាគរយសរុបនៃប្រភេទមុខរបរដែលមានលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មច្រើនជាងគេតាមលំដាប់គឺ មុខរបរក្នុងវិស័យកសិកម្ម (៣៩.៨%) បន្ទាប់មកទៀតមាន មុខរបរផ្នែកសិប្បកម្ម (១៨.៤%) មុខរបរបន្ទាប់បន្សំ (១៥.៧%) មុខរបរផ្នែកសេវាកម្ម និងការលក់ (១៤.៥%) ជាដើម។

ម្យ៉ាងវិញទៀត ប្រសិនពិនិត្យទៅលើការផ្គត់ផ្គង់កម្លាំងពលកម្មពីចំណោមសិស្ស-និស្សិតនៅតាមបណ្តាគ្រឹះស្ថានអប់រំនានា គេសង្កេតឃើញថាភាគរយនៃប្រភេទមុខរបរដែលមានលក្ខណៈបែបបច្ចេកទេស ឬជំនាញវិជ្ជាជីវៈហាក់នៅមានកង្វះខាត ឬមិនទាន់ឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មនៅឡើយទេ អាស្រ័យដោយភាគរយនៅមានកម្រិតទាបក្នុងចំណោមប្រភេទមុខរបរដ៏ទៃទៀតដូចជា៖ អ្នកតំឡើង និងអ្នកបញ្ជាគ្រឿងចក្រ និងម៉ាស៊ីន (៣.២%) អ្នកធ្វើការខាងជំនាញកត់ត្រា (៣.៣%) វិជ្ជាជីវៈ (៣.៣%) និងអ្នកបច្ចេកទេស មានត្រឹមតែ(១.១%) ប៉ុណ្ណោះ។

**រូបទី១៦: ការបែងចែកប្រភេទមុខរបរគិតតាមកម្រិតអប់រំក្នុងចំណោមកម្លាំងពលកម្មចន្លោះពីអាយុ ២០ - ២៩ឆ្នាំ (ឆ្នាំ២០០៩)**



*ប្រភព: ស្ថិតិស្តីពីការអប់រំ (ឆ្នាំ២០០៥ - ២០០៩) ដកស្រង់ចេញពីឯកសាររបស់ The World Bank, (2011). Implementing Cambodia's Growth Strategy after the Crisis: The Skills to Match Cambodia's Aspirations. Page 3.*



តទៅទំព័របន្ទាប់

### ២.៦. អត្រានិស្សិតនៅកម្រិតឧត្តមសិក្សាគិតតាមមុខជំនាញសិក្សាប្រៀបធៀបរវាងប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា

នៅក្នុងរូបទី១៧ ខាងក្រោមបង្ហាញអំពីអត្រានិស្សិតនៅកម្រិតឧត្តមសិក្សាគិតតាមមុខជំនាញសិក្សាប្រៀបធៀបរវាងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា។ យោងទៅតាមទិន្នន័យ បានបង្ហាញថានៅតាមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនដូចជា ជប៉ុន សាធារណរដ្ឋកូរ៉េ ចិន(ហុងកុង) និងប្រទេសដែលកំពុងតែមានសេដ្ឋកិច្ចលូតលាស់ឯទៀតៗដូចជា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី វៀតណាម ជាដើម គេសង្កេតឃើញថាការកំណត់ ឬជ្រើសរើសមុខជំនាញសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សាហាក់មានតុល្យភាពគ្នានៅក្នុងចំណោមមុខជំនាញសិក្សានានា ដោយគិតចាប់ពីជំនាញផ្នែកវិទ្យាសាស្ត្រសង្គម ពាណិជ្ជកម្ម និងច្បាប់ រហូតដល់ជំនាញផ្នែកបច្ចេកទេស ឬវិស្វកម្ម។

ដោយឡែកនៅប្រទេសកម្ពុជា ការបែងចែក ឬជ្រើសរើសមុខជំនាញសិក្សានៅក្នុងចំណោមនិស្សិតនៅឧត្តមសិក្សាហាក់មិនសូវមានតុល្យភាពគ្នានោះទេ។ ក្នុងចំណោមមុខជំនាញសិក្សាដែលមានភាគរយច្រើនជាងគេគឺ វិទ្យាសាស្ត្រសង្គម ពាណិជ្ជកម្ម និងច្បាប់ (៦៦.២%) មនុស្សសាស្ត្រ និងសិល្បៈ (១៣.៩%) វិទ្យាសាស្ត្រ (៩.៤%)។ ចំណែកឯ មុខជំនាញសិក្សាដែលមានភាគរយតិចជាងគេរួមមាន សុខភាព (៣.១%) វិស្វកម្ម រោងចក្រ សហគ្រាស និងសំណង់ (៣.១%) អប់រំ (២.២%) និងកសិកម្ម (២.១%)។

រូបទី១៧: អត្រានិស្សិតនៅកម្រិតឧត្តមសិក្សាគិតតាមមុខជំនាញសិក្សាប្រៀបធៀបរវាងប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា




*ប្រភព: ស្ថិតិស្តីពីការអប់រំ (ឆ្នាំ២០០៥ - ២០០៩) ដកស្រង់ចេញពីឯកសាររបស់ World Bank, (2011). Implementing Cambodia's Growth Strategy after the Crisis: The Skills to Match Cambodia's Aspirations. Page 16.*

តទៅទំព័របន្ទាប់

## ២.៧. អត្រាគ្មានការងារធ្វើក្នុងឆ្នាំ១៩៩៨ និង២០០៨ (គិតជា%)

ក្នុងចន្លោះឆ្នាំ១៩៩៨ ដល់ ២០០៨ អត្រាគ្មានការងារធ្វើនៃកម្លាំងពលកម្មអាយុចាប់ពី១៥ឆ្នាំឡើងបានថយចុះគួរឱ្យកត់សម្គាល់ពីអត្រា ៥.៣% មកនៅត្រឹមតែ ១.៦% (រូបទី១៨)។ ចំពោះកម្លាំងពលកម្មយុវវ័យ អាយុពី ១៥-២៤ ឆ្នាំវិញ អត្រាគ្មានការងារធ្វើបានថយចុះខ្លាំងជាងគេ គឺពី១២.២% មកត្រឹម ៣.៣% ចំណែកឯ អត្រាគ្មានការងារធ្វើនៃកម្លាំងពលកម្មអាយុចាប់ពី២៥ឆ្នាំឡើងបានថយចុះពី ២.៩% មក ១.១%។

**រូបទី១៨: អត្រាគ្មានការងារធ្វើក្នុងឆ្នាំ១៩៩៨ និងឆ្នាំ២០០៨**




*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨*

**តារាងទី៧: អត្រាគ្មានការងារធ្វើក្នុងឆ្នាំ១៩៩៨ និង២០០៨**

| | 1998 | 2008 |
|---|---|---|
| *អត្រាគ្មានការងារធ្វើសរុប (%)* | 5.3 | 1.6 |
| បុរស | 4.6 | 1.5 |
| នារី | 5.8 | 1.8 |
| ទីក្រុង ឬទីប្រជុំជន | 11.0 | 4.5 |
| ជនបទ | 4.1 | 1.0 |
| *ចំនួនអ្នកគ្មានការងារធ្វើសរុប* | 264,894 | 114,368 |
| បុរស | 113,279 | 50,523 |
| នារី | 151,615 | 63,845 |
| ទីក្រុង ឬទីប្រជុំជន | 93,715 | 57,363 |
| ជនបទ | 171,179 | 57,005 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨*


តទៅទំព័របន្ទាប់

### តារាងទី៨: យុវជនក្នុងកម្លាំងពលកម្ម និងគ្មានការងារធ្វើបែងចែកតាមភេទ និងទីក្រុង/ជនបទ ក្នុងឆ្នាំ១៩៩៨ និង២០០៨

| | 1998 | 2008 |
|---|---|---|
| *អត្រាយុវជនគ្មានការងារធ្វើសរុប (%)* | 12.2 | 3.3 |
| បុរស | 12.3 | 3.4 |
| នារី | 12.0 | 3.3 |
| ទីក្រុង ឬទីប្រជុំជន | 22.4 | 7.8 |
| ជនបទ | 10.2 | 2.2 |
| *យុវជនគ្មានការងារធ្វើសរុប (ចំនួន)* | 154,482 | 59,823 |
| បុរស | 70,728 | 29,216 |
| នារី | 83,754 | 30,607 |
| ទីក្រុង ឬទីប្រជុំជន | 45,289 | 28,096 |
| ជនបទ | 109,193 | 31,727 |
| *យុវជនក្នុងកម្លាំងពលកម្មសរុប (ចំនួន)* | 1,268,671 | 1,796,785 |
| បុរស | 572,862 | 858,191 |
| នារី | 695,809 | 938,594 |
| ទីក្រុង ឬទីប្រជុំជន | 202,170 | 358,844 |
| ជនបទ | 1,066,501 | 1,437,941 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨*

### រូបទី១៩: អត្រាគ្មានការងារធ្វើតាមកម្រិតអប់រំ (%)




*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ២០០៨*

### តារាងទី៩: អត្រាគ្មានការងារធ្វើតាមកម្រិតអប់រំ (%)

| *កម្រិតអប់រំ* | 1998 | | | 2008 | | |
|---|---|---|---|---|---|---|
| | សរុប | នារី | បុរស | សរុប | នារី | បុរស |
| មិនបានចូលរៀន | 31.2 | 36.0 | 24.7 | 20.6 | 23.5 | 16.9 |
| មត្តេយ្យសិក្សា | 0.9 | 0.9 | 0.8 | 1.7 | 1.8 | 1.6 |
| បឋមសិក្សា | 38.5 | 39.3 | 37.4 | 29.3 | 30.6 | 27.6 |
| មធ្យមសិក្សា | 28.8 | 23.4 | 36 | 44.7 | 41.1 | 49.3 |
| ឧត្តមសិក្សា | 0.6 | 0.3 | 1.1 | 3.7 | 3.0 | 4.7 |
| *សរុប* | 100 | 100 | 100 | 100 | 100 | 100 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨*

តទៅទំព័របន្ទាប់

តារាងទី១០: ការបែងចែកប្រភេទនៃមុខរបរតាមភេទ និងដោយទីក្រុង/ជនបទ (%) ក្នុងឆ្នាំ១៩៩៨ និង២០០៨

| *ប្រភេទនៃមុខរបរ ឬការងារ* | ១៩៩៨ | | ២០០៨ | |
|---|---|---|---|---|
| | បុរស | នារី | បុរស | នារី |
| *ទីក្រុង ឬទីប្រជុំជន (សរុប)* | 57.3 | 42.7 | 52.9 | 47.1 |
| សមាជិកអង្គនីតិបញ្ញត្តិ មន្ត្រីគ្រប់គ្រងជាន់ខ្ពស់ អ្នកគ្រប់គ្រង | 82.1 | 17.9 | 71.3 | 28.7 |
| អ្នកជំនាញឯកទេសវិជ្ជាជីវៈ | 77.9 | 22.1 | 55.4 | 44.6 |
| អ្នកបច្ចេកទេស និងអ្នកជំនាញឯកទេសវិជ្ជាជីវៈរង | 61.0 | 39.0 | 64.3 | 35.7 |
| ស្មៀន | 70.2 | 29.8 | 64.0 | 36.0 |
| កម្មករនិយោជិតផ្នែកសេវាកម្ម និងបំរើក្នុងហាង និងអ្នកលក់ដូរតាមទីផ្សារ | 42.8 | 57.2 | 39.1 | 60.9 |
| កម្មករជំនាញផ្នែកកសិកម្ម និងនេសាទ | 49.3 | 50.7 | 50.3 | 49.7 |
| កម្មករជំនាញផ្នែកសិប្បកម្ម និងកិច្ចការជំនួញផ្សេងៗ | 69.9 | 30.1 | 42.9 | 57.1 |
| អ្នកបញ្ជា និងផ្គុំតម្លើង ម៉ាស៊ីន និងដំណើរការរោងចក្រ | 66.2 | 33.8 | 94.3 | 5.7 |
| មុខរបរតូចតាចនានា | 47.0 | 53.0 | 66.1 | 33.9 |
| *ជនបទ (សរុប)* | 47.2 | 52.8 | 48.0 | 52.0 |
| សមាជិកអង្គនីតិបញ្ញត្តិ មន្ត្រីគ្រប់គ្រងជាន់ខ្ពស់ អ្នកគ្រប់គ្រង | 95.8 | 4.2 | 86.4 | 13.6 |
| អ្នកជំនាញឯកទេសវិជ្ជាជីវៈ | 91.1 | 8.9 | 66.4 | 33.6 |
| អ្នកបច្ចេកទេស និងអ្នកជំនាញឯកទេសវិជ្ជាជីវៈរង | 75.1 | 24.9 | 79.3 | 20.7 |
| ស្មៀន | 84.6 | 15.4 | 70.6 | 29.4 |
| កម្មករនិយោជិតផ្នែកសេវាកម្ម និងបំរើក្នុងហាង និងអ្នកលក់ដូរតាមទីផ្សារ | 43.9 | 56.1 | 36.7 | 63.3 |
| កម្មករជំនាញផ្នែកកសិកម្ម និងនេសាទ | 44.7 | 55.3 | 46.6 | 53.4 |
| កម្មករជំនាញផ្នែកសិប្បកម្ម និងកិច្ចការជំនួញផ្សេងៗ | 56.1 | 43.9 | 40.7 | 59.3 |
| អ្នកបញ្ជា និងផ្គុំតម្លើង ម៉ាស៊ីន និងដំណើរការរោងចក្រ | 86.8 | 13.2 | 92.0 | 8.0 |
| មុខរបរតូចតាចនានា | 49.1 | 50.9 | 63.4 | 36.6 |

*ប្រភព: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨ និង អង្កេតអំពីសង្គម-សេដ្ឋកិច្ចនៃប្រទេសកម្ពុជាឆ្នាំ ២០០៤ និង២០០៩ (វិទ្យាស្ថានជាតិស្ថិតិ)*

តារាងទី១១: ប្រាក់បៀវត្សគិតជាមធ្យមប្រចាំខែតាមប្រភេទនៃមុខរបរ (គិតជារៀល)

| *ប្រភេទនៃមុខរបរ ឬការងារ* | 2004 | 2009 |
|---|---|---|
| *ប្រាក់ចំណូលសរុប* | 178,793 | 314,665 |
| សមាជិកអង្គនីតិបញ្ញត្តិ មន្ត្រីគ្រប់គ្រងជាន់ខ្ពស់ អ្នកគ្រប់គ្រង | 247,958 | 313,585 |
| អ្នកជំនាញឯកទេសវិជ្ជាជីវៈ | 258,232 | 493,489 |
| អ្នកបច្ចេកទេស និងអ្នកជំនាញឯកទេសវិជ្ជាជីវៈរង | 331,752 | 693,826 |
| ស្មៀន | 383,398 | 592,579 |
| កម្មករនិយោជិតផ្នែកសេវាកម្ម និងបំរើក្នុងហាង និងអ្នកលក់ដូរតាមទីផ្សារ | 178,990 | 328,099 |
| កម្មករជំនាញផ្នែកកសិកម្ម និងនេសាទ | 82,751 | 221,176 |
| កម្មករជំនាញផ្នែកសិប្បកម្ម និងកិច្ចការជំនួញផ្សេងៗ | 195,633 | 325,940 |
| អ្នកបញ្ជា និងផ្គុំតម្លើង ម៉ាស៊ីន និងដំណើរការរោងចក្រ | 239,188 | 436,542 |
| មុខរបរតូចតាចនានា | 157,932 | 233,955 |

*ប្រភព: អង្កេតអំពីសង្គម-សេដ្ឋកិច្ចនៃប្រទេសកម្ពុជាឆ្នាំ ២០០៤ និង២០០៩ (វិទ្យាស្ថានជាតិស្ថិតិ)*


តទៅទំព័របន្ទាប់

# ៣. អ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក និងវគ្គអប់រំបណ្តុះបណ្តាលដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ

ខាងក្រោមនេះជាទិន្នន័យស្តីពីអ្នកស្វែងរកការងារធ្វើ ព័ត៌មានជ្រើសរើសបុគ្គលិក និងវគ្គអប់រំបណ្តុះបណ្តាលដែលត្រូវបានប្រមូលពីគ្រប់ប្រភព (សារព័ត៌មាន អ៊ីនធើណេត និងពីនិយោជកនិងអ្នកស្វែងរកការងារផ្ទាល់) ដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ចាប់ពីខែមីនា ឆ្នាំ២០១០ ដល់ខែមេសា ឆ្នាំ២០១១។ ទិន្នន័យទាំងអស់នេះរួមមាន អ្នកស្វែងរកការងារធ្វើដែលបានចុះឈ្មោះនៅ ទ.ជ.ម.ក មានចំនួន ៣,៤៤២នាក់ ព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥,៤៤០ និងព័ត៌មានវគ្គអប់រំបណ្តុះបណ្តាលចំនួន ៤៥២។ ព័ត៌មានទាំងនេះត្រូវបានប្រមូល និងផ្សព្វផ្សាយជាប្រចាំថ្ងៃនៅលើគេហទំព័រ និងនៅតាមមជ្ឈមណ្ឌលការងាររបស់ ទ.ជ.ម.ក។ ទ.ជ.ម.ក សូមបញ្ជាក់ជូនអ្នកអានទាំងអស់ថា ទិន្នន័យទាំងអស់នេះគឺគ្រាន់តែជាផ្នែកមួយ និងមិនគ្របដណ្តប់លើទិន្នន័យសរុបទាំងអស់សម្រាប់ប្រទេសកម្ពុជាទេ ដូច្នេះរាល់ការប្រើប្រាស់ និងបកស្រាយទិន្នន័យត្រូវយកមកពិចារណានូវបញ្ហានេះ។

### *៣.១. អ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមប្រភេទនៃការងារខ្ពស់បំផុតចំនួន ១០*

បើពិនិត្យមើលផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម (រូបទី២០) គឺចំនួនអ្នកស្វែងរកការងារធ្វើមានចំនួន ៣,៤៤២នាក់ បែងចែកតាមប្រភេទនៃការងារដែលចង់ធ្វើខ្ពស់បំផុតចំនួន ១០ គេសង្កេតឃើញថា ប្រភេទការងារដែលអ្នកស្វែងរកការងារធ្វើចង់ធ្វើច្រើនបំផុតគឺ គណនេយ្យ សវនកម្ម និងពន្ធអាករ (១៣.៩%) បន្ទាប់មកគឺ ធនាគារ ហិរញ្ញវត្ថុ និងធានារ៉ាប់រង (១៣.៧%)។ ចំណែកមុខរបរបន្ទាប់មកទៀតគឺ វិស្វកម្ម (៨.៥%) ការអប់រំ និងបណ្តុះបណ្តាល (៨%) អ្នកបច្ចេកទេសគ្រឿងយន្ត និងអគ្គិសនី (៧.១%) ព័ត៌មានវិទ្យា (៧%) ការលក់ និងទីផ្សារ (៦.៤%) រដ្ឋបាល និងលេខាធិការ (៥.១%) ពាណិជ្ជកម្ម និងគ្រប់គ្រង (៣.៣%) និងសេវាកម្មអតិថិជន (២.៦%)។

ចំណែកឯ តម្រូវការកម្លាំងពលកម្មវិញ គេសង្កេតឃើញថាក្នុងចំណោមព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៤៤០ ប្រភេទការងារដែលនិយោជកត្រូវការជ្រើសរើសខ្ពស់បំផុតតាមលំដាប់គឺ ការលក់ និងទីផ្សារ (២៤.៥%) រដ្ឋបាល និងលេខាធិការ (១២.៥%) គណនេយ្យ សវនកម្ម និងពន្ធអាករ (១២.៤%) ពាណិជ្ជកម្ម និងគ្រប់គ្រង (១២.១%) ការអប់រំ និងបណ្តុះបណ្តាល (៨.៩%) សេវាកម្មអតិថិជន (៨.៧%) ព័ត៌មានវិទ្យា (៧.២%) អ្នកបច្ចេកទេស គ្រឿងយន្ត និងអគ្គិសនី (៦.៨%) ធនាគារ ហិរញ្ញវត្ថុ និងធានារ៉ាប់រង (៣.៧%) និងវិស្វកម្ម (៣.៣%)។

**រូបទី២០: ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមប្រភេទមុខរបរ គិតជា% (ខែមីនា ឆ្នាំ២០១០-ខែមេសា ឆ្នាំ២០១១)**




*សម្គាល់: .អ្នកស្វែងរកការងារធ្វើសរុបចំនួន: ៣៤៤២ .ព័ត៌មានជ្រើសរើសបុគ្គលិកសរុបចំនួន: ៥៤៤០*

តទៅទំព័របន្ទាប់

### ៣.២. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់មុខរបរ (ISCO) (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១១)

ប្រសិនបើពិនិត្យទៅតាមតួលេខនៅក្នុងរូបទី២១ គេសង្កេតឃើញថាការផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់មុខរបរ អ្នកមានជំនាញឯកទេសគឺមានចំនួនច្រើនជាងគេ ៩៥០នាក់។ រីឯមុខរបរដែលអ្នកស្វែងរកការងារធ្វើមានបំណងចង់ធ្វើបន្ទាប់មកទៀតតាមលំដាប់គឺ អ្នកធ្វើការខាងជំនាញកត់ត្រា (៧០០នាក់) អ្នកបច្ចេកទេស និងវិជ្ជាជីវៈជាសហការី (៥៦០ នាក់) អ្នកធ្វើការខាងបម្រើសេវាកម្ម និងលក់ដូរ (៤២៣ នាក់) សិប្បករ និងកម្មករអាជីវកម្មដែលពាក់ព័ន្ធ (៣៧៨ នាក់) អ្នកគ្រប់គ្រង (២៨២ នាក់)។

ចំណែកឯផ្នែកតម្រូវការកម្លាំងពលកម្មវិញ ឱកាសការងារដែលមានច្រើនជាងគេគឺសំដៅលើមុខរបរ វិជ្ជាជីវៈ(១៤១៦) និងមុខរបរ បន្ទាប់ៗមកទៀតគឺ អ្នកធ្វើការខាងបម្រើសេវាកម្ម និងលក់ដូរ(១០៥៦) អ្នកបច្ចេកទេស និងវិជ្ជាជីវៈជាសហការី(៩០៥) អ្នកគ្រប់គ្រង (៧០៧) អ្នកធ្វើការខាងជំនាញកត់ត្រា (៥៥៧) សិប្បករ និងកម្មករអាជីវកម្មដែលពាក់ព័ន្ធ(៣៩៣) មុខរបរតូចតាច(២៣០) និងអ្នកតម្លើង និងបញ្ជាគ្រឿងចក្រ និងម៉ាស៊ីនមានព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ១៦០។

រូបទី២១: ចំនួនអ្នកស្វែងរកការងារធ្វើ និងព័តមានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់មុខរបរ (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១១)




សម្គាល់: .អ្នកស្វែងរកការងារធ្វើសរុបចំនួន: ៣៤៤២ .ព័ត៌មានជ្រើសរើសបុគ្គលិកសរុបចំនួន: ៥៤៤០

### ៣.៣. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមវិស័យ (ខែមីនា ឆ្នាំ២០១០ - ខែមេសា ២០១១)

ទ.ជ.ម.ក បានប្រមូលទិន្នន័យស្តីពីអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដោយបែងចែកតាមវិស័យធំៗបីគឺ៖ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម (រូបទី២២)។ ក្នុងចំណោមវិស័យទាំងបី វិស័យដែលមានសកម្មភាពលេចធ្លោជាងគេគឺវិស័យសេវាកម្ម ដោយហេតុថាទាំងភាគរយនៃអ្នកស្វែងរកការងារធ្វើ (៧៨.១%) ទាំងភាគរយនៃព័ត៌មានជ្រើសរើសបុគ្គលិក(៨៤.៦%) មានអត្រាច្រើនជាងវិស័យដ៏ទៃទៀត។ រីឯវិស័យឧស្សាហកម្មវិញ ហាក់ឈានមុខទីពីរបន្ទាប់ពីវិស័យសេវាកម្មគឺ អត្រាអ្នកស្វែងរកការងារធ្វើ (១៩.៧%) និងព័ត៌មានជ្រើសរើសបុគ្គលិក (១៣.៣%)។ ដោយឡែក វិស័យកសិកម្មមានអត្រាទាបជាងគេ ទោះជាយ៉ាងណាក្តី វិស័យនេះបានបង្ហាញពីអត្រាមានកម្រិតស្មើគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មគឺ ២.២% ដូចគ្នា។

រូបទី២២: ចំនួនអ្នកស្វែងរកការងារធ្វើ និងព័តមានជ្រើសរើសបុគ្គលិកបែងចែកតាមវិស័យ គិតជា (%) (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១១)




សម្គាល់:

.អ្នកស្វែងរកការងារធ្វើសរុបចំនួន: ៣៤៤២

.ព័ត៌មានជ្រើសរើសបុគ្គលិកសរុបចំនួន: ៥៤៤០

តារាងទី១២: ការបែងចែកអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាព សេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០-ខែមេសា ឆ្នាំ២០១១)

| ចំណាត់ថ្នាក់នៃសហគ្រាស | | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % |
| A | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 76 | 2.2 | 117 | 2.2 |
| B | សកម្មភាពរុករកថ្ម និងរ៉ែ | 8 | 0.2 | 2 | 0.0 |
| C | ផលិតកម្ម | 261 | 7.6 | 442 | 8.1 |
| D | ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្តល់ខ្យល់ត្រជាក់ | 238 | 6.9 | 110 | 2.0 |
| E | ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងលូទឹកស្អុយ កាកសំណល់ និងការកែច្នៃកាកសំណល់ | 17 | 0.5 | 4 | 0.1 |
| F | ការសាងសង់ | 154 | 4.5 | 165 | 3.0 |
| G | ការលក់ដុំ និងលក់រាយ ការជួសជុលយានយន្ត និងទោចក្រយានយន្ត | 205 | 6.0 | 350 | 6.4 |
| H | ការដឹកជញ្ជូន និងការស្តុកទុក | 25 | 0.7 | 24 | 0.4 |
| I | សកម្មភាពបម្រើសេវាស្នាក់នៅ និងអាហារ | 178 | 5.2 | 667 | 12.3 |
| J | ព័ត៌មានវិទ្យា និងទំនាក់ទំនង | 328 | 9.5 | 317 | 5.8 |
| K | សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | 620 | 18.0 | 196 | 3.6 |
| L | អចលនទ្រព្យ | 6 | 0.2 | 33 | 0.6 |
| M | សកម្មភាពជំនាញវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | 357 | 10.4 | 433 | 8.0 |
| N | សកម្មភាពរដ្ឋបាល និងសេវាទ្រទ្រង់ | 155 | 4.5 | 164 | 3.0 |
| O | រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គម | 40 | 1.2 | 24 | 0.4 |
| P | ការអប់រំ | 250 | 7.3 | 443 | 8.1 |
| Q | សកម្មភាពផ្នែកសុខភាពមនុស្ស និងសង្គម | 65 | 1.9 | 619 | 11.4 |
| R | សិល្បៈ និងការកំសាន្ត | 21 | 0.6 | 86 | 1.6 |
| S | សកម្មភាពសេវាផ្សេងទៀត | 382 | 11.1 | 1068 | 19.6 |
| T | សកម្មភាពជានិយោជកដោយខ្លួនឯង | 10 | 0.3 | 19 | 0.3 |
| U | សកម្មភាពរបស់អង្គការ និងអង្គភាពក្រៅប្រទេស | 46 | 1.3 | 157 | 2.9 |
| សរុប | | 3442 | 100.0 | 5440 | 100.0 |

*៣.៤. អ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតសិក្សា (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១១)*

យោងទៅតាមតួលេខ(រូបទី២៣ និងតារាងទី១៣) ការផ្គត់ផ្គង់កម្លាំងពលកម្មនៅកម្រិតបរិញ្ញាបត្រមានអត្រាច្រើនជាងគេគឺ (៧០.១%) ចំណែកកម្រិតបន្ទាប់មកទៀតគឺសំដៅអ្នកដែលមិនធ្លាប់បានសិក្សា ឬបញ្ចប់កម្រិតណាមួយ (៩.៦%) និងកម្រិតបរិញ្ញាបត្ររង (៧.៨%)។ បើពិនិត្យលើផ្នែកតម្រូវការកម្លាំងពលកម្មវិញ គេសង្កេតឃើញថាព័ត៌មានជ្រើសរើសបុគ្គលិកដែលតម្រូវលើសញ្ញាបត្រកម្រិតបរិញ្ញាបត្រមានចំនួនច្រើនជាងគេគឺ ៤៥.១% រីឯតម្រូវការបន្ទាប់តាមលំដាប់គឺ សំដៅអ្នកដែលមិនធ្លាប់បានសិក្សា ឬបញ្ចប់កម្រិតណាមួយ (២៧.២%) កម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (១១.១%) កម្រិតសញ្ញាបត្របណ្ឌិត (៥.៤%) និងកម្រិតសញ្ញាបត្រអនុបណ្ឌិត (៣.១%)។

រូបទី២៣: ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតសិក្សា (ខែមីនា ឆ្នាំ២០១០-ខែមេសា ឆ្នាំ២០១១)




*សម្គាល់: .អ្នកស្វែងរកការងារធ្វើសរុបចំនួន: ៣៤៤២ .ព័ត៌មានជ្រើសរើសបុគ្គលិកសរុបចំនួន: ៥៤៤០*

តារាងទី១៣: ទិន្នន័យអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមកម្រិតសិក្សា (ខែមីនា ឆ្នាំ២០១០ - ខែមេសា ឆ្នាំ២០១១)

| ល.រ | ប្រភេទកម្រិតសិក្សា | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| ១ | មិនធ្លាប់បានសិក្សា ឬបញ្ចប់ថ្នាក់ណាមួយឡើយ | 331 | 9.6 | 1477 | 27.2 |
| ២ | បឋម | 23 | 0.7 | 7 | 0.1 |
| ៣ | អនុវិទ្យាល័យ | 47 | 1.4 | 90 | 1.7 |
| ៤ | វិទ្យាល័យ | 97 | 2.8 | 122 | 2.2 |
| ៥ | សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) | 149 | 4.3 | 606 | 11.1 |
| ៦ | សញ្ញាប័ត្រវិជ្ជាជីវៈវគ្គខ្លី | 0 | 0.0 | 5 | 0.1 |
| ៧ | សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត I | 0 | 0.0 | 0 | 0.0 |
| ៨ | សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត II | 0 | 0.0 | 0 | 0.0 |
| ៩ | សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត III | 0 | 0.0 | 1 | 0.0 |
| ១០ | សញ្ញាប័ត្របច្ចេកទេស | 68 | 2.0 | 91 | 1.7 |
| ១១ | បរិញ្ញាប័ត្ររង | 268 | 7.8 | 79 | 1.5 |
| ១២ | បរិញ្ញាប័ត្រ | 2412 | 70.1 | 2454 | 45.1 |
| ១៣ | អនុបណ្ឌិត | 44 | 1.3 | 171 | 3.1 |
| ១៤ | បណ្ឌិត | 1 | 0.0 | 295 | 5.4 |
| ១៥ | សញ្ញាប័ត្របញ្ចាក់វិជ្ជាជីវៈ/អាជ្ញាបណ្ណ/កម្រិត | 2 | 0.1 | 42 | 0.8 |
| | សរុប | 3442 | 100 | 5440 | 100 |


តទៅទំព័របន្ទាប់

តារាងទី១៤: ទិន្នន័យអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមប្រភេទមុខរបរ (ខែមីនា ឆ្នាំ២០១០-ខែមេសា ឆ្នាំ២០១១)

| ល.រ | ប្រភេទមុខរបរ | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| ១ | គណនេយ្យ សវនកម្ម និងពន្ធអាករ | 477 | 13.9 | 428 | 12.4 |
| ២ | ធនាគារ ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 470 | 13.7 | 129 | 3.7 |
| ៣ | វិស្វកម្ម | 293 | 8.5 | 114 | 3.3 |
| ៤ | ការអប់រំ និងបណ្តុះបណ្តាល | 276 | 8.0 | 305 | 8.9 |
| ៥ | អ្នកបច្ចេកទេស/គ្រឿងយន្ត/គ្រឿងអគ្គិសនី | 244 | 7.1 | 234 | 6.8 |
| ៦ | ព័ត៌មានវិទ្យា | 241 | 7.0 | 247 | 7.2 |
| ៧ | ការលក់ និងទីផ្សារ | 219 | 6.4 | 844 | 24.5 |
| ៨ | រដ្ឋបាល និងស្មៀន | 174 | 5.1 | 431 | 12.5 |
| ៩ | ពាណិជ្ជកម្ម និងគ្រប់គ្រង | 113 | 3.3 | 418 | 12.1 |
| ១០ | សេវាកម្មអតិថិជន | 88 | 2.6 | 298 | 8.7 |
| ១១ | កសិកម្ម រុក្ខប្រមាញ់ និងនេសាទ | 77 | 2.2 | 65 | 1.9 |
| ១២ | សណ្ឋាគារ/អាហារដ្ឋាន និងភេសជ្ជៈ | 65 | 1.9 | 238 | 6.9 |
| ១៣ | សំណង់ និងអាគារ | 55 | 1.6 | 24 | 0.7 |
| ១៤ | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ | 45 | 1.3 | 81 | 2.4 |
| ១៥ | ការធ្វើដំណើរ និងទេសចរណ៍ | 45 | 1.3 | 25 | 0.7 |
| ១៦ | ការផ្សព្វផ្សាយ ឬប្រព័ន្ធផ្សព្វផ្សាយ (សារព័ត៌មាន) | 37 | 1.1 | 88 | 2.6 |
| ១៧ | ការថែសម្ផស្ស និងលំហាត់រាង្គកាយ | 34 | 1.0 | 52 | 1.5 |
| ១៨ | សំលៀកបំពាក់/វាយនភ័ណ្ឌ/គ្រឿងតែងកាយ | 33 | 1.0 | 48 | 1.4 |
| ១៩ | ច្បាប់ និងវិជ្ជាជីវៈដែលទាក់ទង | 32 | 0.9 | 70 | 2.0 |
| ២០ | ធនធានមនុស្ស | 31 | 0.9 | 59 | 1.7 |
| ២១ | រដ្ឋបាលសាធារណៈ | 25 | 0.7 | 33 | 1.0 |
| ២២ | កម្មករទូទៅ/ពលករ | 25 | 0.7 | 92 | 2.7 |
| ២៣ | ឱសថ/សុខមាលភាព/សេវាថែទាំ | 20 | 0.6 | 212 | 6.2 |
| ២៤ | ភាសា/ការបកប្រែភាសា | 19 | 0.6 | 94 | 2.7 |
| ២៥ | ការគ្រប់គ្រងពិធីផ្សេងៗ | 19 | 0.6 | 32 | 0.9 |
| ២៦ | សន្តិសុខ និងសុវត្ថិភាព | 19 | 0.6 | 69 | 2.0 |
| ២៧ | ទូរគមនាគមន៍ | 18 | 0.5 | 2 | 0.1 |
| ២៨ | ផលិតកម្ម និងផលិតផលផ្សេងៗ | 17 | 0.5 | 15 | 0.4 |
| ២៩ | អ្នកបើកបរ/ចែកចាយ | 16 | 0.5 | 131 | 3.8 |
| ៣០ | ស្ថាបត្យករ និងរចនា | 13 | 0.4 | 54 | 1.6 |
| ៣១ | ការផ្សព្វផ្សាយពាណិជ្ជកម្ម និងទំនាក់ទំនងសាធារណៈ | 12 | 0.3 | 13 | 0.4 |
| ៣២ | ការដឹកជញ្ជូន ប្រតិបត្តិការ ការបែងចែកស្តុក ឃ្លាំង | 10 | 0.3 | 89 | 2.6 |
| ៣៣ | មន្ទីរពិសោធន៍ | 5 | 0.1 | 5 | 0.1 |
| ៣៤ | ការថែទាំ (មនុស្ស) ដោយផ្ទាល់ | 4 | 0.1 | 19 | 0.6 |
| ៣៥ | អ្នកប្រឹក្សា (យោបល់ ឬកិច្ចការ) | 3 | 0.1 | 100 | 2.9 |
| ៣៦ | ជាងឈើ ជាងដែក សិប្បកម្មជាងចំលាក់ ស្មូន និងវិចិត្រករ | 2 | 0.1 | 33 | 1.0 |
| ៣៧ | អ្នកបោសសំអាត | 1 | 0.0 | 77 | 2.2 |
| ៣៨ | អចលនទ្រព្យ និងទ្រព្យសម្បត្តិ | 0 | 0.0 | 4 | 0.1 |
| ៣៩ | ការចំរាញ់យករ៉ែ និងការគាស់យកថ្ម | 0 | 0.0 | 1 | 0.0 |
| ៤០ | កីឡា និងល្បែងកំសាន្ត | 0 | 0.0 | 7 | 0.2 |
| ៤១ | ផ្សេងៗ | 165 | 4.8 | 160 | 4.6 |
| | **សរុប** | **3442** | **100** | **5440** | **100** |

# បច្ចុប្បន្នភាពនៃវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## ១. ការងារគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញថា វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវ សាចរណែនាំលេខៈ ០១សរណន ស្តីពី "**ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**" ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ . សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានតួនាទីស្នូលក្នុងការងារបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាព ព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ កន្លងមកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានបំពេញតួនាទីខាងលើនេះ ទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់។ ផ្អែកលើភារកិច្ចក្នុងដំណាក់កាលថ្មី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាមទារនូវការពង្រឹង និងពង្រីក ទាំងបរិមាណ និងគុណភាព ដើម្បីមានថាមពលគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាលកំលាំងពលកម្មជំនាញ ផ្នែកបច្ចេកទេស រួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ច បង្កើតឱកាសការងារដល់យុវជន យុវនារី ទាក់ទាញអ្នកវិនិយោគទុនជាតិ និងអន្តរជាតិ ព្រមទាំងដោះស្រាយបញ្ហាប្រឈមដទៃទៀត ដូចជាការចល័តកំលាំងពលកម្ម ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ានក្រោយឆ្នាំ២០១៥។

ផ្អែកលើស្មារតីខាងលើនេះ និងអនុវត្តតាមខ្លឹមសារក្នុងសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៥ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ព្រមទាំងលទ្ធផលវាយតម្លៃរបស់ក្រុមការងារចំពោះស្ថានភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រាជរដ្ឋាភិបាលកំណត់ចេញនូវទិសដៅយុទ្ធសាស្ត្រសម្រាប់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដូចតទៅ៖

- លើកកម្ពស់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានលក្ខណៈទាក់ទាញ ដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបង្កើនការទទួលស្គាល់ជាសាធារណៈ។
- លើកកម្ពស់គុណភាព និងលទ្ធផលការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅបង្កើនឱកាសការងារ ផលិតភាពការងារ និងបង្កើនប្រាក់ចំណូលគ្រួសារ។
- ពង្រឹងគោលការណ៍បណ្តុះបណ្តាលប្រកបដោយសមធម៌ ដោយយកចិត្តទុកដាក់ដល់ស្ត្រីភេទ ជនបាត់បង់ឱកាស ឬមានឱកាសតិចតួចក្នុងសង្គម យុវជនទីទ័លក្រ និងសិស្សដែលបានបោះបង់ការសិក្សា។

ដើម្បីសម្រេចទិសដៅយុទ្ធសាស្ត្រខាងលើ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវអនុវត្តនូវវិធានការទាំងឡាយដូចខាងក្រោម៖

**១. ការបណ្តុះបណ្តាលត្រូវឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ**

- គណៈកម្មាធិការជាតិបណ្តុះបណ្តាល តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវសិក្សាស្រាវជ្រាវអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារមួយ និងប្រើប្រាស់លទ្ធផលព័ត៌មាន និងទិន្នន័យ ដែលផលិតដោយទីភ្នាក់ងារជាតិនេះ ដើម្បីជាបង្អែករឹងមាំសម្រាប់រៀបចំផែនការបណ្តុះបណ្តាល ឱ្យបានឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។

១

*អត្ថបទនេះបានរៀបចំ និងផ្តល់ឲ្យដោយ **អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ទ.ជ.ម.ក បានរក្សាសិទ្ធិ និងចុះផ្សាយនូវខ្លឹមសារនៃឯកសារដើមទាំងស្រុង ដោយគ្រាន់តែរៀបចំរចនា និងកែសម្រួលរបៀបរៀបរយនៃអត្ថបទឲ្យសមស្របទៅតាមទម្រង់រួមនៃព្រឹត្តិបត្រនេះតែប៉ុណ្ណោះ។*

- បង្កើនបរិមាណបណ្តុះបណ្តាលពលករជំនាញ និងអ្នកបច្ចេកទេសឱ្យស្របតាមស្ថានភាពទីផ្សារការងារ ដែលនៅមានភាពទុលំទូលាយ តាមរយៈការពង្រីក ឬកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្មីៗថែមទៀត។
- បង្កើនបរិមាណបណ្តុះបណ្តាលលើមុខជំនាញដែលមានតម្រូវការទីផ្សារការងារ និងសិក្សាស្រាវជ្រាវលើមុខជំនាញថ្មីៗថែមទៀត ។
- ត្រូវបន្តធ្វើការពង្រាយការបណ្តុះបណ្តាលរយៈពេលខ្លី ឱ្យបានច្រើនថែមទៀតដល់សហគមន៍ និងបណ្តុះបណ្តាលនៅនឹងកន្លែង សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន រោងចក្រ និងមូលដ្ឋានផលិតកម្ម ឱ្យឆ្លើយតបតាមតម្រូវការការងារ និងមុខរបរនៅទីនោះ ដើម្បីបង្កើនផលិតភាពការងារ និងប្រាក់ចំណូលគ្រួសារ។
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបញ្ចូលកម្មវិធីបណ្តុះគំនិតសហគ្រិនភាពក្នុងផែនការកម្មវិធីបណ្តុះបណ្តាល ដើម្បីផ្តល់សញ្ញាណអំពីការធ្វើជំនួញ ឬការប្រកបមុខរបរដោយខ្លួនឯង។

## ២. ការធានាគុណភាពបណ្តុះបណ្តាលសំដៅបង្កើនផលិតភាព

- គណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវរៀបចំឱ្យមានជាផ្លូវការនូវក្របខណ្ឌគុណវុឌ្ឍិជាតិ អភិវឌ្ឍស្តង់ដាជាតិសមត្ថភាព ការធ្វើតេស្តបញ្ជាក់សមត្ថភាព លក្ខណៈវិនិច្ឆ័យវាយតម្លៃទទួលស្គាល់ គុណភាព វគ្គ កម្មវិធី គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបទដ្ឋានគតិយុត្តិ ហើយត្រូវដឹកនាំដំណើរការធ្វើតេស្តបញ្ជាក់សមត្ថភាពដល់ពលករជំនាញ និងធ្វើការវាយតម្លៃទទួល ស្គាល់គុណភាពបណ្តុះបណ្តាលរបស់វគ្គ កម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ និងអនុវត្តបានតាមបទដ្ឋានក្របខណ្ឌគុណវុឌ្ឍិជាតិ និងស្តង់ដាជាតិសមត្ថភាពតែមួយ គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវមកធ្វើការ ចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត អាស្រ័យតាមកម្រិតសិក្សានីមួយៗរាប់បញ្ចូលទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានច្បាប់អនុញ្ញាតហើយដោយក្រសួង ឬស្ថាប័នផ្សេងៗ។
- ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវធានាឱ្យបាននូវខ្លឹមសារ ៤យ៉ាងគឺ **ចំណេះដឹង សមត្ថភាពជំនាញ ឥរិយាបថការងារ និងសីលធម៌វិជ្ជាជីវៈ** ព្រមទាំងមានលក្ខណៈផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍ជាក់ស្តែងក្នុងផលិតកម្ម។
- កែលម្អនូវមធ្យោបាយបច្ចេកទេសគរុកោសល្យ បំពាក់បន្ថែមនូវមូលដ្ឋានសម្ភារៈឧបទេ្ទស រោងជាង សៀវភៅឯកសារ បណ្ណាល័យ ដើម្បីឆ្លើយតបតាមការវិវឌ្ឍន៍នៃបច្ចេកវិទ្យាថ្មីៗ។
- បំពាក់បំប៉នលើកកម្ពស់សមត្ថភាពដល់មន្ត្រីគ្រប់គ្រង និងធ្វើវិក្រឹត្យការដល់សាស្ត្រាចារ្យ គ្រូបច្ចេកទេសលើកម្រិតជំនាញ និងគរុកោសល្យ ។

## ៣.ការពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- និយោជកត្រូវផ្តល់អាទិភាពដល់ពលករជំនាញដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងការជ្រើសរើសឱ្យចូលបម្រើការងារក្នុងរោងចក្រ សហគ្រាសរបស់ខ្លួន ព្រមទាំងត្រូវធ្វើកិច្ចសហការជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងការទទួលឱ្យសិស្សនិស្សិតធ្វើកម្មសិក្សា និងសុក្រឹតការក៏ដូចជាការផ្លាស់ប្តូរបទពិសោធនានា ដើម្បីអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ទីផ្សារការងារ។
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវបង្កើតឱ្យមានក្រុមការងារទទួលបន្ទុកធ្វើទំនាក់ទំនង ជាមួយសមាគមវិជ្ជាជីវៈ មូលដ្ឋានផលិតកម្ម សេវាកម្ម រោងចក្រ សហគ្រាសដើម្បីជួយរកការងារឱ្យសិស្ស-និស្សិត ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ។

២

តទៅទំព័របន្ទាប់

- ត្រូវសិក្សាស្រាវជ្រាវ រៀបចំឱ្យមានមូលដ្ឋានគតិយុត្តិស្តីពីកាតព្វកិច្ចរួមចំណែកក្នុងការបណ្តុះបណ្តាលអ្នកបច្ចេកទេស និងវិជ្ជាជីវៈពីនិយោជក និងមូលដ្ឋានគតិយុត្តិស្តីពីការប្រើប្រាស់កំលាំងពលកម្មជំនាញ ដែលធ្លាប់បានទទួលការបណ្តុះបណ្តាល ។

### ៤. សមធម៌ក្នុងការបណ្តុះបណ្តាល

បន្តអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវគោលការណ៍សមធម៌របស់រាជរដ្ឋាភិបាល ក្នុងការបណ្តុះបណ្តាលត្រូវយកចិត្តទុកដាក់ផ្តល់អាទិភាពចំពោះស្ត្រីភេទ ជនពិការ ជនបាត់បង់ឱកាស យុវជនទីទ័លក្រ និងសិស្សដែលបានបោះបង់ការសិក្សា ដើម្បីមានជំនាញមានមុខរបរអាចរួមរស់បានសមរម្យក្នុងសង្គមដូចសមាជិកដទៃទៀត។ ដើម្បីសម្រេចគោលការណ៍នេះ ត្រូវមានវិធានការអាទិភាព រួមមាន ទាំងប្រាក់អាហារូបករណ៍ និងការបង្កើតអន្តេវាសិកដ្ឋានសម្រាប់ក្រុមមុខសញ្ញាខាងលើ។

### ៥. ការលើកកម្ពស់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច

- រៀបចំវិធានការនានា លើកទឹកចិត្តដល់គ្រូបច្ចេកទេស និងសិស្ស-និស្សិតកំពុងសិក្សា ឬបម្រើការក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីទាក់ទាញដល់អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេសថ្មីៗ និងសិស្សពូកែៗ ងាកមករៀន ឬបម្រើការងារក្នុងវិស័យនេះ។
- ដៃគូអភិវឌ្ឍន៍ អង្គការនានា ក្រុមហ៊ុន ឯកជន និងសប្បុរសជន គប្បីពិនិត្យលទ្ធភាពជួយអភិវឌ្ឍសាលាបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងផ្តល់អាហារូបករណ៍ ដល់យុវជន យុវនារីទីទ័លក្រ ដែលស្ម័គ្រចិត្តចូលរៀនផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវគ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាបាននូវគុណភាពព្រមទាំងត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តិ និងសារាចរណែនាំលម្អិត ដើម្បីអនុវត្តវិធានការទាំងឡាយខាងលើនេះ និងធ្វើការតាមដានត្រួតពិនិត្យវាយតម្លៃលទ្ធផលជូនរាជរដ្ឋាភិបាល។

ទទួលបានសារាចរណែនាំនេះ គណៈកម្មាធិការជាតិបណ្តុះបណ្តាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការខេត្តបណ្តុះបណ្តាល ព្រមទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាំងផ្នែករដ្ឋ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលត្រូវអនុវត្តសារាចរណែនាំនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី-ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

៣

ក្រោយពីទទួលបានសាចរណែនាំរបស់រដ្ឋាភិបាលលេខៈ ០/សរណជស្តីពី *"ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ"*ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីប្រកាសលេខៈ ០៧២/១១ក.ប/ប្រ.ក ស្តីពី "**ការចុះបញ្ជិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ**" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១១ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោមៈ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៧២/១១ **ក.ប** /ប្រ.ក

## ប្រកាស

## ស្តីពី

## ចុះបញ្ជីកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អន.ក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

ប្រការ ១ : ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ និងអនុវត្តតាមបទដ្ឋានក្របខណ្ឌគុណវុឌ្ឍិជាតិ និងស្តង់ដាជាតិសមត្ថភាពតែមួយ គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវមកធ្វើការចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត អាស្រ័យតាមកម្រិតសិក្សានីមួយៗ រាប់បញ្ចូលទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានច្បាប់អនុញ្ញាតហើយ ដោយក្រសួង ឬស្ថាប័នផ្សេងៗ ។

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

តទៅទំព័របន្ទាប់

ប្រការ ២ : ចំពោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានកម្រិតបណ្តុះបណ្តាលរយៈពេល ៣ខែចុះ ត្រូវមកធ្វើការចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ។

ប្រការ ៣ : ចំពោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានកម្រិតបណ្តុះបណ្តាលច្រើនជាង ៣ខែឡើង ត្រូវមកធ្វើការចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ) ។

ប្រការ ៤ : ប្រកាស និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានភារៈកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១

រដ្ឋមន្ត្រី

ចច សុគ

**កន្លែងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# បញ្ជីឈ្មោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
## ក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| ល.រ | ឈ្មោះគ្រឹះស្ថាន | ទីតាំង | លេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| ១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | រាជធានីភ្នំពេញ | ០១៦ ៨៤៤ ៧៤១ |
| ២ | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | រាជធានីភ្នំពេញ | ០១២ ៦៦៧ ៧៥៣ |
| ៣ | វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | រាជធានីភ្នំពេញ | ០១២ ៨២៦ ៤០៤ |
| ៤ | វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | រាជធានីភ្នំពេញ | ០៩២ ៤៩២ ០០៥ |
| ៥ | វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម | រាជធានីភ្នំពេញ | ០៩២ ៣៥៥ ៩៦៧ |
| ៦ | មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា | រាជធានីភ្នំពេញ | ០១២ ៨០៦ ៦៣១ |
| ៧ | មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ | រាជធានីភ្នំពេញ | ០១២ ៣៦៣ ៨៣៧ |
| ៨ | សាលាមធ្យមសិក្សាបច្ចេកទេស JVC | រាជធានីភ្នំពេញ | ០១២ ៧៣៧ ១៥៦ |
| ៩ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង | ខេត្តបាត់ដំបង | ០១២ ៩១៨ ១៤៨ |
| ១០ | វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង | ខេត្តបាត់ដំបង | ០១៦ ៨៦៣ ៨៩៩ |
| ១១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត | ខេត្តកំពត | ០១២ ២៨៩ ៩៩២ |
| ១២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រៃកូនខ្លា | ខេត្តបាត់ដំបង | ០១៧ ៣២០ ១៦៦ |
| ១៣ | សាលាបណ្តុះបណ្តាលវិជ្ជាជីវៈបឹងនិមល | ខេត្តកំពត | ០៩២ ២៧៩ ៤៦៤ |
| ១៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល | ខេត្តកណ្តាល | ០១២ ៩៤៦ ៩២៦ |
| ១៥ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ | ខេត្តតាកែវ | ០៩២ ៩៧៤ ៧៩៥ |
| ១៦ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប | ខេត្តកែប | ០៩២ ៩៥៣ ៦៦៧ |
| ១៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ | ខេត្តកំពង់ស្ពឺ | ០១២ ៩៩៥ ៩៥២ |
| ១៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ | ខេត្តព្រះសីហនុ | ០១៦ ៩៧៤ ៧៩៥ |
| ១៩ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង | ខេត្តកោះកុង | ០១២ ៣៥១ ៩៤៣ |
| ២០ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែង | ខេត្តព្រៃវែង | ០១២ ៧៧២ ០៣៧ |
| ២១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង | ខេត្តស្វាយរៀង | ០៨៩ ៧៦៤ ២៤២ |
| ២២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង | ខេត្តកំពង់ឆ្នាំង | ០១២ ៨៦៧ ៩០៤ |
| ២៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ | ខេត្តពោធិ៍សាត់ | ០១២ ៩០២ ៧៣៧ |
| ២៤ | សាលាបណ្តុះបណ្តាលវិជ្ជាជីវៈលលាំងខេត្តពោធិ៍សាត់ | ខេត្តពោធិ៍សាត់ | ០១២ ៥០៧ ៦២៤ |
| ២៥ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន | ខេត្តប៉ៃលិន | ០១៧ ៩៤៥ ៤២៤ |
| ២៦ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ | ខេត្តបន្ទាយមានជ័យ | ០៧៧ ៩៦៩ ៨៥៨ |
| ២៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ | ខេត្តឧត្តរមានជ័យ | ០១៧ ៥១៤ ៧១៤ |
| ២៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ | ខេត្តកំពង់ធំ | ០១២ ៩២៦ ២៣២ |
| ២៩ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | ខេត្តសៀមរាប | ០១២ ៩១៨ ១៦៧ |
| ៣០ | ការដ្ឋានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | ខេត្តសៀមរាប | ០១២ ៩៣៧ ០៥៦ |
| ៣១ | មជ្ឈមណ្ឌលកោសល្យវិប្បកម្មជាតិ | ខេត្តសៀមរាប | ០១២ ២៨៥ ៣១៣ |
| ៣២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម | ខេត្តកំពង់ចាម | ០១១ ៨៦៥ ៤០៧ |
| ៣៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ | ខេត្តក្រចេះ | ០១២ ៣៣៩ ៣៩២ |
| ៣៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង | ខេត្តស្ទឹងត្រែង | ០៩២ ៩៦៣ ៤៣៤ |
| ៣៥ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី | ខេត្តរតនគិរី | ០១២ ៥៥២ ២៨២ |
| ៣៦ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី | ខេត្តមណ្ឌលគិរី | ០១២ ៣១៦ ១០៨ |
| ៣៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ | ខេត្តព្រះវិហារ | ០១១ ២៥៣ ៥៥៨ |
| ៣៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រះវិហារ-យ៉ាឡូយ | ខេត្តព្រះវិហារ | ០១២ ២១២ ២៤៧ |

តទៅទំព័របន្ទាប់

# បញ្ជីឈ្មោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្នែកឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលបានការអនុញ្ញាតច្បាប់ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| ល.រ | ឈ្មោះស្ថាប័ន/គ្រឹះស្ថាន | ទីតាំង | លេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| ១ | វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច (វ.អ.ស) | រាជធានីភ្នំពេញ | ០១២ ៣៩៣ ៩៥៩ |
| ២ | វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា (វ.ព.ក) | ខេត្តព្រៃវែង<br>សាខាស្វាយរៀង<br>សាខាតាកែវ | ០១២ ៧៨៦ ៦២៥ |
| ៣ | វិទ្យាស្ថានពាណិជ្ជសាស្ត្រនាគព័ន្ធ (វ.ព.ន) | ខេត្តកំពង់ចាម | ០១២ ៩២៣ ០៩៣ |
| ៤ | វិទ្យាស្ថានខ្មែរជំនាន់ថ្មី (វ.ខ.ថ) | រាជធានីភ្នំពេញ<br>សាខាខេត្តបាត់ដំបង | ០១២ ៩២៥ ៩៧៤ |
| ៥ | វិទ្យាស្ថានអនាគតយុវជនកម្ពុជា (វ.អ.យ.ក) | រាជធានីភ្នំពេញ | ០១២ ៦៨២ ២៧៨ |
| ៦ | វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា (វ.ស.អ.ក) | រាជធានីភ្នំពេញ | ០១២ ៨៨៩ ៥១៦ |
| ៧ | វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត (វ.អ.ន) | រាជធានីភ្នំពេញ | ០៧៧ ៧៧៧ ០០៨ |
| ៨ | សាលាពាណិជ្ជសាស្ត្រតាយ៉ាម៉ា (ស.ព.ត) | រាជធានីភ្នំពេញ | ០១២ ៦៣៦ ៣៨៨ |
| ៩ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា (មបវ.អក) | រាជធានីភ្នំពេញ | ០១៦ ៨៧១ ១១១ |
| ១០ | មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាកូរ៉េក្រុងតាខ្មៅ (ម.ប.ភ.ក) | ខេត្តកណ្តាល | ០១១ ៨១៦ ៩៨១ |
| ១១ | មជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាកូរ៉េ សេង អាយ (ម.ហ.ភ.ក) | រាជធានីភ្នំពេញ | ០១២ ២០០ ០៨៤ |
| ១២ | សាលាបច្ចេកទេសអន្តរជាតិភ្នំពេញ (ស.ប.អ.ភ.ព) | រាជធានីភ្នំពេញ | ០១២ ៥២៥ ៣៣៥ |
| ១៣ | សាលាអន្តរជាតិអង្គរបូរី (ស.អ.អ) | រាជធានីភ្នំពេញ | ០១២ ៥៤៩ ៥៥០ |
| ១៤ | វិទ្យាស្ថានប៊ែលតុនអន្តរជាតិ | រាជធានីភ្នំពេញ | ០១២ ៣១៨ ៤៩២ |
| ១៥ | សាលាអន្តរជាតិអ៊ីលតុន (ស.អ.ត) | រាជធានីភ្នំពេញ | ០១២ ៥៦៨ ៤៤៨ |
| ១៦ | មជ្ឈមណ្ឌលស៊ីនគីបូ (ម.ស.គ.ប) | រាជធានីភ្នំពេញ | ០១២ ៨០៥ ២៨១ |
| ១៧ | មជ្ឈមណ្ឌលភាសាកូរ៉េ ចេ អេស (ម.ភ.ក.ច.អ) | រាជធានីភ្នំពេញ | ០១៧ ៨៨៨ ៧០៧ |
| ១៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ(ម.ប.ជ.ត) | រាជធានីភ្នំពេញ | ០១២ ៩៦៧ ៤៤៦ |
| ១៩ | អង្គការមូលនិធិដុនបូស្កូកម្ពុជា | រាជធានីភ្នំពេញ | ០២៣ ២១៩ ៦៨០ |
| ២០ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូនារីទួលគោក | រាជធានីភ្នំពេញ | ០១៦ ៣៤៣ ០៦៣ |
| ២១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូទឹកថ្លា | រាជធានីភ្នំពេញ | ០២៣ ៨៨១ ៧៧២ |
| ២២ | សាលាបច្ចេកទេសដុនបូស្កូខេត្តព្រះសីហនុ | ខេត្តព្រះសីហនុ | ០១៥ ៧២៦ ២៦៣ |
| ២៣ | សាលាបច្ចេកទេសដុនបូស្កូបាត់ដំបង | ខេត្តបាត់ដំបង | ០១២ ៧៨៨ ៦៤៧ |
| ២៤ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន | រាជធានីភ្នំពេញ | ០២៣ ២១១ ៦៧៣ |
| ២៥ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកូរ៉េ | រាជធានីភ្នំពេញ | ០២៣ ២២០ ៤៥៧ |
| ២៦ | មជ្ឈមណ្ឌលទ្រទ្រង់ក្រសួងកូរ៉េ យេស៊ូចាមាហិ | រាជធានីភ្នំពេញ | ០២៣ ២១៦ ១២៨ |
| ២៧ | អង្គការក្រៅរដ្ឋាភិបាលបរទេស អេអិលស៊ី កុមុយនីកេសិនន៍ | រាជធានីភ្នំពេញ | ០២៣ ៩៨៦ ៧៨១ |
| ២៨ | សាលាសណ្ឋាគារ និងទេសចរណ៍ ប៉ូល ឌុយប្រ៊ូល | ខេត្តសៀមរាប | ០៦៣ ៩៦៣ ៦៧២ |
| ២៩ | អង្គការជួយកម្ពុជា | ខេត្តសៀមរាប | ០១២ ៧៣៧ ៩១៣ |
| ៣០ | សមាគមសម្រស់កញ្ញាកុមារខ្មែរ | រាជធានីភ្នំពេញ | ០១២ ៩២៨ ០៥៩ |
| ៣១ | អង្គការដើម្បីភាពញញឹមនៃកុមារ | រាជធានីភ្នំពេញ | ០២៣ ៩៩៥ ៦៦០ |
| ៣២ | អង្គការអោហ្វេស៊ីបកម្ពុជា | រាជធានីភ្នំពេញ | ០២៣ ៨៨៤ ១២៣ |
| ៣៣ | អង្គការគម្រោងកាម៉ូណូហាសុិ | រាជធានីភ្នំពេញ | ០៩២ ៣៩៨ ៤៣១ |
| ៣៤ | អង្គការ វ៉េក អន្តរជាតិកម្ពុជា | រាជធានីភ្នំពេញ | ០១២ ២៦៧ ៨០០ |
| ៣៥ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឡូស្កូយ៉ាតូឡូ អនឡឺស | ខេត្តបាត់ដំបង | ០២៣ ២២០ ៨២៤ |


តទៅទំព័របន្ទាប់

## ២. ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

### ២.ក. ថវិកាតាមកម្មវិធីអភិវឌ្ឍការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យប្រកបដោយគុណភាព និងមានការចូលរៀនប្រកបដោយសមធម៌

ថវិកានេះបានផ្តល់ជូនដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទទាំង ៣៨ សម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញរយៈពេលវែង និងខ្លី។ ហើយមួយផ្នែកទៀតផ្តល់ជូនដល់អង្គភាពបណ្តុះបណ្តាលទាំងសាធារណៈ ឯកជន សមាគម និងអង្គការក្រៅរដ្ឋាភិបាល តាមរយៈមូលនិធិជាតិបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រសម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញរយៈខ្លីលើមុខជំនាញបច្ចេកទេស ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ទេសចរណ៍ និងកសិកម្ម។

### ២.ខ. គម្រោង "មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលគម្រោង *"មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី"* សម្រាប់បណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនដល់កម្មករ កម្មការិនី និងយុវជន យុវនារី ដែលបាត់បង់ និងគ្មានការងារធ្វើ នៅរាជធានីភ្នំពេញ-ខេត្តកណ្តាល ព្រះសីហនុ សៀមរាប និងខេត្តមួយចំនួនទៀតដែលមាន ឬអាចមានតំបន់សេដ្ឋកិច្ចពិសេសដូចជាខេត្តស្វាយរៀង តាកែវ កោះកុង បន្ទាយមានជ័យ និងខេត្តកំពង់ចាម រយៈពេល៣ឆ្នាំ ពីឆ្នាំ២០១១-២០១៣ ក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាលនេះសិក្ខាកាមនឹងទទួលបានអាហារូបករណ៍ និងប្រាក់ឧបត្ថម្ភជាថវិកាចំនួន ៤.០០០រៀល ក្នុង ១ថ្ងៃសម្រាប់ការហូបចុក និងចំនួន ៤០.០០០រៀល ក្នុង ១ខែ សម្រាប់ការស្នាក់នៅ។ នៅក្នុងឆ្នាំ២០១១នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមគម្រោង **"មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី"** ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម៖

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខៈ ១០៥ ក.ប/ស.ជ.ណ

**សេចក្តីជូនដំណឹង**
**ស្តីពីវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ**
**ក្រោមគម្រោង "មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី"**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនឲ្យបានជ្រាបថា រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យ **មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនដល់កម្មករ កម្មការិនី និងយុវជន យុវនារី ដែលបាត់បង់ និងគ្មានការងារធ្វើ នៅរាជធានីភ្នំពេញ-ខេត្តកណ្តាល ព្រះសីហនុ សៀមរាប និងខេត្តមួយចំនួនទៀតដែលមាន ឬអាចមានតំបន់សេដ្ឋកិច្ចពិសេសដូចជាខេត្តស្វាយរៀង តាកែវ កោះកុង បន្ទាយមានជ័យ និងខេត្តកំពង់ចាម រយៈពេល ៣ឆ្នាំ ពីឆ្នាំ២០១១-២០១៣។ នៅក្នុងឆ្នាំ២០១១នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបើកវគ្គបណ្តុះបណ្តាលជូនដល់ក្រុមគោលដៅខាងលើ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្ថិតក្រោមឱវាទក្រសួងផ្ទាល់តាមបណ្តារាជធានី-ខេត្តដូចដែលបានរៀបរាប់ខាងលើ។ ក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាលនេះសិក្ខាកាមនឹងទទួលបានអាហារូបករណ៍ និងប្រាក់ឧបត្ថម្ភជាថវិកាចំនួន ៤.០០០រៀល ក្នុង ១ថ្ងៃសម្រាប់ការហូបចុក និងចំនួន ៤០.០០០រៀល ក្នុង ១ខែ សម្រាប់ការស្នាក់នៅ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើសូម កម្មករ កម្មការិនី និងយុវជន យុវនារី ដែលមានចំណាប់អារម្មណ៍លើមូលនិធិពិសេសនេះ សូមមកធ្វើការទំនាក់ទំនងព័ត៌មានលម្អិតនៅនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី ឬនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រាជធានី-ខេត្ត ដែលស្ថិតនៅក្រោមឱវាទក្រសួងផ្ទាល់ នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១
រដ្ឋមន្ត្រី
វង សូត

ចម្លងជូន
-ខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ
-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
-គ្រឹះស្ថានសិក្សាក្រោមឱវាទ
"ដើម្បីជួយផ្សព្វផ្សាយ"
-កាលប្បវត្តិ-ឯកសារ
-ទូរស័ព្ទទំនាក់ទំនង: ០១៧ ៤១៤ ៧៤៨/០១២ ២២៣ ១៤៥
-ភ្ជាប់ជាមួយនូវបញ្ជីឈ្មោះគ្រឹះស្ថានដែលធ្វើការបណ្តុះបណ្តាល

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៩ និងទូរសារ :(០២៣)៨៨ ២៧ ២៩*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

បញ្ជីឈ្មោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
ដែលធ្វើការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដល់កម្មករ កម្មការិនី
និងយុវជន យុវនារី ដែលបាត់បង់ និងគ្មានការងារធ្វើ ក្រោមគម្រោង
"មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី" ឆ្នាំ២០១១

| ល-រ | គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ទីតាំង | លេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| ១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | រាជធានីភ្នំពេញ | ០១៦ ៨៤៤ ៧៤១ |
| ២ | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | រាជធានីភ្នំពេញ | ០១២ ៦៦៧ ៧៥៣ |
| ៣ | វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | រាជធានីភ្នំពេញ | ០៩២ ៤៩២ ០០៥ |
| ៤ | វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | រាជធានីភ្នំពេញ | ០១២ ៨២៦ ៤០៤ |
| ៥ | វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម | រាជធានីភ្នំពេញ | ០៩២ ៣៥៥ ៩៦៧ |
| ៦ | មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-កូរ៉េ | រាជធានីភ្នំពេញ | ០១២ ៨០៦ ៦៣១ |
| ៧ | មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ | រាជធានីភ្នំពេញ | ០៩២ ៨២៧ ០៨៤ |
| ៨ | សាលាមធ្យមសិក្សាបច្ចេកទេស JVC | រាជធានីភ្នំពេញ | ០១២ ៧៣៧ ១៥៦ |
| ៩ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល | ខេត្តកណ្តាល | ០១២ ៩៤៦ ៩២៦ |
| ១០ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ | ខេត្តតាកែវ | ០៩២ ៩៧៤ ៧៩៥ |
| ១១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ | ខេត្តព្រះសីហនុ | ០១៦ ៩០៧ ៥១៨ |
| ១២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង | ខេត្តកោះកុង | ០១២ ៣៥១ ៩៤៣ |
| ១៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ | ខេត្តបន្ទាយមានជ័យ | ០៧៧ ៩៦៩ ៨៥៨ |
| ១៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | ខេត្តសៀមរាប | ០១២ ៩១៨ ១៦៧ |
| ១៥ | ការដ្ឋានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | ខេត្តសៀមរាប | ០១២ ៩៣៧ ០៥៦ |
| ១៦ | មជ្ឈមណ្ឌលកោសល្យវប្បកម្មជាតិខេត្តសៀមរាប | ខេត្តសៀមរាប | ០១២ ២៨៥ ៣១៣ |
| ១៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម | ខេត្តកំពង់ចាម | ០១១ ៨៦៥ ៤០៧ |
| ១៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង | ខេត្តស្វាយរៀង | ០៨៩ ៧៦៤ ២៤២ |

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១
អ្នកធ្វើតារាង

ថុង សាម៉ុន

បានឃើញ និងឯកភាព
ប្រធាននាយកដ្ឋានស្តីទី

ហ៊ីង_ស៊ីផេត

## ២.គ. *ការអនុវត្តន៍គម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (STVET) ជំនួយធនាគារអភិវឌ្ឍន៍អាស៊ីលេខ 0178-CAM*

| អង្គភាពអនុវត្តគម្រោង |
|---|
| អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អាសយដ្ឋាន៖ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ទូរស័ព្ទ/ទូរសារ: ០២៣ ៨៨២ ៩០១ / អ៊ីម៉ែល: tvetproject@gmail.com / គេហទំព័រ: http://www.ntb.gov.kh/stvet/ |

| គោលបំណង ផលប៉ះពាល់ និងលទ្ធផល |
|---|
| • **គោលបំណង** |
| ដើម្បីធានាបានការពង្រីកប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) សាធារណៈមួយ ដោយមានការគាំទ្រពីផ្នែកឧស្សាហកម្ម ហើយផ្សារភ្ជាប់ទៅនឹងតម្រូវការជំនាញនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ |
| • **ផលប៉ះពាល់** |
| ដើម្បីពង្រីកការងារដែលមានស្រាប់ កម្លាំងពលកម្មជាតិកម្រិតកណ្តាល ទាំងនៅជនបទ និងទីក្រុង។ យើងរំពឹងថានៅឆ្នាំ២០២០ ចំនួននិយោជិត ដែលមានគុណវុឌ្ឍិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងប្រព័ន្ធនឹងកើនឡើង ៣០% យ៉ាងតិច ហើយនិយោជកកាន់តែពេញចិត្តចំពោះនិយោជិតទាំងនោះ។ |
| • **លទ្ធផល** |
| ប្រព័ន្ធបណ្តុះបណ្តាលមួយដែលបានពង្រីក និងធ្វើសមាហរណកម្មបានច្រើនមានការគាំទ្រពីឧស្សាហកម្ម ផ្សារភ្ជាប់ជាមួយតម្រូវការជំនាញកម្រិតមូលដ្ឋាន និងពាក់កណ្តាលជំនាញនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធក្នុងវិស័យទាំងបី៖ យន្តសាស្ត្រ សំណង់ ពាណិជ្ជសាស្ត្រ និងបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា។ |

| គម្រោងនឹងផ្តល់លទ្ធផលចំនួន ០៣ គឺ៖ |
|---|
| *ក. លទ្ធផលទី១៖* កម្មវិធីក្នុងប្រព័ន្ធដែលទាក់ទងកាន់តែច្រើននឹងផ្នែកឧស្សាហកម្ម |
| *ខ. លទ្ធផលទី២៖* គុណភាពនៃការបណ្តុះបណ្តាលក្រៅប្រព័ន្ធត្រូវបានពង្រីក និងធ្វើឱ្យកាន់តែប្រសើរឡើង |
| *គ. លទ្ធផលទី៣៖* បានពង្រឹងសមត្ថភាពស្ថាប័នក្នុងការរៀបចំ និងការគ្រប់គ្រងផែនការ TVET |

ក្នុងឆ្នាំ២០១១នេះមានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងខេត្តចំនួន ០៧ ដែលបាននឹងកំពុងអនុវត្តគម្រោងនេះដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង វិទ្យាស្ថានពហុបច្ចេកទេសបាត់ដំបង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង។

## ២.ឃ. *ការអនុវត្តន៍គម្រោងមូលនិធិជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រ* ADB/JFPR 9133-CAM

### ◈ គោលបំណង

គោលបំណងនៃបច្ចេកទេសក្រោយប្រមូលផល ការកែច្នៃអាហារ និងទីផ្សារ គឺដើម្បីបង្កើតឡើងនូវប្រព័ន្ធបណ្តុះបណ្តាលថ្នាក់ជាតិមួយ សម្រាប់បង្រៀនដល់កសិករ ឬអ្នកដាំដុះដើម្បី៖

- អនុវត្តនូវការគ្រប់គ្រងបច្ចេកទេសក្រោយប្រមូលផលបន្លែ ផ្លែឈើ រួមមាន៖ ការងារប្រមូលផលនៅចំការ ការស្តុកទុក ការវេចខ្ចប់ ការដឹកជញ្ជូន និងការងារដាក់លក់នៅទីផ្សារ។
- កំណត់តំបន់ និងទីផ្សារផលិតផលនៃខេត្តទិសដៅនីមួយៗ
- អនុវត្តនូវបច្ចេកទេសកែច្នៃអាហារសមស្រប ដែលអាចលក់បានពីផលិតផលបន្លែ ផ្លែឈើដែលលើសតម្រូវការ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារ។
- ពិសោធន៍លើអនាម័យ និងសុវត្ថិភាពអាហារ និងរៀបចំនូវនិន្នភោពបណ្តុះបណ្តាលជុំវិញប្រធានបទទាំងនោះ។

តទៅទំព័របន្ទាប់

- ជាទិសដៅនៃការបង្កើតសហគ្រាសខ្នាតតូច ដើម្បីគាំទ្រដល់ផលិតកម្មកែច្នៃអាហារនៅតាមឃុំជាមូលដ្ឋាន។

◈ **សកម្មភាព**

- បណ្តុះបណ្តាលគ្រូបង្គោល និងសាងសង់មន្ទីរពិសោធន៍អាហារសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈខេត្តទាំងបួន។
- សហការជាមួយឃុំទាំង៤៤ ដើម្បីស្វែងយល់ពីតម្រូវការទីផ្សារ សម្រាប់ផលិតផលស្រស់ និងកែច្នៃ។
- បណ្តុះបណ្តាលកសិករ ឬអ្នកដាំដុះប្រមាណ ៣,០០០នាក់ នៅក្នុងឃុំទាំងនោះ ជុំវិញការអនុវត្តន៍បច្ចេកទេសក្រោយប្រមូលផល ការរក្សាទុក និងកែច្នៃអាហារ អនាម័យសុវត្ថិភាពអាហារ និងការគ្រប់គ្រងមុខរបរខ្នាតតូច។
- ជួយក្នុងការបង្កើតឲ្យមានសហគ្រាសខ្នាតតូចនៅតាមឃុំជាមូលដ្ឋាន ដើម្បីបង្កើនសមត្ថភាពផលិតកម្ម កែច្នៃ និងដើម្បីជួយដោះស្រាយបញ្ហាទីផ្សារសម្រាប់ផលិតផលស្រស់ និងកែច្នៃ។

| **គម្រោង JFPR នេះមានកម្មវិធីចំនួន ០៣ធំៗគឺ៖** |
|---|
| *១. កម្មវិធីស្ពានចម្លងបន្តជំនាញ* |
| អនុវត្តសាកល្បងជាមួយសិស្សដែលបោះបង់ចោលការសិក្សាប្រមាណ ៧០០នាក់ ដើម្បីបង្កើតប្រព័ន្ធបណ្តុះបណ្តាល ថ្នាក់ជាតិ សម្រាប់ផ្តល់ឱកាសទីពីរដល់អ្នកដែលបោះបង់ចោលការសិក្សាដើម្បីមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ទទួលបាននូវការបណ្តុះបណ្តាលជំនាញកម្រិតសញ្ញាបត្រនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ទាំង ៣៨។ |
| *២. បច្ចេកទេសក្រោយប្រមូលផល* |
| ក. ដើម្បីរក្សា និងបង្កើននូវគុណភាពផលិតផលរួមមាន៖ រូបរាង រស់ជាតិ និងសារជាតុចិញ្ចឹម។<br>ខ. ដើម្បីកាត់បន្ថយការបាត់បង់ក្នុងរាល់សកម្មភាព ចាប់ពីពេលប្រមូលផលដល់ការប្រើប្រាស់។<br>គ. ដើម្បីការពារសុវត្ថិភាពអាហារ ដើម្បីកុំឲ្យផលិតផលខូច(តើត្រូវប្រមូលផលដូចម្តេច?)បែងចែកចំណាត់ថ្នាក់ដើម្បីលក់ផលិតផលបានថ្លៃ វេចខ្ចប់ និងដឹកជញ្ជូនបានត្រឹមត្រូវ ដើម្បីការពារផលិតផល វេចខ្ចប់ដោយថង់ប្លាស្ទិច គឺរក្សាទំងន់ ពណ៌ និងរូបរាង្គ ស្តុកទុកត្រជាក់ដោយរំហួតជួយរក្សាផលិតផលបានយូរហើយសមស្របសម្រាប់ជនបទ។ |
| *៣. ការកែច្នៃអាហារ* |
| *ហេតុអ្វីត្រូវធ្វើការកែច្នៃផលិតផល?*<br>ក. រក្សាទុក និងកែច្នៃផលិតផលដែលលើសតម្រូវការ<br>ខ. បង្កើតតម្លៃបន្ថែមសម្រាប់ផលិតផល និង<br>គ. សុវត្ថិភាពក្នុងការបរិភោគ<br><br>*អនាម័យ និងសុវត្ថិភាពអាហារ*<br>ក. រក្សាភាពស្អាត<br>ខ. ដាក់អាហារឆៅ-ឆ្អិនដាច់ដោយឡែក<br>គ. ចំអិនអាហារឲ្យបានឆ្អិនល្អ<br>ឃ. ទុកដាក់អាហារនៅសីតុណ្ហភាពត្រឹមត្រូវ<br>ង. ប្រើប្រាស់ទឹកស្អាត និងវត្ថុធាតុដើមល្អ |

*២.ង. មូលនិធិបង្កើតមុខរបរដោយខ្លួនឯង*

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនត្រឹមតែផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដល់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្តល់នូវមូលនិធិបង្កើតមុខរបរដោយខ្លួនឯងដល់សិស្ស សិក្ខាកាមនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលទៀតផង ដើម្បីយកទៅប្រកបមុខរបរដោយខ្លួនឯង។ នៅក្នុងដំណើរការនៃការផ្តល់មូលនិធិនេះ តម្រូវឱ្យសិស្ស សិក្ខាកាម ធ្វើការចងក្រងជាក្រុមចាប់ពី ៣ ទៅ ៥នាក់ ជាពិសេសក្នុងក្រុមនីមួយៗត្រូវមានស្ត្រីចាប់ពី ២ នាក់ឡើងទៅ។

# វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- ផ្តល់នូវជំនាញវិជ្ជាជីវៈ ឬអាជីពមួយជាក់លាក់ដល់សិស្ស សិក្ខាកាម
- ផ្គត់ផ្គង់កម្លាំងពលកម្មជំនាញដល់ទីផ្សារការងារ
- បង្កើនគុណភាព និងផលិតភាពការងារឲ្យកាន់តែប្រសើរជាងមុន
- ផ្តល់ និងបង្កើនប្រាក់ចំណូលដល់សិស្ស សិក្ខាកាមដើម្បីរួចផុតពីភាពក្រីក្រ

